CDRI

Cambodia Development Resource Institute

# ឧបសគ្គចំពោះការផលិត និងការប្រើប្រាស់ស្បៀងប្រកបដោយអាហារូបត្ថម្ភ៖ លទ្ធផលរកឃើញក្នុងករណីសិក្សាចំនួនពីរ




អាង-រស្មី អាណានយ៉ា-ខុមឹងប្រូស ឆាំង-ម៉ារ៉ុង
ប៊ុណ្ណាត-ហ្សអ៊ីស៊ីដាណា សូរ-លីហុង និង ងិន-ច័ន្ទរិទ្ធ



ឯកសារពិភាក្សាលេខ ១៤៨
ខែកញ្ញា ឆ្នាំ២០២៤

ឯកសារពិភាក្សាលេខ ១៤៨

# ឧបសគ្គចំពោះការផលិត និងការប្រើប្រាស់ស្បៀង ប្រកបដោយអាហារូបត្ថម្ភ៖ លទ្ធផលរកឃើញក្នុង ករណីសិក្សាចំនួនពីរ

អាង-រស្មី អាណានយ៉ា-ខុមីងប្រូស ឆាំង-ម៉ារ៉ុង
ប៊ុណ្ណាត-ហ្សអ៊ីស៊ីដាណា សូរ-លីហុង និង ងិន-ច័ន្ទរិទ្ធ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ភ្នំពេញ ខែកញ្ញា ឆ្នាំ២០២៤

**គណៈកម្មាធិការនិពន្ធ**

**ចាងហ្វាង៖** អេង នេត្រា
**និពន្ធនាយក៖** ងិន-ច័ន្ទរិទ្ធ
**និពន្ធនាយករង៖** អ៊ុំ ចាន់ថា, ខាត់ ប៊ុនថន

© ២០២៤ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI)

ISBN-13: 978-9924-500-56-8

**សេចក្តីអះអាង**
ទស្សនៈដែលបង្ហាញនៅក្នុងរបាយការណ៍នេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ មិនតំណាងឱ្យទស្សនៈរបស់វិទ្យាស្ថាន CDRI ឬវិទ្យាស្ថានគ្រប់គ្រងទឹកអន្តរជាតិនោះទេ។ អ្នកនិពន្ធត្រូវទទួលខុសត្រូវចំពោះកំហុស ឬកំហុសអចេតនាណាមួយ។ អ្នកនិពន្ធឆ្លើយឆ្លង៖ ងិន-ច័ន្ទរិទ្ធ chanrith.ngin@cdri.org.kh។

**សូមយោងឯកសារនេះថា៖**
Ang Raksmey, Ananya Cumming-Bruce, Chhaing Marong, Bunnath Zoe Sidana, So Lyhong and Ngin Chanrith. 2024. *Barriers to Nutritious Food Production and Consumption: Insights from Two Case Studies.* CDRI Working Paper Series No. 148. Phnom Penh: CDRI.

**វិទ្យាស្ថាន CDRI**
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ ៨៨១៧០១, ៨៨១៩១៦, ៨៨៣៦០៣
ទូរសារ៖ +៨៥៥២៣ ៨៨០៧៣៤
អ៊ីមែល៖ cdri@cdri.org.kh    http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ ចាន់ថា និង ទឹម បូរិទ្ធ
ប្រែសម្រួលដោយ៖ ជិន ចាន់ណា

# មាតិកា

តារាងអក្សរកាត់ ....................................................................................................................... VI
សេចក្តីថ្លែងអំណរគុណ ....................................................................................................................... VII
សេចក្តីសង្ខេប ....................................................................................................................... VII
១. សេចក្តីផ្តើម ....................................................................................................................... 1
២. ការវិភាគលើវិវេចនាឯកសារ ....................................................................................................................... 3
២.១. ការយល់ដឹងអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ....................................................................................... 3
២.២. កត្តាសេដ្ឋកិច្ច-សង្គមដែលប៉ះពាល់ដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ....................................................... 4
២.៣. សន្តិសុខស្បៀង អាហារូបត្ថម្ភ និងសមភាពយេនឌ័រ ....................................................................................... 6
២.៤. សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធាន ....................................... 8
៣. វិធីសាស្ត្រ ....................................................................................................................... 11
៣.១ តំបន់ដែលបានធ្វើការសិក្សា ....................................................................................................... 11
៣.២ ការប្រមូលទិន្នន័យ ....................................................................................................... 13
៣.៣ ការវិភាគទិន្នន័យ ....................................................................................................... 14
៤. លទ្ធផលស្រាវជ្រាវ ....................................................................................................................... 14
៤.១ បរិបទ ....................................................................................................... 14
៤.២ ការផ្សព្វផ្សាយ និងការទទួលបានព័ត៌មានស្តីពីអាហារូបត្ថម្ភ ....................................................................... 15
៤.៣ ការចំណាយ និងស្បៀងអាហារ ....................................................................................................... 19
៤.៤ ផលិតកម្មស្បៀងអាហារ ....................................................................................................... 20
៤.៥. ការចាត់ចែងស្បៀងអាហារក្នុងគ្រាខ្វះខាត និងផលប៉ះពាល់នៃផលិតកម្មស្បៀងអាហារ ....................................... 22
៥. ការពិភាក្សា ....................................................................................................................... 25
៦. សេចក្តីសន្និដ្ឋាន ....................................................................................................................... 30
៧. អនុសាសន៍ ....................................................................................................................... 31
៨. ដែនកំណត់ និងទិសដៅសម្រាប់ការស្រាវជ្រាវបន្ថែម ....................................................................................... 32
ឧបសម្ព័ន្ធ ....................................................................................................................... 33
ឯកសារយោង ....................................................................................................................... 34
ស៊េរីឯកសារពិភាក្សា ....................................................................................................................... 41

# បញ្ជីរូបភាព និងតារាង

រូបភាពទី១៖ ផែនទីនៃទីតាំងសម្រាប់ធ្វើការសិក្សា ....................................................................................... 12

តារាងទី១៖ ការធ្វើសំណាក និងទំហំនៃសំណាក ....................................................................................... 13
តារាងទី២៖ របាយនៃសំណាកសរុបតាមតំបន់/ឃុំនីមួយៗ ....................................................................................... 13

តារាង ក១៖ ព័ត៌មានលម្អិតនៃក្រុមគោលដៅ និងទីតាំងសិក្សាសម្រាប់ការសម្ភាស ....................................................... 33

# តារាងអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CARD | ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| CASIC | សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា |
| CDRI | វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CFR | ស្រះជម្រកត្រីសហគមន៍ |
| FAO | អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ |
| FGD | ការពិភាក្សាក្រុម |
| FWUC | សហគមន៍កសិករអ្នកប្រើប្រាស់ទឹក |
| FSN | សន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| GIZ | កិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| ID-Poor | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| IFAD | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម |
| IFPRI | វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអាហារអន្តរជាតិ |
| KII | ការសម្ភាសអ្នកផ្ដល់ព័ត៌មានគន្លឹះ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NSFSN | យុទ្ធសាស្ត្រជាតិស្ដីពីស្បៀង និងអាហារូបត្ថម្ភ |
| TWG-SP&FSN | ក្រុមការងារបច្ចេកទេសផ្នែកគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |
| WHO | អង្គការសុខភាពពិភពលោក |

## សេចក្តីថ្លែងអំណរគុណ

អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ គំនិតផ្តួចផ្តើមស្រាវជ្រាវរបស់ ក្រុមពិគ្រោះយោបល់ស្តីពីការស្រាវជ្រាវកសិកម្មអន្តរជាតិ (CGIAR) គម្រោងមហាដីសណ្តរនៅអាស៊ី (Asian Mega-Deltas) និងផលប៉ះពាល់យេនឌ័រនៃវេទិកា CGIAR សម្រាប់ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ការសិក្សានេះ។ យើងខ្ញុំសូមអរគុណដល់អ្នកផ្តល់មូលនិធិទាំងអស់ ដែលបានគាំទ្រការងារនេះតាមរយៈការរួមចំណែករបស់ពួកគេចំពោះមូលនិធិ CGIAR Trust។ របាយការណ៍នេះ ផ្តល់នូវអត្ថប្រយោជន៍ដែលជាលទ្ធផលរកឃើញ ចែករំលែកដោយសប្បុរសពី ក្រុមអ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នា ចំពោះការចូលរួមចំណែកដ៏សំខាន់ នៅក្នុងដំណាក់កាលផ្សេងៗនៃការសិក្សានេះ។ ជាចុងក្រោយ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះលោក Sanjiv De Silva និងអ្នកជួយពិនិត្យកែសម្រួលអនាមិកម្នាក់ទៀត ដែលបានជួយពិនិត្យឡើងវិញយ៉ាងយកចិត្តទុកដាក់លើសេចក្តីព្រាងលើកមុននៃរបាយការណ៍នេះ។

## សេចក្តីសង្ខេប

ប្រទេសកម្ពុជាបានបោះជំហានទៅមុខគួរឱ្យកត់សម្គាល់ ក្នុងការកាត់បន្ថយភាពក្រីក្រ និងជំរុញការអភិវឌ្ឍធនធានមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ មួយផ្នែកធំនៃចំនួនប្រជាជនកម្ពុជា នៅតែងាយទទួលរងគ្រោះពីភាពក្រីក្រ អសន្តិសុខស្បៀង កង្វះអាហារូបត្ថម្ភ និងវិបត្តិផ្សេងៗ។ ការរាតត្បាតនៃជំងឺកូវីដ-១៩ កាលពីឆ្នាំ២០១៩ រួមជាមួយនឹងវិបត្តិស្បៀងអាហារ និងឥន្ធនៈសកល និងព្រឹត្តិការណ៍ដែលទាក់ទងនឹងអាកាសធាតុថ្មីៗនេះ បានបង្កឱ្យមានស្ថានភាពកាន់តែធ្ងន់ធ្ងរឡើងសម្រាប់មនុស្សជាច្រើន ជាពិសេសសហគមន៍ទាំងឡាយដែលងាយរងគ្រោះទៅនឹងវិបត្តិផ្សេងៗ។

បឹងទន្លេសាប និងដីសណ្តទន្លេមេគង្គរបស់ប្រទេសកម្ពុជា មានសារៈសំខាន់សម្រាប់និរន្តរភាព ចំពោះភាពសម្បូរបែបនៃប្រភេទត្រី ការបង្កបង្កើនផលស្រូវ និងការចិញ្ចឹមជីវិតក្នុងមូលដ្ឋាន ទន្ទឹមនឹងការអភិរក្សជីវចម្រុះផងដែរ។ ទោះជាយ៉ាងណា ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗទាំងនេះ កំពុងប្រឈមនឹងការគំរាមកំហែងយ៉ាងខ្លាំងពីសកម្មភាពមនុស្ស ដូចជាការពង្រីកកសិកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ក៏ដូចជាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ កំណើនសេដ្ឋកិច្ចឆាប់រហ័សនៅតំបន់ កំពុងដាក់សម្ពាធយ៉ាងសម្បើមលើធនធានដែលមាន ដែលនាំឱ្យមានភាពតានតឹងលើតុល្យភាពសង្គម-អេកូឡូស៊ី។ នៅក្នុងប្រទេសកម្ពុជា បញ្ហាប្រឈមនៃការសម្រេចបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភមានលក្ខណៈកាន់តែស្មុគស្មាញ៖ ទោះបីមានរបបអាហារច្រើនមុខក៏ដោយ ក៏កង្វះអាហារូបត្ថម្ភកើតមានជាហូរហែរ ដោយសារតែការរីករាលដាលនៃអសន្តិសុខស្បៀង និងកង្វះចំណេះដឹងផ្នែកអាហារូបត្ថម្ភ។ អង្ករ និងត្រី គឺជាអាហារចម្បងដ៏សំខាន់ជាងគេសម្រាប់ប្រជាជនកម្ពុជាទាំងមូល។

យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN) លើកទី២ ឆ្នាំ២០១៩-២០២៣ បង្កើតជាមូលដ្ឋាននៃវិធីសាស្ត្របច្ចុប្បន្នរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហានេះ ដោយមានគោលបំណងធានាឱ្យមានសិទ្ធិទទួលបានអាហារូបត្ថម្ភដោយសមធម៌ ទន្ទឹមនឹងការពង្រឹងសហគមន៍ និងយន្តការអភិបាលកិច្ចសំដៅដោះស្រាយបញ្ហាភ្លាមៗ និងយូរអង្វែង។ វាគឺជាយុទ្ធសាស្ត្រដ៏ទូលំទូលាយ និងមានមហិច្ឆតា ហើយជាបញ្ហាអាទិភាពខ្ពស់សម្រាប់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងណា អ្វីដែលបានរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ មិនមែនជាការបកស្រាយក្នុងកម្រិតនៃការយកចិត្តទុកដាក់ស្រដៀងគ្នា នៅក្នុងគ្រប់កម្រិតមូលដ្ឋានទាំងអស់នោះទេ ព្រោះថាឧបសគ្គចម្បងនៃភាពជោគជ័យ គឺកង្វះការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងស្ថាប័នគ្រប់ជាន់ថ្នាក់។

ការសិក្សានេះ បានឈ្វេងយល់ពីសក្តានុពលដ៏ស្មុគស្មាញនៃការផលិត និងការប្រើប្រាស់អាហារនៅក្នុងតំបន់ទំនាបលិចទឹកបឹងទន្លេសាប និងតំបន់ដីសណ្តទន្លេមេគង្គរបស់ប្រទេសកម្ពុជា ដោយផ្តោតលើឧបសគ្គចំពោះការយល់ដឹងអំពីលំអាននៃការផលិត និងការប្រើប្រាស់ស្បៀងអាហារ និងកត្តាជំរុញនានា។ ជាមួយនឹងការប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ការសិក្សានេះបានប្រមូលទិន្នន័យតាមរយៈការពិភាក្សាក្រុម (FGD) និងការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ (KII)។ ការពិភាក្សា និងការសម្ភាសមានការចូលរួមពីបុគ្គលចម្រុះជាច្រើននាក់ ដែលរស់នៅក្នុងទីតាំងពីរផ្សេងគ្នា៖ ស្រះជម្រកត្រីសហគមន៍បឹងរៀមក្នុងខេត្តកំពង់ធំ និងគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង ក្នុងខេត្តតាកែវ។

លទ្ធផលនៃការសិក្សា គឺបង្ហាញទិដ្ឋភាពច្រើនយ៉ាង ដោយរំលេចឱ្យឃើញថា លំអាននៃការបរិភោគចំណីអាហារ មិនគ្រាន់តែជាបញ្ហាទាក់ទងនឹងជម្រើសផ្ទាល់ខ្លួននោះទេ ប៉ុន្តែផ្ទុយទៅវិញ វាបានជះឥទ្ធិពលដោយអន្តរកម្មដ៏ស្មុគស្មាញនៃកត្តារួមផ្សំនានា រួមទាំងចំណង់ចំណូលចិត្តលើចំណីអាហារ ភាពអាចរកបាន និងតម្លៃសមរម្យនៃចំណីអាហារ ការទទួលបានព័ត៌មានដែលអាចទុកចិត្តបានអំពី អាហារូបត្ថម្ភ សមត្ថភាពស្ថាប័ន ក្នុងការផ្តល់ផែនការឆ្លើយតបចំពោះអាហារូបត្ថម្ភ តួនាទីយេនឌ័រ និងស្ថានភាពសេដ្ឋកិច្ច-សង្គម។ លទ្ធផលដ៏គួរឱ្យកត់សម្គាល់មួយនៃការសិក្សានេះ គឺគម្លាតចំណេះដឹង និងការយល់ដឹងអំពីអាហារូបត្ថម្ភ ក្នុងចំណោមអ្នកចូលរួមឆ្លើយសំណួរ។ កង្វះព័ត៌មាននេះ ត្រូវបានរួមផ្សំបន្ថែមដោយបញ្ហាប្រឈមក្នុងការផលិតស្បៀង ដែលត្រូវបានកំណត់ដោយការប្រែប្រួលកសិអេកូឡូស៊ី កង្វះការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលស្តីពីកសិកម្ម និងបញ្ហាទាក់ទងនឹងការគ្រប់គ្រងធនធានទឹក។ ទោះបីជាមានការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាអសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅថ្នាក់ជាតិក៏ដោយ ការសិក្សានេះបានរកឃើញវិធីសាស្ត្រផ្សេងៗ ដែលមានលក្ខណៈមិនមាំទាំ និងកង្វះការសម្របសម្រួលទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត។

ដោយមើលឃើញពីលទ្ធផលទាំងនេះ ទើបការសិក្សានេះ បានដាក់ចេញនូវអនុសាសន៍មួយចំនួនផងដែរ។ អនុសាសន៍ទាំងនេះ រួមមាន អន្តរាគមន៍ក្នុងគោលបំណងកែលម្អលទ្ធភាពទទួលបានព័ត៌មាន ស្តីពីអាហារូបត្ថម្ភ ដោះស្រាយឧបសគ្គចំពោះផលិតកម្មស្បៀង និងផ្តល់ការគាំទ្រដល់គ្រួសារនីមួយៗ។ ការសិក្សានេះសបញ្ជាក់ពីសារៈសំខាន់នៃវិធីសាស្ត្ររួមមួយ ដែលរួមបញ្ចូលការអប់រំអាហារូបត្ថម្ភ ទៅក្នុងផែនការអភិវឌ្ឍន៍ឱ្យរឹតតែទូលំទូលាយជាងនេះ។ វិធីសាស្ត្រនេះ បានពន្យល់ហេតុផលសំខាន់ៗសម្រាប់ការកសាងភាពធន់ ការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា ក្នុងរយៈពេលយូរអង្វែង។ ដូច្នេះ គេត្រូវសង្កត់ធ្ងន់លើតម្រូវការចាំបាច់សម្រាប់វិធីសាស្ត្រពហុវិស័យ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធក្នុងវិស័យផ្សេងៗ ដើម្បីដោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា។ ចំណុចនេះមានសារៈសំខាន់ណាស់ ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងលើកកម្ពស់គុណភាពជីវិតជារួមរបស់ប្រជាជនទាំងមូល។

អនុសាសន៍សម្រាប់គោលនយោបាយ រួមមាន៖

- ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ ក្នុងការរៀបចំ និងគ្រប់គ្រងអាហារូបត្ថម្ភ និងសេវាផ្សព្វផ្សាយព័ត៌មាន និងការពង្រឹងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងផែនការវិនិយោគឃុំ-សង្កាត់ រយៈពេលបីឆ្នាំរំកិលសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- ការពង្រីកកម្មវិធីជំនួយសង្គម ដើម្បីកាត់បន្ថយឧបសគ្គលើសេវាសុខភាព និងអាហារូបត្ថម្ភ ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ ដូចជាស្ត្រី និងកុមារ សំដៅបង្កើនការទទួលទានអាហារសម្បូរជីវជាតិ។
- ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីអាហារសម្បូរជីវជាតិដែលមានតម្លៃសមរម្យ និងការលើកកម្ពស់ទម្លាប់ទទួលទានរបបអាហារដែលផ្តល់សុខភាពល្អ។ ការទទួលស្គាល់ និងគាំទ្រតួនាទីរបស់ស្ត្រីលើផ្នែកអាហារូបត្ថម្ភក្នុងគ្រួសារ និងរួមទាំងបុរសក្នុងការអប់រំអាហារូបត្ថម្ភ ដើម្បីធ្វើឱ្យមានតុល្យភាពទំនួលខុសត្រូវក្នុងគ្រួសារ។
- ការកសាងភាពធន់នឹងអាកាសធាតុ នៅក្នុងប្រព័ន្ធផលិតកម្ម និងចែកចាយស្បៀង ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ដោយធានាឱ្យមានស្ថិរភាពនៃការផលិត និងការប្រើប្រាស់ស្បៀងអាហារ។

# ១. សេចក្តីផ្តើម

ក្នុងរយៈពេលពីរទសវត្សរ៍មុនការរាតត្បាតនៃជំងឺកូវីដ-១៩ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានរីកចម្រើនយ៉ាងឆាប់រហ័ស ដែលឈានទៅដល់ការរំពឹងទុកថា នឹងបញ្ចប់ពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច នៅត្រឹមឆ្នាំ២០២៧ (អង្គការសហប្រជាជាតិ នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមឆ្នាំ២០២១)។ ប្រទេសកម្ពុជាមានគោលដៅសម្រេចឱ្យបានស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់ នៅត្រឹមឆ្នាំ២០៣០ និងស្ថានភាពចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០ (RGC 2023)។ ទោះជាយ៉ាងណា ១៥% នៃចំនួនប្រជាជន នៅតែស្ថិតក្នុងភាពក្រីក្រ និងងាយរងគ្រោះទៅនឹងវិបត្តិសេដ្ឋកិច្ច (Karamba et al. 2022)។ ជំងឺរាតត្បាត រួមជាមួយនឹងវិបត្តិជាសកល និងការប្រែប្រួលអាកាសធាតុ រឹតតែធ្វើឱ្យស្ថានភាពកាន់តែដុនដាបទៅៗសម្រាប់មនុស្សជាច្រើន ជាពិសេសក្រុមទាំងឡាយដែលងាយរងគ្រោះទៅនឹងវិបត្តិផ្សេងៗ (WFP 2023)។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល រួមទាំងការផ្ទេរសាច់ប្រាក់ទៅកាន់ ១៧% នៃចំនួនប្រជាជនក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះ ៣% នៅឆ្នាំ២០២០ ហើយអត្រានៃភាពក្រីក្របានកើនឡើង ២,៨% ជាលើកដំបូង (Karamba et al. 2022)។

ជាមួយគ្នានេះ ភាពងាយរងគ្រោះរបស់ប្រទេសកម្ពុជាចំពោះគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ បានគំរាមកំហែងដល់ផលិតភាពកសិកម្ម ការចិញ្ចឹមជីវិត សន្តិសុខស្បៀង និងអាហារូបត្ថម្ភ រឹតតែធ្វើឱ្យភាពក្រីក្រក្នុងគ្រួសារជាច្រើនចុះដុនដាបទៅៗ (Smith 2023)។ ប្រទេសកម្ពុជា ជាប់ចំណាត់ថ្នាក់ទី១៤ ក្នុងចំណោម ១៨០ប្រទេស នៅលើសន្ទស្សន៍ហានិភ័យអាកាសធាតុសម្រាប់ឆ្នាំ២០០០-២០១៩ (Eckstein, David និង Laura 2021)។ ការកើនឡើងកម្ដៅ និងគ្រោះមហន្តរាយដោយអាកាសធាតុ ដូចជាទឹកជំនន់ និងគ្រោះរាំងស្ងួត ជួនកាលនាំឱ្យមានព្រឹត្តិការណ៍ធ្ងន់ធ្ងរឈានដល់ការបាត់បង់ជីវិតមនុស្ស និងប៉ះពាល់ជីវភាពរស់នៅ។ ភាពងាយរងគ្រោះនេះ ត្រូវបានរួមផ្សំដោយនិន្នាការប្រជាសាស្ត្រ លក្ខណៈសេដ្ឋកិច្ច-សង្គម និងសមត្ថភាពបន្សាំនៅមានកម្រិត។

ការរួមចំណែកនៃវិស័យកសិកម្មចំពោះផលិតផលក្នុងស្រុកសរុប បានធ្លាក់ចុះមកនៅត្រឹម ២២% ក្នុងឆ្នាំ២០២០ ប៉ុន្តែ ៥៧% នៃគ្រួសារកសិករនៅតែចូលរួមក្នុងសកម្មភាពកសិកម្មជាធម្មតា។ ក្នុងចំណោមកសិករតូចតាចជិត ៣លាននាក់ ប្រហែលមួយភាគបី មានដីកសិកម្មតិចជាង ១ហិកតា។ ដោយសារការយល់ដឹងពីចរន្តទីផ្សារនៅមានកម្រិត ពួកគេភាគច្រើនបង្កបង្កើនផលស្រូវតាមបែបប្រពៃណី។ ជាលទ្ធផលនាំឱ្យទិន្នផល និងគុណភាពស្រូវ ងាយរងការខូចខាតដោយសារអាកាសធាតុ ជាមួយនឹងប្រព័ន្ធគ្រប់គ្រងខាងក្នុងមានកម្រិត (NIS 2022; WFP 2023)។ ប្រព័ន្ធស្បៀងអាហារអាចធ្វើឱ្យប្រសើរឡើងយ៉ាងខ្លាំងនូវភាពធន់ កាត់បន្ថយភាពក្រីក្រ ពង្រឹងជីវភាពរស់នៅ និងធានាបាននូវលទ្ធភាពទទួលបានរបបអាហារដែលផ្តល់សុខភាពល្អ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមដូចជា ការគ្រប់គ្រងទឹកមិនបានល្អប្រសើរ លទ្ធភាពទទួលបានធាតុចូល និងឥណទានមានកម្រិត ហើយចំណេះដឹងផ្នែកកសិកម្មក៏នៅតែមានកម្រិតដូចគ្នាផងដែរ។ លើសពីនេះ បញ្ហាប្រឈមក្រោយការប្រមូលផល ដូចជាសមត្ថភាពកែច្នៃចំណីអាហារនៅទន់ខ្សោយ និងស្តង់ដាសុវត្ថិភាពចំណីអាហារក៏មិនទាន់ល្អប្រសើរ គឺសុទ្ធសឹងតែជាបញ្ហាដែលតែងកើតមាន។ តម្លៃដើមខ្ពស់នៃខ្សែច្រវាក់ផ្គត់ផ្គង់ ធ្វើឱ្យជម្រើសចំណីអាហារសម្បូរជីវជាតិកាន់តែមានតម្លៃថ្លៃទៅៗ (WFP 2023)។

ដើម្បីបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តគោលនយោបាយ ស្តីពីអាហារូបត្ថម្ភ ក្រោមក្របខណ្ឌយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN) ឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ ឆ្នាំ២០១៩-២០២៣។ គោលនយោបាយនេះ មានគោលបំណងលុបបំបាត់រាល់ទម្រង់នៃកង្វះអាហារូបត្ថម្ភ (កង្វះអាហារូបត្ថម្ភ រួមមានជាអាទិ៍ ការស្គមស្គាំង ការក្រេសក្រិន ការខ្វះទម្ងន់ និងកង្វះមីក្រូសារជាតិ និងកង្វះអាហារូបត្ថម្ភ) និងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ត្រង់ចំណុច «ធានាថាមិនទុកឱ្យនរណាម្នាក់ខ្វះអាហារ ឬរងគ្រោះដោយសារកង្វះអាហារូបត្ថម្ភ»។ ជាពិសេសនោះ គឺស្របតាមគោលដៅទី២ ដែលមានគោលបំណង «បញ្ចប់គ្រោះអត់ឃ្លាន សម្រេចបាននូវសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាពភាព»។ យុទ្ធសាស្ត្រអាហារូបត្ថម្ភ មានគោលបំណងពង្រឹងបរិយាកាសស្បៀងអាហារ (ឧទាហរណ៍ ទីកន្លែង និងវិធីដែលចំណីអាហារត្រូវបានលក់ដូរ និងបរិភោគដោយមនុស្ស) និងការប្រព្រឹត្តរបស់អ្នកប្រើប្រាស់ ដើម្បីជំរុញឱ្យមានជម្រើសចំណីអាហារដែលរឹតតែផ្តល់សុខភាពល្អ និងលើកកម្ពស់ការផលិតស្បៀងអាហារចម្រុះច្រើនយ៉ាង សម្បូរជីវជាតិ និងមាននិរន្តរភាព។

លើសពីនេះ បើយោងតាមទីភ្នាក់ងារ USAID (2018) គោលនយោបាយនេះរួមបញ្ចូលទាំងការណែនាំអំពីរបបអាហារផ្អែកលើចំណីអាហារ ច្បាប់ស្តីពីការដាក់អ៊ីយ៉ូតអំបិលជាកាតព្វកិច្ច និងវិធានការកាត់បន្ថយការប្រើប្រាស់អំបិល/សូដ្យូម និងជំងឺទឹកនោមផ្អែម។ ក្រៅពីនេះ ក៏នៅមានឯកសារបំពេញបន្ថែមផ្សេងទៀតដូចជា ផែនទីបង្ហាញផ្លូវថ្នាក់ជាតិសម្រាប់លើកកម្ពស់អាហារូបត្ថម្ភ (២០១៤-២០២០) និងក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្រ្តស្តីពីការអភិវឌ្ឍ និងការការពារកុមារក្នុងវិស័យកសិកម្ម (២០១៦-២០២០)។ ផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងអាហាររបស់កម្ពុជា សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព បង្ហាញពីចក្ខុវិស័យ ដើម្បីបំបែករង្វង់នៃកង្វះអាហារូបត្ថម្ភអន្តរជំនាន់ ការលើកកម្ពស់ផលិតកម្មក្នុងស្រុក និងឱកាសពាណិជ្ជកម្ម និងការកសាងប្រព័ន្ធដែលកាន់តែធន់នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយផ្សេងៗ (RGC 2021)។ បន្ថែមពីលើគោលនយោបាយជាតិទាំងនេះ ប្រទេសកម្ពុជាក៏បានក្លាយជាផ្នែកមួយនៃចលនាពិភពលោកផងដែរ ដែលប្រមូលផ្តុំដោយមេដឹកនាំជាតិ សង្គមស៊ីវិល អង្គការទ្វេភាគី និងពហុភាគី ម្ចាស់ជំនួយ ធុរកិច្ច និងក្រុមអ្នកស្រាវជ្រាវក្នុងកិច្ចខិតខំរួមគ្នាដើម្បីបង្កើនអាហារូបត្ថម្ភ (USAID 2018)។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្តី ក៏បញ្ហាកង្វះអាហារូបត្ថម្ភនៅតែជាកង្វល់ដ៏ធំមួយ ដោយពុំទាន់មានដំណោះស្រាយឱ្យបានដិតដល់នៅឡើយទេ។ អត្រាប្រេវ៉ាឡង់នៃភាពងាយរងគ្រោះ ដោយសារអសន្តិសុខស្បៀងបានកើនឡើង ៥% នៅក្នុងចន្លោះឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ និងឈានដល់ ២៧,៥% ដែលជាការកើនឡើងលើកដំបូង ក្នុងរយៈពេលជាច្រើនទសវត្សរ៍។ ភាពងាយរងគ្រោះ មានកម្រិតទាបជាងគេបំផុត នៅក្នុងរាជធានីភ្នំពេញ (១៦,៧%) និងនៅតំបន់ទីក្រុងផ្សេងទៀត (២០,៤%) ប៉ុន្តែមានកម្រិតខ្ពស់បំផុតនៅតំបន់ជនបទ (៣២,៨%)។ នៅតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ ដូចជា តំបន់ទន្លេសាប ភាពងាយរងគ្រោះឡើងដល់កម្រិតខ្ពស់រហូតដល់ ៣៥,៥% និងជិត ៣២% នៅតំបន់ខ្ពង់រាប (WFP 2023)។ តម្រូវការ និងការទទួលទានរបបអាហារដែលផ្តល់សុខភាព និងសម្បូរជីវជាតិ នៅពុំទាន់ឈានដល់កម្រិតល្អបំផុតនៅឡើយ ដោយការទទួលទានផ្លែឈើ និងបន្លែនៅមានកម្រិតទាប។ អង្ករ (ឬបាយ) ដែលមានមីក្រូសារជាតិទាប និងមិនសូវមានសារធាតុចិញ្ចឹម មានចំនួនរហូតដល់ ៦៥% នៃការប្រើប្រាស់ថាមពលចំណីអាហារប្រចាំថ្ងៃ ដែលនាំឱ្យខ្វះភាពចម្រុះនៃរបបអាហារ (NIS 2020)។ ជាពិសេស ការប្រព្រឹត្ត និងការសម្រេចចិត្តរបស់អ្នកទទួលទានអាហារ គឺមានទិដ្ឋភាពច្រើនយ៉ាង ហើយប្រហែលជា មិនស្របតាមជម្រើសណែនាំដែលផ្តល់អាទិភាពដល់អាហារូបត្ថម្ភ និងសុខភាពនោះទេ។ ការសម្រេចចិត្តទាំងនេះត្រូវបានបង្កើតឡើងដោយវិសាលគមទូលំទូលាយនៃកត្តារួមផ្សំនានា ដូចជា ទម្លាប់នៃរបបអាហារ បទដ្ឋានសង្គម និន្នាការទីផ្សារ និងលទ្ធភាពទទួលបានព័ត៌មាន ហើយអាចប្រែប្រួលទៅតាមរដូវកាល និងត្រូវបានរឹតត្បិតដោយកម្រិតនៃការយល់ដឹងទាក់ទងនឹងការបរិភោគអាហារដែលមានជីវជាតិ។ មានតែ ៥១% ប៉ុណ្ណោះនៃកុមារតូចៗដែលទទួលទានរបបអាហារត្រឹមត្រូវកម្រិតអប្បបរមាទាក់ទងនឹងភាពចម្រុះ (NIS 2023) ហើយសមាមាត្រក្នុងចំណោមស្ត្រី និងក្មេងស្រីក្នុងអាយុបន្តពូជបានធ្លាក់ចុះដល់ទៅ ២៣% ក្នុងពេលថ្មីៗនេះ។ បន្ថែមពីនេះទៀត ការទទួលទានចំណីអាហារ និងភេសជ្ជៈដែលប៉ះពាល់ដល់សុខភាព មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ (WFP 2023)។

ស្ត្រីកំពុងប្រឈមនឹងហានិភ័យយ៉ាងខ្លាំង ចំពោះការមិនអើពើ ដោយសារទស្សនៈតាមទម្លាប់យេនឌ័រ ការលើកតម្លៃបុរសជាធំ និងឱកាសសេដ្ឋកិច្ចមានកម្រិត ជាពិសេសនៅតាមតំបន់ជនបទ។ នៅក្នុងគ្រួសារខ្លះ ភរិយាមិនមានអំណាចគ្រប់គ្រងស្មើភាពគ្នាជាមួយបុរសទេ ដោយស្វាមីបានរួមចំណែកត្រឹមតែមួយភាគដប់ប៉ុណ្ណោះនៃការងារផ្ទះ និងការថែទាំ។ បន្ថែមពីនេះ ស្ត្រីងាយនឹងរៀបការមុនអាយុ។ កត្តាទាំងនេះរារាំងសមត្ថភាពរបស់ពួកគេក្នុងការរួមចំណែកដោយស្មើភាពគ្នានៅក្នុងសង្គមខាងក្រៅ។ អ្វីដែលដ៏គួរឱ្យតក់ស្លុតនោះ គឺស្ត្រីខ្មែរម្នាក់ក្នុងចំណោមប្រាំនាក់ បានឱ្យដឹងថា ខ្លួនធ្លាប់ទទួលរងអំពើហិង្សា ទាក់ទងនឹងយេនឌ័រក្នុងមួយជីវិតរបស់ពួកគេ (អង្គការសហប្រជាជាតិ ប្រចាំប្រទេសកម្ពុជា ឆ្នាំ២០២១)។

បើគិតពីបរិបទទាំងនេះ អ្វីដែលសំខាន់ គឺការយល់ដឹងពីរបៀបដែលក្រុមមនុស្សមកពីសេដ្ឋកិច្ច-សង្គមផ្សេងៗគ្នាផលិត និងប្រើប្រាស់ស្បៀងអាហារ ជាពិសេស ក្នុងគ្រាមានវិបត្តិ និងបញ្ហាប្រឈមដែលពួកគេកំពុងជួបប្រទះក្នុងការធានាការផ្គត់ផ្គង់ស្បៀងអាហារឱ្យបានគ្រប់គ្រាន់ និងប្រកបដោយអាហារូបត្ថម្ភ។ ការទទួលស្គាល់សក្តានុពលនៃសេដ្ឋកិច្ច-សង្គម និងយេនឌ័រដែលពាក់ព័ន្ធ គឺជាកត្តាចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពនៃអន្តរាគមន៍ សំដៅលើកកម្ពស់ការផលិត និងការប្រើប្រាស់ស្បៀងអាហារដែលរឹតតែផ្តល់សុខភាពល្អ។

ដោយបានយល់ដឹងអំពីបញ្ហាខាងលើនេះហើយ ទើបការសិក្សានេះ បានឈ្វេងយល់បន្ថែមលើទិដ្ឋភាពដែលមិនទាន់បានពិនិត្យពិច័យ ទាក់ទងនឹងលំអាននៃការផលិត និងការប្រើប្រាស់ស្បៀងអាហារ ក្នុងចំណោមក្រុមសេដ្ឋកិច្ច-សង្គមផ្សេងៗគ្នា។ គោលបំណងចម្បងនៃការសិក្សានេះ គឺដើម្បីឈ្វេងយល់ពីទម្លាប់នៃហូបចុក ការអនុវត្តលើការផលិតស្បៀងអាហារ និងឧបសគ្គចំពោះការផលិតស្បៀងអាហារមិនបានគ្រប់គ្រាន់ និងការទទួលបានអាហារូបត្ថម្ភ និងជាពិសេស តួនាទីរបស់រចនាសម្ព័ន្ធអភិបាលកិច្ចផ្លូវការ និងក្រៅផ្លូវការក្នុងការអនុវត្តគោលនយោបាយជាតិ ស្តីពីអាហារូបត្ថម្ភនៅកម្រិតមូលដ្ឋាន។ ទោះបីជាការស្រាវជ្រាវធ្លាប់ត្រូវបានធ្វើឡើងពីមុនរួចមកហើយ លើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងចំណោមក្រុមសេដ្ឋកិច្ច-សង្គមផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជាក៏ដោយ ប៉ុន្តែការសិក្សាស្រាវជ្រាវលើកនេះ គឺមានមានលក្ខណៈផ្តោតជាពិសេស។ វាជាការសិក្សាមួយលើកដំបូងបង្អស់ ដើម្បីឈ្វេងយល់ពីទំនាក់ទំនងរវាងស្ថាប័នផ្លូវការ និងក្រៅផ្លូវការ និងលទ្ធភាពរបស់គ្រួសារនីមួយៗ ក្នុងការរកបានអាហារសម្បូរជីវជាតិ និងព័ត៌មានអាហារូបត្ថម្ភ ទន្ទឹមនឹងការពិចារណាផងដែរអំពីឥទ្ធិពលនៃកម្រិតជីវភាព និងយេនឌ័រ។ ការសិក្សានេះ មានគោលបំណងឆ្លើយនឹងសំណួរស្រាវជ្រាវ ដូចខាងក្រោម៖

១. តើអ្វីខ្លះជាឧបសគ្គផ្លូវការ និងក្រៅផ្លូវការ ចំពោះការផលិត និងការប្រើប្រាស់ស្បៀងអាហារប្រកបដោយអាហារូបត្ថម្ភ?

២. តើឧបសគ្គទាំងនេះ ប្រឈមនឹងការប្រើប្រាស់ស្បៀងអាហារប្រកបដោយអាហារូបត្ថម្ភ ក្នុងចំណោមក្រុមសេដ្ឋកិច្ច-សង្គមផ្សេងៗគ្នាយ៉ាងដូចម្តេច?

តាមរយៈការវិភាគឧបសគ្គទាំងនេះ ការសិក្សានេះមានគោលបំណង ដើម្បីកំណត់ពីផលវិបាកជាក់លាក់ដែលរារាំងដល់លទ្ធភាពទទួលបាន និងលទ្ធភាពរកបាននូវជម្រើសចំណីអាហារដែលផ្តល់សុខភាពល្អ។ ជាងនេះទៅទៀត ការសិក្សានេះឈ្វេងយល់អំពី ទម្លាប់នៃរបបអាហារ និងការអនុវត្តលើការផលិតស្បៀងអាហារដែលកំពុងរាលដាលក្នុងចំណោមសហគមន៍ ដោយផ្តល់នូវការពិនិត្យអំពីរបៀបដែលបទដ្ឋានវប្បធម៌ វិធានកំណត់ដោយសង្គម លក្ខខណ្ឌសេដ្ឋកិច្ច និងកត្តាបរិស្ថាន បង្កើតទម្លាប់អនុវត្តទាំងនេះឡើង។ វិធីសាស្ត្រនេះ អនុញ្ញាតឱ្យយើងយល់អំពីបញ្ហាប្រឈម និងការប្រព្រឹត្ត ដែលមានឥទ្ធិពលលើលទ្ធផលអាហារូបត្ថម្ភ ដែលទីបំផុតបានរួមចំណែកដល់ ការបង្កើតយុទ្ធសាស្ត្រគោលដៅសំដៅបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា។

# ២. ការវិភាគលើវិវេចនាឯកសារ

## ២.១. ការយល់ដឹងអំពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

សន្តិសុខស្បៀង ត្រូវបានកំណត់និយមន័យនៅក្នុងរបាយការណ៍ស្តីពីអសន្តិសុខស្បៀង សំដៅសេចក្តីថា "គ្រប់ស្ថានភាព សង្គម សេដ្ឋកិច្ច មនុស្សគ្រប់រូបមានលទ្ធភាពទទួលបាននូវអាហារូបត្ថម្ភចម្រុះ គ្រប់គ្រាន់ និងមានសុវត្ថិភាពដែលឆ្លើយតបទៅនឹងតម្រូវការ និងសុខភាពរបស់ពួកគេ" (FAO 2001)។ និយមន័យនេះត្រូវបានកែសម្រួលបន្ថែមទៀតនៅក្នុងកិច្ចប្រជុំកំពូលពិភពលោក ស្តីពីសន្តិសុខស្បៀងក្នុងឆ្នាំ២០០៩ ដោយកំណត់ពីសសរស្តម្ភសំខាន់ៗចំនួនបួនដែលត្រូវតែបំពេញក្នុងពេលដំណាលគ្នា ដើម្បីធ្វើឱ្យសម្រេចបាននូវគោលដៅសន្តិសុខស្បៀង (ភាពអាចរកបាន ភាពអាចទទួលបាន ការប្រើប្រាស់ និងស្ថិរភាព) និងគូសបញ្ជាក់ពីសារៈសំខាន់នៃ «វិមាត្រអាហារូបត្ថម្ភ» នៅក្នុងគោលគំនិតនៃសន្តិសុខស្បៀង (FAO 2009)។

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងច្រើន និងមានកំណើនគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ដោយអត្រានៃភាពក្រីក្របានធ្លាក់ចុះពី ៤៧,៨% ក្នុងឆ្នាំ២០០៧ មកត្រឹម ១៧,៨% ក្នុងឆ្នាំ២០១៩-២០២០ (WFP 2023)។ ស្ថានភាពសន្តិសុខស្បៀងក្នុងប្រទេសបានឆ្លុះបញ្ចាំងឱ្យឃើញពីចំណុចដូចជា៖ តួលេខកង្វះអាហារូបត្ថម្ភបានធ្លាក់ចុះពី ៣៨% ក្នុងឆ្នាំ១៩៩២ មកត្រឹម ២៥% ក្នុងឆ្នាំ២០០៦ ការប្រើប្រាស់ក្នុងគ្រួសារបានកើនឡើងជិត ៤០% នៅចន្លោះឆ្នាំ២០០៤ និងឆ្នាំ២០១១ ហើយផលិតកម្មដំណាំ និងស្បៀងបានកើនឡើងបួនដងចន្លោះឆ្នាំ១៩៩០ និងឆ្នាំ២០១៣ (Ecker and Diao 2011; Theng 2014; World Bank 2014)។ កាលពីឆ្នាំ ២០១៧ វិស័យកសិកម្មបានផ្តល់ការងារដល់ប្រជាជនកម្ពុជាសរុបចំនួន ៣៧% ហើយកាលពីឆ្នាំ២០១៩ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសមានចំនួនជាង ១/៥ គឺបានមកពីផលិតកម្មស្រូវ ដោយបានរួមចំណែកប្រហែលពាក់កណ្តាលនៃទិន្នផល

សេដ្ឋកិច្ច (Alvar-Beltrán et al. 2022; Sok et al. 2021)។ កម្ពុជាសម្រេចបាននូវសន្តិសុខស្បៀងទាក់ទង នឹងភាពអាចរកបាន ការផលិតបរិមាណអង្ករលើសពីតម្រូវការក្នុងស្រុក ហើយបច្ចុប្បន្នកំពុងស្ថិតនៅលើផ្លូវឆ្ពោះទៅមុខ ដើម្បីក្លាយជាប្រទេសនាំចេញអង្ករដ៏ធំមួយ (MAFF 2015; Thath 2014)។ ទោះបីជាយ៉ាងនេះក្តី បញ្ហាលំបាកក្នុង ការទទួលបានអាហារ ភាពសម្បូរបែបនៃរបបអាហារមានកម្រិតទាប កង្វះអាហារូបត្ថម្ភ និងលើសអាហារូបត្ថម្ភនៅតែ បន្តរីករាលដាលនៅក្នុងប្រទេសកម្ពុជា ហើយជាពិសេស គឺនៅតាមតំបន់ជនបទដែលមានប្រជាជនក្រីក្ររស់នៅភាគ ច្រើន។ ប្រហែល ១៤,២% (ឬ ២,៣លាននាក់) នៃចំនួនប្រជាជនសរុប កំពុងប្រឈមអសន្តិសុខស្បៀងយ៉ាងធ្ងន់ធ្ងរ ក្នុង នោះស្ត្រីមានចំនួន ៤៤% កើតជំងឺស្លេកស្លាំង ខ្វះគ្រាប់ឈាម និង ៣២% នៃកុមារដែលមានអាយុក្រោម ៥ឆ្នាំ កើតជំងឺ ក្រេសក្រិន (FAO 2014; McDonald et al 2015; USAID 2021; WFP 2023)។

ការដោះស្រាយបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅតែជាអាទិភាពចម្បង សម្រាប់រាជរដ្ឋាភិបាលកម្ពុជា។ គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបច្ចេកទេសសម្រាប់កិច្ចគាំពារសង្គម សន្តិសុខស្បៀង និង អាហារូបត្ថម្ភ (TWG-SP&FSN) ដែលដឹកនាំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) ដែលជាយន្តការមួយ ក្នុងការសម្របសម្រួលឱ្យបានកាន់តែប្រសើរ និងធ្វើឱ្យសុខដុមនូវកិច្ចខិតខំប្រឹងប្រែងក្នុងចំណោម ក្រសួងពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយទ្វេភាគី និងពហុភាគី និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បី កំណត់ឱ្យឃើញ និងដោះស្រាយចំពោះបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN) ឆ្នាំ២០១៤-២០១៨ និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទីពីរ ឆ្នាំ២០១៩-២០២៣ ត្រូវបានបង្កើតឡើងដោយ CARD ដោយសហការជាមួយ TWG-SP&FSN (CARD 2014; CARD 2019)។ យុទ្ធសាស្ត្រជាតិ NSFSN លើកទីពីរនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងយ៉ាងទូលំទូលាយ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (CSGD) នៃប្រទេសកម្ពុជាត្រឹមឆ្នាំ២០៣០ ត្រង់ចំណុច «ធានាថាមិនទុកឱ្យនរណាម្នាក់ខ្វះអាហារ ឬរងគ្រោះដោយសារកង្វះអាហារូបត្ថម្ភ» ជាពិសេសគោលដៅទី២ ដែល មានគោលបំណង («បញ្ចប់គ្រោះអត់ឃ្លាន សម្រេចបាននូវសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និង លើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាពភាព»)។ ការផ្តួចផ្តើមមួយចំនួនផ្សេងទៀតត្រូវបានបង្កើតឡើងរួមជាមួយ គោលនយោបាយដូចជា ផែនទីបង្ហាញផ្លូវថ្នាក់ជាតិឆាប់រហ័ស សម្រាប់លើកកម្ពស់អាហារូបត្ថម្ភ (២០១៤-២០២០) និង ក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍ និងការគាំពារកុមារក្នុងវិស័យកសិកម្ម (២០១៦-២០២០)។

## ២.២. កត្តាសេដ្ឋកិច្ច-សង្គមដែលប៉ះពាល់ដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ទំនាក់ទំនងរវាងភាពក្រីក្រ និងសន្តិសុខស្បៀង ត្រូវបានបង្កើតឡើងយ៉ាងរឹងមាំនៅក្នុងវិរេចនាឯកសារ។ ភាព ក្រីក្រ និងសន្តិសុខស្បៀងមានទំនាក់ទំនងគ្នាទៅវិញទៅមក ដើម្បីបង្កើតបានជាវដ្តមួយវិលចុះឡើងៗ (ឬ «បន្ទុកទ្វេ») ដែលជាឧបសគ្គផ្នែកហិរញ្ញវត្ថុក្នុងការរារាំងមនុស្សមិនឱ្យទទួលបានចំណីអាហារដែលមានសុវត្ថិភាព គ្រប់គ្រាន់ និង មានជីវជាតិ។ បន្ថែមលើនេះ ការដាក់កម្រិតសមត្ថភាពរាងកាយ និងផ្លូវចិត្តរបស់ពួកគេក្នុងការអនុវត្តការងារប្រចាំថ្ងៃ ក៏ដូចជាសក្តានុពលសេដ្ឋកិច្ចរបស់ពួកគេ ជាហេតុបង្កើនភាពងាយរងគ្រោះដល់ពួកគេឱ្យធ្លាក់ក្នុងភាពក្រីក្រ (Ahmed, Ibrahim and Al-feel 2014; Siddiqui et al. 2020; Vorster 2010)។ ម៉្យាងវិញទៀត អ្នកដែលមានលទ្ធភាព ទទួលបានធនធានហិរញ្ញវត្ថុមានកម្រិត ជារឿយៗយល់ថា ខ្លួនឯងមិនអាចទទួលបានចំណីអាហារដែលមានសុវត្ថិភាព គ្រប់គ្រាន់ និងមានជីវជាតិទេ ដូច្នេះដើម្បីបានអាហារចម្រុះច្រើនមុខ និងគុណភាពនៃការទទួលទានចំណីអាហារ ពួកគេ ច្រើនតែប្រើប្រាស់ផលិតផលដែលមានសារធាតុចិញ្ចឹមតិច និងតម្លៃថោកជាង (Peña and Bacallao 2002)។ ភាព ក្រីក្រ និងស្ថានភាពសេដ្ឋកិច្ច-សង្គមនៅទាប ក៏ផ្សារភ្ជាប់ជាមួយនឹងការលំបាកក្នុងការទទួលបានការអប់រំប្រកបដោយ គុណភាព ការថែទាំសុខភាព និងហេដ្ឋារចនាសម្ព័ន្ធ ទន្ទឹមនឹងការមានកម្មសិទ្ធិដីធ្លី លទ្ធភាពទទួលបានឥណទាន និង ការទទួលបានការងារ គឺមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយនឹងកម្រិតប្រាក់ចំណូលរឹតតែខ្ពស់ ទើបសន្តិសុខស្បៀងក៏ រឹតតែប្រសើរជាងនេះផងដែរ (Khudri and Chowdhury 2013; Mupaso et al 2024; USAID 2011)។

ដូចដែលបានរៀបរាប់ពីមុន អត្រានៃភាពក្រីក្រនៅកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំង ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វិសមភាពប្រាក់ចំណូលក៏កំពុងកើនឡើងផងដែរ ដោយសារតែអត្រាកំណើនសេដ្ឋកិច្ចខុសៗគ្នា នៅតាមតំបន់ផ្សេងៗគ្នា

ជាពិសេសនៅតំបន់ជនបទមិនមានវឌ្ឍនភាពច្រើននោះទេ (Ecker and Diao 2011; Hansen and Gjonbalaj 2019)។ បើយោងតាមរបាយការណ៍ Chhoun et al. (2016) បានរកឃើញថា វិសមភាពក្នុងស្ថានភាពការងារ ជាពិសេស ទាក់ទងនឹងយេនឌ័រ បានបង្កើនវិសមភាពប្រាក់ចំណូល ជាហេតុធ្វើឱ្យជះឥទ្ធិពលប្រយោល ដល់ស្ថានភាពអាហារូបត្ថម្ភរបស់មនុស្សម្នាក់ៗ។ ការសិក្សារបស់ Chen (2022) ស្ដីពីការទទួលទានចំណីអាហារ ប្រាក់ចំណូលក្នុងគ្រួសារ និងអាហារូបត្ថម្ភរបស់កុមារនៅក្នុងស្រុកមួយនៃខេត្តកំពង់ស្ពឺ បានបញ្ជាក់ពីការពិតដែលថា ទោះបីជាមានចំណេះដឹងអំពី របៀបផ្លាស់ប្ដូរការផ្ដល់អាហារូបត្ថម្ភដល់កុមារក៏ដោយ ក៏សមត្ថភាពរបស់ពួកគេ ក្នុងការអនុវត្តនៅតែមានកម្រិត ដោយសារតែគ្រួសារប្រឈមនឹងការលំបាកផ្នែកហិរញ្ញវត្ថុ។ ជនក្រីក្រក៏ងាយរងគ្រោះ ដោយសារបញ្ហាសុខភាព ដែលកាន់តែធ្ងន់ធ្ងរឡើង ដោយសារការជាប់ពាក់ព័ន្ធក្នុងការងារដែលមានហានិភ័យខ្ពស់ កង្វះលទ្ធភាពទទួលបានទឹកស្អាត និងកង្វះសេវាថែទាំសុខភាព ជាហេតុបង្កើនហានិភ័យនៃកង្វះអាហារូបត្ថម្ភ (ADB 2011; Poirot et al. 2020)។

ទីផ្សារក្រៅផ្លូវការ គឺជាជម្រើសដ៏ពេញនិយមមួយសម្រាប់មនុស្សក្នុងការទិញចំណីអាហារ ដោយសារតែទំនិញផ្សេងៗ ជាធម្មតាមានតម្លៃទាបជាងទីផ្សារផ្លូវការដែលមានការគ្រប់គ្រង។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្ត និងការគ្រប់គ្រងទឹកស្អាត និងអនាម័យ (WASH) ទំនងជាមានភាពទន់ខ្សោយនៅតាមទីផ្សារក្រៅផ្លូវការ ដែលនាំឱ្យមានអត្រាខ្ពស់នៃការចម្លងរោគទៅលើចំណីអាហារដែលកើតចេញពីផលិតផលបន្លែបង្ការ និងសាច់ (Schwan et al. 2021; Wiwanitkit and Kaewla 2015)។ ការឆ្លងមេរោគបាក់តេរី និងមេរោគដែលបង្កឡើងដោយភ្នាក់ងារបង្កជំងឺទាំងនេះ ក៏ដូចជាការឆ្លងមេរោគប៉ារ៉ាស៊ីត ដូចជាបណ្ដាលឱ្យរាករូស ធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ បន្ថយសមត្ថភាពស្រូបយកសារធាតុចិញ្ចឹមសំខាន់ៗ និងបន្ថយបរិមាណអាហារូបត្ថម្ភ ដែលមានសក្ដានុពលខ្ពស់នៅក្នុងចំណីអាហារមួយចំនួន (Vilain et al. 2016; Wallace et al. 2014)។ ជាការពិតណាស់ បើយោងតាមរបាយការណ៍ Laillou et al. (2020) បានរកឃើញថា សូចនាករទឹកស្អាត និងអនាម័យ (WASH) ស្ថិតក្នុងកម្រិតទាប បូករួមទាំងពិន្ទុនៃការចិញ្ចឹមបីបាច់កូនក៏នៅទាបដែរ ដែលជាការព្យាករក្នុងចំនួនស្មើគ្នាពី ៣០% ទៅ ៤០% ចំពោះអត្រាប្រេវ៉ាឡង់នៃកុមារក្រេសក្រិន និងមិនគ្រប់ទម្ងន់នៅក្នុងប្រទេសកម្ពុជា។

ជាការពិត ទម្លាប់នៃរបបអាហារ ក៏ជាមូលហេតុនាំឱ្យប៉ះពាល់ដល់ការទទួលបានសារធាតុចិញ្ចឹមផងដែរ។ អត្រាកង្វះអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា ស្ថិតក្នុងចំណោមអត្រាខ្ពស់បំផុតនៃតំបន់អាស៊ាន ជាពិសេសគឺកុមារ និងស្ត្រីមានផ្ទៃពោះ (World Bank, 2019)។ បញ្ហានេះមាននៅទូទាំងប្រទេសកម្ពុជា គឺដោយសារតែកង្វះនិន្នាការនៃរបបអាហារ ច្រើនតែខ្វះភាពចម្រុះច្រើនមុខ និងខ្វះជីវជាតិ។ អង្ករ និងត្រី គឺជាអាហារចម្បងដ៏សំខាន់ជាងគេដែលមានផ្ទុកថាមពលចំនួន ៦០% និង ៣៧% នៃប្រូតេអ៊ីនសរុប។ កង្វះការទទួលទានបន្លែ និងផ្លែឈើឱ្យបានគ្រប់គ្រាន់ ត្រូវបានកត់សម្គាល់ថា ជាបញ្ហាមួយដោយសារភាពក្រីក្រ គឺមិនមែនដោយសារ មិនអាចរកបាននូវចំណីអាហារទាំងនេះទេ (Vilain 2016; Wallace et al. 2014)។ ការស្រាវជ្រាវប្រមូលព័ត៌មានបានបង្ហាញថា ប្រជាជនកម្ពុជាភាគច្រើនចាត់ទុកថាអង្ករ (ឬបាយ) មានជីវជាតិគ្រប់គ្រាន់ក្នុងការបង្ការជំងឺលើកុមារ និងជួយទ្រទ្រង់ដល់ការអភិវឌ្ឍរបស់ពួកគេ បើទោះបីជាវាមានបរិមាណមីក្រូសារជាតិទាបក៏ដោយ ដែលជាការបង្ហាញពីគម្លាតនៃចំណេះដឹងទាក់ទងនឹងអាហារូបត្ថម្ភ (UNICEF, Helen Keller International and National Nutrition Program 2016 cited in Som et al. 2018។ លើសពីនេះ អង្ករ (ឬបាយ) មានផ្ទុកសារធាតុដែលរារាំងការទទួលបានអាហារជាតិស័ង្កសី និងជាតិដែក ដែលធ្វើឱ្យថយចុះថែមទៀតនូវ បរិមាណមីក្រូសារជាតិនៃរបបអាហាររបស់ប្រជាជនកម្ពុជា។ Vilain et al. (2016) ចង្អុលបង្ហាញថា ទំនោរនៃការទទួលទានមុខម្ហូប គឺជាប់ទាក់ទងនឹងការចំណាយរបស់ពួកគេដោយសមាមាត្រដ៏សំខាន់នៃប្រាក់ចំណូលគ្រួសារ នឹងឆ្ពោះទៅរកការធានាថាមានអង្ករហូបគ្រប់គ្រាន់។

ការសិក្សារបស់ Reinbott et al. (2016) បានរកឃើញថា កម្មវិធីអប់រំអាហារូបត្ថម្ភដែលផ្សព្វផ្សាយដល់ប្រជាជនកម្ពុជានៅជនបទដោយរាជរដ្ឋាភិបាលកម្ពុជា និងដោយអ្នកស្ម័គ្រចិត្តសុខភាពភូមិ បានជំរុញឱ្យមានការកែលម្អគុណភាពរបបអាហារ និងភាពសម្បូរបែបនៅក្នុងរបបអាហារសម្រាប់កូនៗរបស់ពួកគេ។ ឯកសារស្រាវជ្រាវបានលើកឡើងថា កង្វះនៃវិធីសាស្ត្រអន្តរវិស័យ និងវិធីសាស្ត្រដែលពឹងផ្អែកលើសហគមន៍ចំពោះកម្មវិធីអាហារូបត្ថម្ភ គឺជាកត្តារួមចំណែកមួយ។ ការស្ទង់មតិដែលធ្វើឡើង ក្នុងចំណោមស្ត្រីដែលមានអាយុមានសមត្ថភាពបន្តពូជ នៅក្នុងខេត្ត

កំពត និងកំពង់ធំ បានរកឃើញថា ការប្រឹក្សាផ្នែកអាហារូបត្ថម្ភ និងអនាម័យ នៅមានកម្រិតតិចតួចខ្លាំងណាស់ ដោយស្ទើរតែពាក់កណ្ដាលនៃចំនួនភូមិដែលបានស្ទង់មតិ មានរចនាសម្ព័ន្ធប្រឹក្សាអាហារូបត្ថម្ភមិនគ្រប់គ្រាន់ទេ (Ok and Weingärtner 2016)។ ជាងនេះទៅទៀត ជិតពាក់កណ្ដាលនៃចំនួនអ្នកឆ្លើយសំណួរនៅទូទាំងខេត្តទាំងពីរបានឱ្យដឹងថា ពួកគេនឹងសួរម្ដាយរបស់ខ្លួនចំពោះការផ្ដល់ចំណីអាហារ និងដំបូន្មានទាក់ទងនឹងអាហារូបត្ថម្ភ ហើយក្នុងនោះមានជាងមួយភាគបីដែលបានប្រឹក្សាជាមួយមិត្តភក្តិ ឬអ្នកជិតខាង។ ការសិក្សារបស់ Wallace et al. (2014) ក៏បង្ហាញឱ្យឃើញពីតម្រូវការចាំបាច់សម្រាប់យុទ្ធនាការអប់រំអាហារូបត្ថម្ភ ឱ្យបានទូលំទូលាយបន្ថែមទៀត ដោយចង្អុលបង្ហាញថា ការបង្កើតកម្មវិធីអាហារូបត្ថម្ភនៅប្រទេសកម្ពុជា មិនត្រូវបានរួមបញ្ចូលល្អប្រសើរជាមួយវិស័យកសិកម្ម និងសុខភាពសាធារណៈទេ ហើយខ្វះគំនិតផ្ដួចផ្ដើមផ្ដោតលើសហគមន៍ ជាហេតុធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជនកាន់តែដុនដាបធ្ងន់ធ្ងរឡើង។

ក្នុងន័យដូចគ្នានេះ អត្រាប្រេវ៉ាឡង់នៃជំនឿប្រពៃណី និងទម្លាប់អនុវត្តមួយចំនួន ក៏ត្រូវបានកំណត់ថា ជាកត្តាប៉ះពាល់ដល់ការទទួលបានអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជាផងដែរ។ ការសិក្សាដែលធ្វើឡើងនៅប្រទេសឡាវ បានរកឃើញថា ស្ត្រីមានផ្ទៃពោះ និងក្រោយសម្រាល គឺខ្វះសារធាតុចិញ្ចឹមមិនសមាមាត្រធៀបនឹងប្រជាជនទូទៅ ដោយសារជំនឿប្រពៃណីក្នុងតំបន់ ជុំវិញទម្លាប់នៃការបរិភោគចំណីអាហារអំឡុងពេលមានផ្ទៃពោះ និងបំបៅដោះកូន ដែលរួមមាន ការជៀសវាង ឬដាក់កម្រិតលើការបរិភោគអាហារមួយចំនួនដូចជា ផ្លែឈើ បន្លែឆៅ អាហារហឹរ និងសាច់ជ្រូកជាដើម (Barennes et al. 2009; Ratsavong et al. 2020)។ ដូចគ្នានេះដែរ នៅក្នុងប្រទេសកម្ពុជា វាជារឿងធម្មតាទេដែលស្ត្រីមានគភ៌ ត្រូវជៀសវាងបរិភោគចំណីអាហារមួយចំនួនដូចជា ផ្អកត្រី និងអាហារ «ហិរ» ដែលត្រូវបានគេជឿថា ប៉ះពាល់ដល់សុខភាពរយៈពេលវែងទាំងម្ដាយ និងកូន ដែលជារឿយៗធ្វើឱ្យបាត់បង់សារធាតុចិញ្ចឹមសំខាន់ៗ នៅក្នុងដំណាក់កាលលូតលាស់ និងការវិវត្តរបស់ទារកក្នុងផ្ទៃម្ដាយ (Galvin et al. 2008; Vilain et al. 2016)។ ការដាក់កម្រិតលើការបរិភោគចំណីអាហារដូច្នេះ គឺដើម្បីធានាបាននូវការសម្រាលកូនដែលងាយស្រួលដោយមានគភ៌តូចងាយសម្រាល ឬដើម្បីសន្សំប្រាក់ សម្រាប់ការចំណាយលើការសម្រាលកូន គឺជាកត្តារួមចំណែកមួយផ្សេងទៀត ចំពោះកង្វះអាហារូបត្ថម្ភរបស់ស្ត្រីជាមាតា (Som et al. 2018)។ ក្បួនប្រពៃណីមួយចំនួនដែលប្រជាជនកម្ពុជាប្រើប្រាស់ក្នុងការកែច្នៃម្ហូបអាហារ ដូចជា ការដាក់ហាលថ្ងៃ ការផ្អាប់ទុកយូរ និងការដុតចម្អិនឱ្យក្រៀមក្នុងផុងកម្ដៅ ក៏ជាការកាត់បន្ថយបរិមាណមីក្រូសារជាតិនៃចំណីអាហារដែលមានសារធាតុចិញ្ចឹម ឱ្យរឹតតែនៅតិចតួចផងដែរ (Vilain et al. 2016)។

## ២.៣. សន្តិសុខស្បៀង អាហារូបត្ថម្ភ និងសមភាពយេនឌ័រ

ទោះបីជាស្ត្រី (ជាពិសេស ស្ត្រីនៅតាមជនបទ) ដើរតួនាទីសំខាន់ក្នុងដំណើរការផលិត ការរៀបចំ និងការចែកចាយស្បៀងអាហារក៏ដោយ ក៏ពួកគេនៅតែជួបប្រទះបញ្ហាអសន្តិសុខស្បៀង ជាពិសេស នៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម (FAO 2022) ដែលត្រូវបានគេប៉ាន់ប្រមាណថា ស្ត្រីមានចំនួនជាង ៤០% នៃកម្លាំងពលកម្មកសិកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍ (FAO 2012)។ ការរើសអើងទាក់ទងនឹងយេនឌ័របានចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងបទដ្ឋាន និងរចនាសម្ព័ន្ធសង្គម-វប្បធម៌ ពោលគឺមានន័យថា ស្ត្រីតែងតែជាអ្នកទទួលរ៉ាប់រងលើការផលិតស្បៀងអាហារ និងការធានាសន្តិសុខស្បៀងក្នុងគ្រួសារ ប៉ុន្តែវិសាលភាពនៃការរួមចំណែករបស់ពួកគេ បែរជាត្រូវបានគេមើលរំលងទៅវិញ (Maffii 2015)។

ដូចដែលបានរៀបរាប់ពីខាងដើម អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភជារឿយៗ កើតចេញពីភាពក្រីក្រដែលត្រូវបានគេរកឃើញផងដែរថា ជាដើមហេតុនាំឱ្យកើតមានវិសមភាពយេនឌ័រ (Visser and Wangu 2021; Clement et al. 2019)។ ជាពិសេស ស្ត្រីនៅតាមជនបទមានអារម្មណ៍ថា ផលប៉ះពាល់កើតឡើងដោយសារក្រីក្រខ្លាំងពេក ឬដោយសារតែពួកគេទំនងជាមានការងារធ្វើតិចតួចពេក ឬធ្វើតែការងារដែលមិនទទួលបានប្រាក់ខែ ជាពិសេសការងារក្នុងស្រុកភូមិ និងការងារផ្នែកថែទាំ ស្របពេលដែលពួកគេត្រូវបែងចែកសមាមាត្រដ៏ធំនៃប្រាក់ចំណូលរបស់ខ្លួន ចំពោះការផ្គត់ផ្គង់ស្បៀងអាហារក្នុងគ្រួសារ ច្រើនជាងបុរសជាសមាជិកក្នុងគ្រួសារ (Kotzé 2003; Sinclair et al. 2019។ លើសពីនេះ ដោយសារមានការអប់រំទាបក្នុងចំណោមស្ត្រី បានរួមចំណែកយ៉ាងធំដល់

ភាពខុសគ្នារវាងយេនឌ័រទាក់ទងនឹងប្រាក់ចំណូល និងអសន្តិសុខស្បៀង ហើយបង្កើនហានិភ័យនៃការទទួលបានអាហារូបត្ថម្ភមិនគ្រប់គ្រាន់ (Broussard 2019; Ekbrand and Halleröd 2018; Miller and Rodgers 2009)។ នេះហើយគឺជាចំណុចដែលការសិក្សារបស់ Suri និង Ashok (2022) បានចាត់ទុកថាជា: 'អក្ខរកម្មអាហារូបត្ថម្ភ' ដែលពួកគេបានបកស្រាយថា មានសារៈសំខាន់ក្នុងការធានាសន្តិសុខស្បៀងឱ្យបានកាន់តែប្រសើរនៅក្នុងគ្រួសារនីមួយៗ។ លទ្ធភាពតិចតួចក្នុងការទទួលបានដីធ្លី ធនធាន ដើមទុន និងឥណទាន ធ្វើឱ្យភាពងាយរងគ្រោះរបស់ពួកគេកាន់តែធ្ងន់ធ្ងរឡើង (Quisumbing et al. 1996)។ ភាពមិនស្មើគ្នានៃទំនាក់ទំនង និងអំណាចគ្រប់គ្រងក្នុងគ្រួសារ (រួមទាំងការបែងចែកការងារ និងការសម្រេចចិត្ត) ក៏ត្រូវបានលើកឡើងថា ជាកត្តារួមចំណែកដល់អត្រាខ្ពស់នៃកង្វះអាហារូបត្ថម្ភចំពោះស្ត្រី ដែលជារឿយៗដាក់កម្រិតស្វ័យភាពហិរញ្ញវត្ថុដែលពួកគេត្រូវការជាចាំបាច់ (Botreau and Cohen 2020)។

មានស្ថាប័នស្រាវជ្រាវជាច្រើន ដែលបានចងក្រងឯកសារអំពី អត្ថប្រយោជន៍នៃការបញ្ជ្រាបទស្សនៈយេនឌ័រនៅក្នុងដំណើរការផលិតកម្មស្បៀង និងសន្តិសុខអាហារូបត្ថម្ភទូទាំងពិភពលោក (Ayamga, Ayawine and Ayentimi 2023; Ghosh et al. 2021; Lufuke et al. 2022; Nnaji, Ratna and Renwick 2022; Suri and Ashok 2022)។ ទោះបីជាមានការយកចិត្តទុកដាក់កាន់តែច្រើនឡើងគួរឱ្យកត់សម្គាល់ ចំពោះទិដ្ឋភាពយេនឌ័រនៅក្នុងការជជែកពិភាក្សាអំពី គោលនយោបាយសន្តិសុខស្បៀងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ ក៏ការបកស្រាយអំពីបញ្ហាសមភាពយេនឌ័រ ឬសន្តិសុខស្បៀងមិនទាន់បានលទ្ធផលផ្លែផ្កាច្រើននោះទេ (Clement et al. 2019)។ ហេតុដូច្នេះហើយ ទើបទាមទារឱ្យមានការលាតត្រដាងពីតម្រូវការចាំបាច់ សម្រាប់ការទទួលស្គាល់ឱ្យបានកាន់តែច្រើនអំពីតួនាទីស្នូលរបស់ស្ត្រីនៅក្នុងប្រព័ន្ធស្បៀងអាហារនៅក្នុងប្រទេសកំពុងអភិវឌ្ឍ និងរបៀបនៃការតស៊ូមតិ ដើម្បីផ្តល់សិទ្ធិអំណាចដល់ស្ត្រី សម្រាប់ជាយុទ្ធសាស្ត្រគន្លឹះក្នុងការជំរុញដំណោះស្រាយសន្តិសុខស្បៀង (Visser and Wangu 2021)។

បទដ្ឋានយេនឌ័រសង្គម-វប្បធម៌ ដែលកើតចេញពីសង្គមដែលឱ្យតម្លៃមនុស្សតាមឋានានុក្រម និងចាត់ទុកបុរសជាធំ ដូចករណីនៅប្រទេសកម្ពុជា ជាធម្មតាបានកំណត់ឱ្យស្ត្រីនូវតួនាទីជាអ្នកមើលថែទាំ ដោយការទទួលខុសត្រូវរបស់ពួកគេ ផ្តោតជាចម្បងលើការងារក្នុងស្រុកភូមិ ការគ្រប់គ្រងគ្រួសារ និងសកម្មភាពកសិកម្ម ចំណែកបុរសវិញត្រូវចេញទៅធ្វើការនៅក្រៅផ្ទះ (Chhoun et al. 2016; Phuong 2018)។ ប្រហែល ២/៣ នៃស្ត្រីខ្មែរធ្វើការក្នុងវិស័យកសិកម្ម (ADB 2019) ស្របតាមលទ្ធផលរកឃើញពីការសិក្សាជាសាកលស្តីពីយេនឌ័រ និងសន្តិសុខស្បៀង ដូចដែលបានសិក្សាពីមុនមក ស្ត្រីចូលរួមយ៉ាងច្រើនក្នុងផលិតកម្មស្បៀង ការទិញ ការស្តុកទុក និងដំណើរការរៀបចំទុកដាក់ ដូច្នេះហើយពួកគេបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ស្ថានភាពសុខភាព និងសន្តិសុខអាហារូបត្ថម្ភនៅក្នុងគ្រួសាររបស់ពួកគេ (GIZ 2023; Phuong 2018)។ តាមការសិក្សា គេបានរកឃើញថា ក្នុងឆ្នាំ២០១០ ស្ត្រីខ្មែរចំនួន ១៨% ជួបបញ្ហាកង្វះអាហារូបត្ថម្ភ (Windus et al. 2022) ខណៈដែល Wallace et al. (2014) បានរកឃើញលទ្ធផលទាក់ទងនឹងការទទួលបានសារធាតុចិញ្ចឹមរបស់ស្ត្រីនៅក្នុងខេត្តកណ្តាលដូច្នេះថា ៩៧% នៃស្ត្រីទាំងនោះមិនបានទទួលទានជាតិដែកគ្រប់គ្រាប់ជាប្រចាំថ្ងៃតាមការណែនាំនោះទេ។ ចំណែកលទ្ធផលនៃការសិក្សារបស់ McDonald et al. (2015) បានបង្ហាញថា ដោយសារតែកង្វះចំណេះដឹង និងការទទួលបានព័ត៌មានអាហារូបត្ថម្ភ ទើបបណ្តាលឱ្យស្ត្រីត្រូវជួបបញ្ហាកង្វះអាហារូបត្ថម្ភដែលកើតចេញពីអំណាចគ្រប់គ្រងយេនឌ័រក្នុងគ្រួសារ ដោយសារស្ត្រីទាំងនោះ ត្រូវផ្តល់អាទិភាពលើតម្រូវការចាំបាច់នៃការប្រើប្រាស់ និងអាហារូបត្ថម្ភរបស់សមាជិកផ្សេងទៀតក្នុងគ្រួសារជាជាងតម្រូវការរបស់ខ្លួនឯង។

រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ពីតម្រូវការចាំបាច់ ចំពោះកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងជាងនេះ ដើម្បីបង្កើនបរិយាបន្ន និងកាត់បន្ថយវិសមភាព ហើយបានកំណត់ថាស្ត្រីជាក្រុមងាយរងគ្រោះដែលត្រូវដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (FSN) (Smith 2023)។ ចំណុចនេះក៏បង្ហាញឱ្យឃើញផងដែរនៅក្នុងយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ (ឆ្នាំ២០១៩-២០២៣) ដែលយកចិត្តទុកដាក់ជាពិសេស ចំពោះតួនាទីរបស់ស្ត្រីខ្មែរនៅក្នុងគ្រួសារជនបទ និងសារៈសំខាន់នៃការពង្រឹងសុខភាពមាតា និងទារក និងអាហារូបត្ថម្ភ (CARD 2019)។ ដើម្បីបំពេញបន្ថែមលើចំណុចនេះ យុទ្ធសាស្ត្រនេះបានរំលេចឱ្យឃើញពីតម្រូវការដឹកនាំកម្មវិធីអប់រំអាហារូបត្ថម្ភទៅដល់ក្រុមបុរស ដោយធ្វើដូច្នេះទើបអាចជំរុញឱ្យសមភាពយេនឌ័រ កាន់តែប្រសើរជាងមុន

តាមរយៈការធ្វើឱ្យមានតុល្យភាពលើការបែងចែកទំនួលខុសត្រូវរៀងៗខ្លួន និងការកែលម្អស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅតាមគ្រួសារនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សារបស់ Windus et al. (2022) បានកត់សម្គាល់ថា យុទ្ធសាស្ត្រខាងលើ មិនអាចដោះស្រាយបានជោគជ័យ ជាពិសេសចំពោះភាពគ្រប់គ្រាន់នៃការទទួលបានអាហារូបត្ថម្ភនោះឡើយ។ ស្ត្រី ឬស្ត្រីមេគ្រួសារ ហើយដែលមានសមាជិកគ្រួសារជាជនពិការ ត្រូវបានទទួលស្គាល់ថា ជាក្រុមងាយរងគ្រោះដែលត្រូវដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (FSN) (Smith 2023)។ គ្រួសារក្រីក្របំផុត ដែលច្រើនតែមានមនុស្សស្រីជាមេផ្ទះ ឬរាប់បញ្ចូលទាំងសមាជិកគ្រួសារដែលមានពិការភាព ក៏ដូចជាអ្នកដែលគ្មានដីធ្លី ជនជាតិដើមភាគតិច ឬមកពីតំបន់ដាច់ស្រយាល ឬតំបន់ក្រីក្រ ក៏ងាយរងគ្រោះនឹងកង្វះអាហារូបត្ថម្ភផងដែរ។ ទន្ទឹមនឹងនេះ របាយការណ៍របស់ ADB (2021) បានសង្កត់ធ្ងន់ថា ឱនភាពស្បៀងអាហារតាមមូលដ្ឋានផ្សេងៗ ឬតាមរដូវកាលនីមួយៗនៅតែកើតមានឡើង ហើយនៅពេលដែលឱនភាពទាំងនេះកើតឡើង នោះគ្រួសារក្រីក្រជាងគេគឺជាអ្នករងទុក្ខធំបំផុត ដូច្នេះរបាយការណ៍នេះបានចង្អុលបង្ហាញពីតម្រូវការចាំបាច់ ដើម្បីធ្វើពិពិធកម្មប្រភពអាហារូបត្ថម្ភថ្នាក់ជាតិ និងលើកកម្ពស់គុណភាពស្បៀងអាហារទាំងមូលសម្រាប់ជនក្រីក្រ។

## ២.៤. សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធាន

កន្លងមកមានស្ថាប័នជាច្រើន បានធ្វើការស្រាវជ្រាវអំពីផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័សលើការផលិត និងការប្រើប្រាស់ស្បៀងអាហារ។ ការប្រែប្រួលអាកាសធាតុ និងភាពប្រែប្រួលផ្សេងៗ មានផលប៉ះពាល់យ៉ាងខ្លាំងចំពោះផលិតកម្មកសិកម្ម បសុសត្វ និងជលផលជាសកល ដែលជះឥទ្ធិពលទាំងបរិមាណ និងគុណភាពស្បៀងអាហារ ហើយក៏បន្តជះឥទ្ធិពលដល់តម្លៃ និងសុវត្ថិភាពចំណីអាហារ (Ajilogba and Walker 2021; Mirzabaev et al. 2023; Visser and Wangu 2021; Wheeler and von Braun 2013)។ នៅក្នុងប្រទេសអភិវឌ្ឍន៍ ប្រជាជនពឹងអាស្រ័យជាខ្លាំងលើវិស័យកសិកម្មជាប្រភពស្បៀងអាហារ និងប្រាក់ចំណូល ដោយការគំរាមកំហែងពីបញ្ហាបម្រែបម្រួលអាកាសធាតុ ភាពក្រីក្រ និងអសន្តិសុខស្បៀងអាហារនឹងកើតមានឡើង ក្នុងនោះការសិក្សារបស់ Mugambiwa និង Tirivangasi (2022) បានសន្និដ្ឋានថា ការប្រែប្រួលអាកាសធាតុ គឺជាឧបសគ្គដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅ២ «បញ្ចប់គ្រោះអត់ឃ្លាន» ព្រោះវាប៉ះពាល់ដល់ទំហំដែលបានរៀបរាប់ខាងលើទាំងអស់ ទាក់ទងនឹងស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជនទាំងមូល (El Bilali et al. 2020)។

ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍ ដែលពឹងផ្អែកខ្លាំងលើវិស័យកសិកម្ម កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុត ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលជាច្រើនទៀតនៅពេលនិយាយអំពីសន្តិសុខស្បៀង។ បញ្ហានេះកើតឡើងដោយសារភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់ធម្មជាតិដែលទាក់ទងនឹងអាកាសធាតុ រួមទាំងគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ និងព្យុះត្រូពិច រួមជាមួយនឹងសមត្ថភាពបន្សាំទន់ខ្សោយរបស់ប្រជាជន និងកង្វះយន្តការដែលផ្តល់ឱ្យកសិករនូវជម្រើសក្នុងការបន្សាំតួយ៉ាងដូចជា «អាកាសធាតុឆ្លាតវៃ» ដែលមានសារៈសំខាន់សម្រាប់ផលិតកម្មស្បៀង និងផលិតភាពកសិកម្ម ក៏ដូចជាសម្រាប់សុខភាព និងសន្តិសុខអាហារូបត្ថម្ភរបស់ប្រជាជនទាំងមូល (Nong 2021; Touch et al. 2016; World Bank 2017)។ ការប្រែប្រួលនៃទឹកភ្លៀង ការកើនឡើងនូវសីតុណ្ហភាព និងការកើនឡើងនូវភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃព្រឹត្តិការណ៍អាកាសធាតុធំៗ បានជះឥទ្ធិពលយ៉ាងខ្លាំង ដល់ផលិតកម្មដំណាំក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ រួមទាំងស្រូវ ជីវភាពស្នូលរបស់ប្រជាជននៅតាមជនបទដែលមានចំនួនជាង ៦០% នៃការប្រើប្រាស់ថាមពលចំណីអាហារសរុបប្រចាំថ្ងៃ (Chhinh and Poch 2012; In et al. 2015; Sok et al. 2021)។

នៅក្នុងការសិក្សារបស់ Alvar-Beltrán et al. (2022) បានរកឃើញថាការបាត់បង់ទិន្នផលយ៉ាងច្រើនសន្ធឹក ត្រូវបានព្យាករណ៍ចំពោះដំណាំបន្លែមួយចំនួន ដែលដាំដុះជាទូទៅក្នុងប្រទេសកម្ពុជា គឺកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ និងសម្ពាធកើនឡើងលើបញ្ហាធនធានទឹក។ បញ្ហានេះនឹងបង្កហានិភ័យយ៉ាងខ្លាំងដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់ប្រជាជនកម្ពុជា ដោយហេតុថា បន្លែដើរតួនាទីយ៉ាងសំខាន់ ក្នុងការរក្សារបបអាហារដែលផ្តល់សុខភាពល្អ ហើយដូចបានរៀបរាប់ក្នុងការសិក្សានេះផងដែរ បានបញ្ជាក់ថា ការកើនឡើងនៃ

សីតុណ្ហភាពខ្យល់ អាចជះឥទ្ធិពលអវិជ្ជមានដល់គុណភាពសារធាតុចិញ្ចឹមរបស់ដំណាំមួយចំនួន ដូចជាស្ពៃក្តោបជាដើម (Hwang et al. 2018 cited in Alvar-Beltrán et al. 2022)។ ការសិក្សារបស់ Chen (2022) ពន្យល់ថា ការប្រែប្រួលអាកាសធាតុបង្កជាបញ្ហាអសន្តិសុខស្បៀង និងជាពិសេសការទទួលបានសារធាតុចិញ្ចឹមមិនល្អសម្រាប់គ្រួសារដែលរស់នៅតំបន់ជនបទ ព្រោះតែមនុស្សត្រូវបានប្តូរផ្លាស់ពីការអនុវត្តកសិកម្មបែបប្រពៃណី («កេរ្តិ៍ដំណែល») ទៅជាសកម្មភាពចិញ្ចឹមជីវិតបែបថ្មី ដូចជាការជួញដូរសត្វពាហនៈ ដែលអាចបង្កើនភាពងាយរងគ្រោះ ដោយសារកង្វះចំណេះដឹងនៅក្នុងកិច្ចការជួញដូរនេះ។

ការសិក្សារបស់ Messina et al. (2017) សង្កត់ធ្ងន់លើយេនឌ័រជាកត្តាសំខាន់ ដែលជះឥទ្ធិពលលើបុរស និងស្ត្រីខ្មែរ កំពុងជួបប្រទះនឹងការប្រែប្រួលអាកាសធាតុ និងកំណត់សមត្ថភាពរបស់ពួកគេ ក្នុងការសម្របខ្លួន និងឆ្លើយតបទៅនឹងការប្រែប្រួលនេះ ដោយសារតែវិសមភាពយេនឌ័របានបង្កប់ទស្សនៈថា ជាវិសមភាពនៅក្នុងតួនាទី និងការទទួលខុសត្រូវ ព្រមទាំងសិទ្ធិទទួលបាន និងការគ្រប់គ្រងលើធនធាននានា។ Nong (2021) ក៏គូសបញ្ជាក់ផងដែរនូវការពិតដែលថា ការប្រែប្រួលអាកាសធាតុអាចប៉ះពាល់ដោយវិសមាមាត្រចំពោះក្រុមងាយរងគ្រោះ រួមទាំងស្ត្រី ដែលទំនងជាត្រូវរស់នៅក្នុងភាពក្រីក្រ ដូច្នេះហើយទើបគេយល់ថា ការប្រែប្រួលអាកាសធាតុ អាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរចំពោះស្ត្រីច្រើនជាងបុរស។

ការសិក្សាបានគូសបញ្ជាក់ពី អត្ថប្រយោជន៍នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី និងការសាងសង់ទំនប់ក្នុងការលើកកម្ពស់ និងធានានិរន្តរភាពកំណើនសេដ្ឋកិច្ចក្នុងប្រទេសកំពុងអភិវឌ្ឍ (Kondolf and Yi 2022; Shi et al. 2019)។ ទោះជាយ៉ាងណាក៏ដោយ ហេតុប៉ះពាល់សង្គម និងបរិស្ថាននៃគម្រោងទាំងនេះ រួមទាំងផលប៉ះពាល់របស់វា ទៅលើសន្តិសុខស្បៀងរបស់ប្រជាជនដែលកំពុងរស់នៅជាប់តំបន់ទាំងនោះ ក៏ត្រូវបានកត់ត្រាទុកជាឯកសារយ៉ាងទូលំទូលាយផងដែរ។ តួយ៉ាងដូចជាការសិក្សារបស់ Jima et al. (2022) អំពីផលប៉ះពាល់នៃអាងស្តុកទឹកទំនប់វារីអគ្គិសនីចំនួនពីរនៅភាគពាយ័ព្យនៃប្រទេសអេត្យូពី បានរកឃើញថា ការសាងសង់ទំនប់វារីអគ្គិសនីបានបង្កើនអសន្តិសុខស្បៀងរបស់គ្រួសារដែលរស់នៅជាប់តំបន់ទាំងនោះចំនួន ១៤,៦% និងកាត់បន្ថយភាពសម្បូរបែបនៃរបបអាហារចំនួន ២៤%។ ចំណែកការសិក្សារបស់ Cavallini Johansen et al. (2024) អំពីបញ្ហាប្រឈមរបស់សហគមន៍មួយនៅក្នុងតំបន់អាម៉ាហ្សូននៃប្រទេសប្រេស៊ីល បន្ទាប់ពីការសាងសង់ទំនប់វារីអគ្គិសនីនៅក្បែរនោះ ក៏បានផ្តល់លទ្ធផលនៃផលប៉ះពាល់ស្រដៀងគ្នានេះដែរ។ ការសិក្សារបស់ Cavallini Johansen et al. (2024) ក៏បានកំណត់ពីកត្តា និងលក្ខណៈសេដ្ឋកិច្ច-សង្គមមួយចំនួនផងដែរ រួមទាំងក្នុងគ្រួសារដែលមានយុវជន ឬស្ត្រីមេគ្រួសារបង្ហាញថា កម្រិតអប់រំទាប និងភាពអត់ការងារធ្វើបានផ្សារភ្ជាប់ទៅនឹងកម្រិតខ្ពស់នៃអសន្តិសុខស្បៀង។

ការអភិវឌ្ឍវារីអគ្គិសនីនៅតំបន់អាងទន្លេមេគង្គ គឺជាការគំរាមកំហែងយ៉ាងពិតប្រាកដ ចំពោះសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាជន នៅតាមដងទន្លេ រួមទាំងនៅប្រទេសកម្ពុជាផងដែរ។ ម្យ៉ាងវិញទៀត ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធខាងលើ បានគំរាមកំហែងដល់ជីវចម្រុះក្នុងទឹក និងភាពសម្បូរបែបនៃប្រភេទត្រីតាមដងទន្លេ ដោយការផ្លាស់ប្តូរសីតុណ្ហភាពទឹក គុណភាព ការផ្គត់ផ្គង់សារធាតុចិញ្ចឹម និងដីល្បាប់ បង្កការរំខានដល់ផ្លូវចរាចរសំខាន់ៗរបស់ត្រី ក៏ដូចជាបង្កឱ្យមានគ្រោះថ្នាក់ដល់រាងកាយរបស់ត្រី ដោយសារការធ្វើចលនានៃម៉ាស៊ីនទួរប៊ីន និងការផ្លាស់ប្តូរសម្ពាធបារ៉ាម៉ែត្រ (Alghera et al. 2020; Baird and Hogan 2023; Bonnema et al. 2020; Ziv et al. 2012)។ ការថយចុះនៃផលិតកម្មជលផល គំរាមកំហែងដល់ជីវភាពរស់នៅ និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជននៅតាមដងទន្លេនៅកម្ពុជា និងអាងទន្លេមេគង្គក្រោមទាំងមូល (Golden et al. 2019; Pearse-Smith 2012; Sor et al. 2023; Soukhaphon, Baird and Hogan 2021)។ Golden et al. (2019) ប៉ាន់ប្រមាណថា នៅឆ្នាំ២០៣០ ធៀបនឹងឆ្នាំ២០១០ មនុស្សរាប់លាននាក់នឹងប្រឈមមុខនឹងហានិភ័យនៃកង្វះប្រូតេអ៊ីន និងមីក្រូសារជាតិ ដែលជាលទ្ធផលនៃការថយចុះនៃធនធានត្រី ដោយសាររោងចក្រវារីអគ្គិសនី។

ការថយចុះជាផលវិបាកនៃផលិតកម្មជលផល បានគំរាមកំហែងដល់ជីវភាពរស់នៅ និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជន នៅតាមដងទន្លេនានាក្នុងប្រទេសកម្ពុជា និងអាងទន្លេមេគង្គក្រោមទាំងមូល (Golden et al. 2019; Pearse-Smith 2012; Sor et al. 2023; Soukhaphon, Baird and Hogan 2021)។ ចំណែកការសិក្សារបស់ Golden et al. (2019) បានប៉ាន់ប្រមាណថា នៅត្រឹមឆ្នាំ២០៣០ខាងមុខ ធៀបនឹងកាលពី

ឆ្នាំ២០១០ មនុស្សរាប់លាននាក់នឹងប្រឈមហានិភ័យនៃកង្វះប្រូតេអ៊ីន និងមីក្រូសារជាតិ ដែលជាលទ្ធផលនៃការថយចុះនូវធនធានត្រី ដោយសារតែសំណង់វារីអគ្គិសនី។

អ្វីដែលសំខាន់នោះ គឺគេចាំបាច់ត្រូវតែពិចារណាលើការអភិវឌ្ឍទាំងនេះ ក្នុងបរិបទទូលំទូលាយទាក់ទងនឹងការប្រែប្រួលអាកាសធាតុ (Hoang et al. 2016)។ មិនទាន់មានវិវេចនាឯកសារគ្រប់គ្រាន់ដែលបានពិនិត្យមើលលើផលប៉ះពាល់ជាបន្តបន្ទាប់នៃការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកទៅលើប្រព័ន្ធ និងលក្ខខណ្ឌធារាសាស្ត្រ និងកេរ្តិ៍ត្របរិស្ថាននៅទន្លេមេគង្គនៅឡើយទេ (Pokhrel 2018)។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវដែលមានស្រាប់បានបង្ហាញថា ប្រតិបត្តិការទំនប់វារីអគ្គិសនី និងអាងស្តុកទឹក មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើផ្នែកជលសាស្ត្រ និងប្រព័ន្ធអេកូឡូស៊ីនៃទន្លេ និងបឹងទន្លេសាបរបស់ប្រទេសកម្ពុជា ប៉ុន្តែមានឥទ្ធិពលតិចតួចលើហេតុប៉ះពាល់ ដោយសារព្រឹត្តិការណ៍ដែលបង្កឡើងដោយអាកាសធាតុធំៗ (ដូចជា ទឹកជំនន់ ជាដើម)។ ការប្រែប្រួលអាកាសធាតុ នៅតែជាកត្តាជំរុញដ៏សំខាន់នៃការផ្លាស់ប្តូរផ្នែកជលសាស្ត្រ ហើយថែមទាំងអាចបង្កើនភាពមិនច្បាស់លាស់ ជុំវិញផលប៉ះពាល់នៃប្រតិបត្តិការវារីអគ្គីសនីទាំងនេះ (Arias et al. 2012; Lauri et al. 2012; Ly, Sayama and Try 2023; Try et al. 2023)។ ការសិក្សាមួយរបស់ Allison et al. (2009) ក៏បានបង្ហាញពីការលំបាក ក្នុងការព្យាករលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូរបរិស្ថានរូបវន្ត និងប្រព័ន្ធអេកូឡូស៊ីលើពពួកត្រី និងផលិតកម្មជលផលនៅក្នុងប្រទេសកំពុងអភិវឌ្ឍ រួមទាំងប្រទេសកម្ពុជាផងដែរ (Allison et al. 2009)។ ដោយសារប្រទេសកម្ពុជាមានភាពងាយរងគ្រោះខ្លាំង ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាមួយនឹងសមត្ថភាពក្នុងការបន្សាំនៅមានកម្រិតនៅឡើយ ដូចនេះភាពមិនច្បាស់លាស់នៃធនធានមច្ឆាជាតិ និងធនធានជលផលនាពេលអនាគត នៅតែជាមូលហេតុនៃការព្រួយបារម្ភកាន់តែខ្លាំងឡើងៗ។

លើសពីនេះទៀត ការគ្រប់គ្រងទឹក និងដី និងអភិបាលកិច្ច មិនច្បាស់លាស់ បាននាំឱ្យមានការសម្របសម្រួលជាលក្ខណៈអន្តរក្រសួងគ្មានប្រសិទ្ធភាព ដែលបណ្តាលឱ្យគោលនយោបាយគ្មានប្រសិទ្ធភាព និងកាត់បន្ថយផលិតភាពកសិកម្ម (Ngin et al. 2024; Öjendal et al. 2023; Sithirith 2017)។ ការសិក្សារបស់ Sithirith (2017) បានគូសបញ្ជាក់ថា ទោះបីជាមានយុទ្ធសាស្ត្រដែលផ្តល់អត្ថប្រយោជន៍ដល់ សហគមន៍កសិករអ្នកប្រើប្រាស់ទឹក ដែលផ្តល់អាទិភាពដល់ ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងទឹកក្តី ក៏យុទ្ធសាស្ត្រទាំងនោះ នៅតែគ្មានប្រសិទ្ធភាព ដោយសារនៅតែត្រូវជាចាំបាច់នូវ ការគាំទ្រពីរាជរដ្ឋាភិបាល និងនៅតែមិនអាចដោះស្រាយតម្រូវការផលិតកម្មកសិកម្មជាលក្ខណៈទូលំទូលាយបាន។ ផលវិបាកនៃកង្វះការសម្របសម្រួលនេះនៅគ្រប់កម្រិតនៃអភិបាលកិច្ច គឺជម្លោះដែលកំពុងកើតមានបន្តលើការប្រើប្រាស់ទឹក រវាងសហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUC) និងសហគមន៍នេសាទនៅក្នុងស្រះជម្រកត្រីសហគមន៍បឹងរៀម និងគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង (Ngin et al. 2024)។ ជាងនេះទៅទៀត ការផ្តោតខ្លាំងលើផលិតកម្មស្រូវក្នុងវិស័យកសិកម្ម ដែលងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ បានផ្តល់ផលអវិជ្ជមានមួយចំនួនលើសន្តិសុខស្បៀង រួមទាំងការបាត់បង់ធនធានទឹក ការខូចខាតដល់ប្រព័ន្ធអេកូឡូស៊ី និងការថយចុះស្តុកត្រី ជម្លោះកាន់តែធ្ងន់ធ្ងរឡើងរវាងអ្នកប្រើប្រាស់ទឹក និងការខូចខាតដល់សន្តិសុខអាហារូបត្ថម្ភ និងការចិញ្ចឹមជីវិត (Ngin et al. 2024)។ ជាងនេះទៅទៀត ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកប៉ះពាល់យ៉ាងខ្លាំងដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងបឹងទន្លេសាប និងដីសណ្តទន្លេមេគង្គរបស់ប្រទេសកម្ពុជា។ គម្រោងវារីអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងអាងទន្លេមេគង្គ ជាពិសេសក្នុងប្រទេសដែលស្ថិតនៅខ្សែទឹកខាងលើ ដែលកម្ពុជាកំពុងខ្វះការគ្រប់គ្រងធនធានទឹក បានធ្វើឱ្យមានការផ្លាស់ប្តូររបបជលសាស្ត្រនៃទន្លេមេគង្គ និងបឹងទន្លេសាប។ ប្រការនេះបានប៉ះពាល់ដល់ផលិតភាពជលផល និងការផ្គត់ផ្គង់ស្បៀងអាហារសម្រាប់ប្រជាជនរស់នៅតាមជនបទ (Sithirith 2024)។ ភាពមិនអាចព្យាករទុកជាមុនបាននៃការទទួលបានទឹក ដោយសារតែការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅផ្នែកខាងលើ និងការប្រែប្រួលអាកាសធាតុ ធ្វើឱ្យបញ្ហាទាំងនេះកាន់តែធ្ងន់ធ្ងរឡើង ដែលបង្កជាការលំបាកដល់កសិករ និងសហគមន៍នេសាទក្នុងការទ្រទ្រង់ជីវភាពរបស់ពួកគេ។

ប្រទេសកម្ពុជាមានសមត្ថភាពទន់ខ្សោយនៅឡើយ ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ រួមជាមួយនឹងហានិភ័យខ្ពស់នៃការធ្វើកសិកម្ម មានន័យថា វិស័យកសិកម្មកាន់តែងាយរងគ្រោះដោយសារកត្តាមួយចំនួន ជាពិសេសការកើនឡើងនៃតម្លៃធាតុចូល ការគំរាមកំហែងដល់សន្តិសុខស្បៀង និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ (Ham et

al. 2023; Touch et al 2023)។ ការចំណាយលើគ្រឿងចក្រ ប្រភេទគ្រាប់ពូជថ្មី ជីគីមី និងថ្នាំសម្លាប់សត្វល្អិត រួមផ្សំនឹងការចំណាយក្នុងគ្រួសារលើការហូបចុកប្រចាំថ្ងៃ ជារឿយៗ មានចំនួនលើសពីចំណូលរបស់កសិករពីរបរកសិកម្ម ដែលបណ្តាលឱ្យមានប្រាក់ចំណេញតិចតួច ក៏ដូចជាការកើនឡើងនៃភាពក្រីក្រនៅតំបន់ជនបទ និងបំណុលកាន់តែច្រើន (Ham et al. 2023; Korn 2021)។ លទ្ធភាពនៅមានកម្រិតក្នុងការទទួលបានដីដែលមានគុណភាពខ្ពស់ អាចទុកចិត្តបាន និងមានតម្លៃសមរម្យ គឺជាកត្តាចម្បងមួយដែលនាំឱ្យទិន្នផលស្រូវទាប ហើយកាន់តែធ្ងន់ធ្ងរឡើងដោយសារក្របខណ្ឌច្បាប់រឹតបន្តឹង ក៏ដូចជាបញ្ហាប្រឈមក្នុងការចែកចាយដីកសិកម្ម (Theng 2020)។ លើសពីនេះ ការខ្វះខាតជំនាញបច្ចេកទេស និងចំណេះដឹងរបស់កសិករ ដោយសារខ្វះការជួយគាំទ្រ និងការបណ្តុះបណ្តាលជាក់ស្តែង មានន័យថាធាតុចូលត្រូវបានប្រើប្រាស់មិនសមស្រប និងគ្មានប្រសិទ្ធភាព បានកម្រិតលើផលិតភាព ទិន្នផលដំណាំ និងកំណើនទាំងមូលនៃវិស័យកសិកម្ម (Korn 2021; MAFF 2020 cited in Nong 2021; Ros, Chhinh and Nang 2011)។ ជាឧទាហរណ៍ ការយល់ដឹងទាបរបស់កសិករអំពីការគ្រប់គ្រងត្រឹមត្រូវ ការប្រើប្រាស់ និងការអនុវត្តតាមវិធីសាស្ត្រនៃការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត មិនត្រឹមតែមានផលប៉ះពាល់អវិជ្ជមានដល់សុខភាព និងបរិស្ថានប៉ុណ្ណោះទេ ថែមទាំងបានជំរុញឱ្យកសិករត្រូវធ្លាក់ក្នុងអន្ទាក់ «ពឹងផ្អែកលើថ្នាំសម្លាប់សត្វល្អិត» ហើយជាហេតុធ្វើឱ្យថយចុះប្រាក់ចំណូលរបស់ពួកគេ (Dunn et al. 2023; Ngin et al. 2017 cited in Dunn et al. 2023)។ ដូចដែលបានរៀបរាប់ពីខាងដើម ទិន្នផលទាំងនោះ ក៏កំពុងថយចុះផងដែរ ដោយសារតែការប្រែប្រួលអាកាសធាតុ ខណៈដែលការចំណាយខ្ពស់ និងលទ្ធភាពរកបាននៅមានកម្រិត ចំពោះធាតុចូលកសិកម្មតាមបែបអភិរក្ស និងរារាំងដល់កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនផលិតភាព និងបង្កើនភាពធន់ទៅនឹងអាកាសធាតុ (Alvar-Beltrán et al. 2022; FAO 2022)។

សេវាផ្សព្វផ្សាយកសិកម្ម គឺជាមធ្យោបាយមួយសម្រាប់កសិករក្នុងការបង្កើនផលិតភាព និងលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់ពួកគេ ដោយផ្តល់ឱ្យពួកគេនូវការទទួលបានព័ត៌មាន ការបណ្តុះបណ្តាល និងបច្ចេកវិទ្យាថ្មីៗ ដែលពិតជាមានសារៈសំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ជាពិសេសក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ (Michigan State University 2017)។ ការគ្របដណ្តប់សេវាផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា គឺមានលក្ខណៈមិនទៀងទាត់ទេ ដោយមានការប៉ាន់ប្រមាណថា ៧០% នៃភូមិដែលបានទទួលសេវាផ្សព្វផ្សាយ ទោះបីជាការផ្សព្វផ្សាយទាំងនេះប្រែប្រួលខុសគ្នាតាមខេត្តនីមួយៗ ហើយម្តងម្កាល គឺទាបជាង ៥០% (Michigan State University 2017; ADB 2021)។ វិស័យសាធារណៈ និងឯកជន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការម្ចាស់ជំនួយ បានផ្តល់សេវាផ្សព្វផ្សាយជាច្រើន ប៉ុន្តែទោះជាយ៉ាងនេះក្តី ការសម្របសម្រួលរវាងអ្នកផ្តល់សេវានៅទន់ខ្សោយ បានន័យថាកសិករជាញឹកញាប់ ទទួលបានព័ត៌មានដែលផ្ទុយគ្នា ដូច្នេះពុំសូវមានប្រសិទ្ធភាពក្នុងការដោះស្រាយ ចំពោះតម្រូវការចាំបាច់របស់សហគមន៍កសិកម្មឱ្យបានគ្រប់គ្រាន់នោះទេ (Bicksler et al. cited in Nickens, Ader and Enriquez 2023; Ke and Babu 2018)។ យោងតាមការសិក្សារបស់ Nickens, Ader and Enriquez (2023) ការទទួលបានព័ត៌មានកាន់តែប្រសើរ នឹងជួយសម្រួលដល់ការអនុវត្តកាន់តែមានប្រសិទ្ធភាពនៃបច្ចេកវិទ្យាប្រកបដោយនិរន្តរភាព ដែលនឹងជួយបង្កើនភាពអាចរកបាន និងភាពខុសគ្នានៃប្រភពអាហារ ក៏ដូចជាបង្កើនសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

# ៣. វិធីសាស្ត្រ

## ៣.១ តំបន់ដែលបានធ្វើការសិក្សា

ខេត្តកំពង់ធំ និងខេត្តតាកែវ ត្រូវបានជ្រើសរើសជាតំបន់សម្រាប់ធ្វើការសិក្សា ដោយសារទីតាំងខេត្តទាំងពីរនេះស្ថិតនៅក្នុងតំបន់ទំនាបលិចទឹកបឹងទន្លេសាប និងដីសណ្តទន្លេមេគង្គនៃប្រទេសកម្ពុជា (រូបភាពទី១)។ ទឹកជំនន់តាមរដូវនៃបឹងទន្លេសាបនាំមកនូវសារធាតុចិញ្ចឹមដល់ត្រី និងការបង្កបង្កើនផលស្រូវ ដែលទាំងពីរនេះជាប្រភពអាហារចម្បងដែលផ្តល់ប្រូតេអ៊ីន សម្រាប់សហគមន៍មូលដ្ឋាន (Sok et al. 2019)។ ដូចគ្នាដែរ ដីមានជីជាតិ និងការផ្គត់ផ្គង់ទឹកដ៏សម្បូរហូរហៀរនៃដីសណ្តទន្លេមេគង្គនៃប្រទេសកម្ពុជា គឺមានអំណោយផលសម្រាប់ការធ្វើស្រែចម្ការ ដែលជាមុខរបរចម្បង និងជាប្រភពចំណូលដ៏សំខាន់សម្រាប់គ្រួសារខ្មែរជាច្រើន (Sithirith et al. 2024)។ តំបន់ទាំងពីរនេះប្រឈមនឹងបញ្ហា ដូចជា ការប្រែប្រួលអាកាសធាតុ ការប្រែប្រួលប្រព័ន្ធធារាសាស្ត្រ និងការរេចរឹលបរិស្ថាន ដែលបានជះ

ឥទ្ធិពលដល់ផលិតភាព និងនិរន្តរភាពនៃតំបន់ទាំងនេះ។ ទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ ការរួមចំណែកនៃតំបន់ទាំងនេះ នៅតែមានតម្លៃមិនអាចកាត់ថ្លៃបានចំពោះសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ អត្រាប្រេវ៉ាឡង់នៃអសន្តិសុខស្បៀងក្នុងតំបន់ទាំងនេះនៅតែមានកម្រិតខ្ពស់ដដែល។ ជាឧទាហរណ៍ ភាពងាយរងគ្រោះនៅតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ ដូចជាបឹងទន្លេសាប ឈានដល់កម្រិតខ្ពស់ ៣៥,៥% ហើយនៅតំបន់ជនបទគឺ ៣២,៨% (WFP 2023)។

ជាក់ស្តែង ការស្រាវជ្រាវនេះ ផ្តោតលើស្រះជម្រកត្រីសហគមន៍បឹងរៀម (CFR) និងគម្រោងធារាសាស្ត្រតាសួង។ បឹងរៀម គឺជាអាងស្តុកទឹកសាបដែលមានតាំងសម័យដើម ស្ថិតក្នុងភូមិជ័យជំនះ និងភូមិសំណាក ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។ បឹងរៀមដែលតភ្ជាប់ជាមួយប្រព័ន្ធធារាសាស្ត្រតាំងក្រសាំងត្រូវបានកំណត់ជាផ្លូវការថាជា “ស្រះជម្រកត្រីសហគមន៍”។ ស្រះជម្រកត្រីនេះស្ថិតនៅក្នុងឃុំកកោះ ដែលជាសហគមន៍មួយចំណុះភូមិចំនួន ១០ និងមានប្រមាណ ៣.៣០៩ខ្នងផ្ទះ (Sithirith et al. 2024)។ ចំណែកប្រជាពលរដ្ឋនៅភូមិកញ្ចិល និងភូមិកំពង់រាប ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ដែលជាទីតាំងគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង ត្រូវបានជ្រើសរើសសម្រាប់ធ្វើការសម្ភាស។ គម្រោងប្រព័ន្ធធារាសាស្ត្រតាសួង គឺជាសមាសភាគដ៏សំខាន់ក្នុងការផលិតស្បៀងប្រកបដោយអាហារូបត្ថម្ភក្នុងតំបន់។ វាអាចស្រោចស្រពលើផ្ទៃដីសរុប ១.៥១១ហិកតា និងផ្តល់អត្ថប្រយោជន៍ដល់កសិករចំនួន ៩៧០គ្រួសារ នៅទូទាំង១៥ភូមិក្នុងឃុំចំនួន៤ (Sithirith et al. 2024)។ តំបន់នេះជាកន្លែងបង្កបង្កើនផលស្រូវយ៉ាងសំខាន់ ដោយកសិករដាំដំណាំស្រូវចំនួនបីដងក្នុងមួយឆ្នាំ ដោយប្រើប្រាស់ទឹកពីទន្លេបាសាក់។ ការអនុវត្តការដាំដុះនេះ អាចធានាបាននូវការផ្គត់ផ្គង់ជាប្រចាំនូវអាហារចម្បង ដែលរួមចំណែកដល់របបអាហារដែលមានតុល្យភាព សម្រាប់ប្រជាជនក្នុងតំបន់។ លើសពីនេះទៀត តំបន់នេះរួមបញ្ចូលទាំងអតីតតំបន់នេសាទមួយផង ដែលបន្ថែមលទ្ធភាពមួយទៀតដល់សមត្ថភាពផលិតអាហារផងដែរ។ ទាំងអង្ករ និងត្រី ត្រូវបានប្រមូលផលនៅទីនេះ ដោយផ្តល់នូវជម្រើសចំណីអាហារសម្បូរជីវជាតិចម្រុះសម្រាប់ទាំងការបរិភោគ និងគោលបំណងពាណិជ្ជកម្ម។ នេះហើយដែលបង្ហាញឱ្យឃើញពីសារៈសំខាន់នៃគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង ក្នុងការលើកកម្ពស់លំអាននៃការផលិត និងការប្រើប្រាស់ស្បៀងអាហារប្រកបដោយនិរន្តរភាពនៅក្នុងតំបន់ (Sithirith et al. 2024)។

រូបភាពទី១៖ ផែនទីនៃទីតាំងសម្រាប់ធ្វើការសិក្សា



## ៣.២ ការប្រមូលទិន្នន័យ

ការសិក្សានេះ ប្រើវិធីសាស្ត្របែបគុណវិស័យ ដែលទិន្នន័យបឋម ត្រូវបានប្រមូលតាមរយៈការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ (KIIs) និងការពិភាក្សាក្រុម (FGDs)។ ជាពិសេសការសម្ភាស KIIs បានធ្វើឡើងជាមួយអ្នកពាក់ព័ន្ធ រួមមាន ប្រធានភូមិ ក្រុមប្រឹក្សាឃុំ ការិយាល័យកសិកម្មស្រុក ធនធានទឹក និងបរិស្ថាន ខណ្ឌរដ្ឋបាលជលផលខេត្ត ស្រះជម្រកត្រីសហគមន៍ សហគមន៍កសិករអ្នកប្រើប្រាស់ទឹក មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរបរិស្ថាន និងមន្ទីរកសិកម្មខេត្ត ដើម្បីទទួលបានព័ត៌មានពីក្រុមមនុស្សទាំងនេះលើវិស័យនានា និងទទួលបានការយល់ដឹងស៊ីជម្រៅអំពីបរិបទក្នុងស្រុកទាក់ទងនឹងការផលិត និងការប្រើប្រាស់ស្បៀងអាហារ។ លើសពីនេះទៀតការពិភាក្សា FGDs ត្រូវបានធ្វើឡើងជាមួយក្រុមមនុស្សផ្សេងៗគ្នាដូចជា ក្រុមបុរសដែលមិនស្ថិតក្នុងគ្រួសារក្រីក្រ ក្រុមបុរសដែលក្រីក្រ (អត្តសញ្ញាណក្រីក្រ១ និង ២) ក្រុមស្ត្រីដែលមិនស្ថិតក្នុងគ្រួសារក្រីក្រ ក្រុមស្ត្រីដែលក្រីក្រ (អត្តសញ្ញាណក្រីក្រ១ និង ២) និងក្រុមស្ត្រីដែលជាមេគ្រួសារនៅតាមទីតាំងនីមួយៗដែលបានធ្វើការសិក្សា។ កម្មវិធីអត្តសញ្ញាណកម្មក្រីក្រ (ID Poor) គឺជាគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល ក្រោមការគ្រប់គ្រងដោយក្រសួងផែនការ ដែលបានចាត់ថ្នាក់គ្រួសារជាបួនក្រុមផ្សេងគ្នាដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេៈ ក្រីក្រ១ (ក្រីក្រខ្លាំង) ក្រីក្រ២ (ក្រីក្រ) មានហានិភ័យ និងមិនមែនក្រីក្រ (RGC 2011)។ ប្រព័ន្ធនេះ អនុញ្ញាតឱ្យមានការផ្តល់ជំនួយចំគោលដៅ និងការបែងចែកធនធានឱ្យបានសមស្រប។ កម្រងសំណួរសម្រាប់ការសម្ភាស KII និងការពិភាក្សា FGD ត្រូវបានរៀបចំឡើងដើម្បីឈ្វេងយល់ពីឧបសគ្គចំពោះការប្រើប្រាស់ស្បៀងអាហារនៅក្នុងសហគមន៍ទាំងនេះ ដោយគ្របដណ្តប់លើប្រធានបទជាច្រើន រួមមានប្រភពចំណូល ការយល់ដឹងអំពីអាហារូបត្ថម្ភ ទម្លាប់នៃការចំណាយ ការផលិតស្បៀងអាហារ និងវិធីទប់ទល់ក្នុងគ្រាមានប្រាក់ចំណូលទាប។ តារាងទី១ខាងក្រោម បង្ហាញពីចំនួនអ្នកចូលរួមផ្តល់ព័ត៌មានក្នុងការសិក្សាស្រាវជ្រាវនេះ។ ព័ត៌មានលម្អិតអាចរកបាននៅក្នុងឧបសម្ព័ន្ធ (សូមមើលតារាង ក១)។

តារាងទី១ៈ ការធ្វើសំណាក និងទំហំនៃសំណាក

| លរ. | អ្នកផ្តល់បទសម្ភាសន៍ | ចំនួនសំណាក |
|---|---|---|
| ១ | មន្ត្រីរាជការនៅក្នុងខេត្ត អាជ្ញាធរមូលដ្ឋាន មេឃុំ និងក្រុមប្រឹក្សាឃុំ (ការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ) | ១៩នាក់ |
| ២ | គ្រួសារមិនមែនក្រីក្រ ក្រីក្រ និងស្ត្រីមេគ្រួសារ (ការពិភាក្សាក្រុម) | ២០ក្រុម ឬស្មើនឹង ១២០នាក់ |

អ្នកចូលរួមផ្តល់ព័ត៌មាន ត្រូវបានជ្រើសរើសតាមទីតាំងភូមិសាស្ត្រ ដែលពួកគេកំពុងរស់នៅ ជាពិសេសអ្នកភូមិ និងអាជ្ញាធរមូលដ្ឋានដែលកំពុងរស់នៅ និងប្រកបការងារ នៅតាមគម្រោងប្រព័ន្ធធារាសាស្ត្រ និងស្រះជម្រកត្រីសហគមន៍។ ពួកគាត់ភាគច្រើន រស់ដោយពឹងអាស្រ័យលើតំបន់ទាំងនេះ សម្រាប់ការចិញ្ចឹមជីវិតជាប្រចាំថ្ងៃ ចំណែកអាជ្ញាធរមូលដ្ឋានវិញ ក៏មានការយល់ដឹងច្បាស់លាស់ ទាក់ទងនឹងការផលិត និងការប្រើប្រាស់ស្បៀងអាហារនៅក្នុងតំបន់ទាំងនេះផងដែរ។

តារាងទី២ៈ របាយនៃសំណាកសរុបតាមតំបន់/ឃុំនីមួយៗ

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ | ការពិភាក្សាក្រុម |
|---|---|---|---|---|---|
| ស្រះជម្រកត្រីសហគមន៍បឹងរៀម | | | | | |
| កំពង់ធំ | សន្ទុក | កកោះ | • ជ័យជំនះ<br>• សំណាក | ១០ | ១០ |
| គម្រោងប្រព័ន្ធធារាសាស្ត្រតាសួង | | | | | |
| តាកែវ | ព្រៃកប្បាស | កំពង់រាប | • កញ្ជិល<br>• កំពង់រាប | ៩ | ១០ |
| | | | សរុប | ១៩នាក់ | ២០ក្រុម |

កម្រងសំណួរសម្រាប់ការសម្ភាស (KII) និងការពិភាក្សាក្រុម (FGD) ត្រូវបានរៀបចំឡើង ដើម្បីឈ្វេងយល់ពីកត្តាដែលជះឥទ្ធិពលលើជម្រើស និងការប្រើប្រាស់ស្បៀងអាហារនៅក្នុងសហគមន៍ទាំងនេះ និងនៅតាមគ្រួសារដែលមានទីតាំងខុសៗគ្នា ដោយគ្របដណ្តប់លើប្រធានបទជាច្រើន រួមមាន ប្រភពចំណូល ការយល់ដឹងអំពីអាហារូបត្ថម្ភ ទម្លាប់នៃការចំណាយ ការផលិតស្បៀងអាហារ និងវិធីទប់ទល់ក្នុងគ្រាមានប្រាក់ចំណូលទាប។ សម័យប្រជុំមួយត្រូវបានធ្វើឡើងនៅវិទ្យាស្ថាន CDRI ក្នុងសប្តាហ៍ទីពីរនៃខែមករា ឆ្នាំ២០២៤ ដើម្បីបណ្តុះបណ្តាលអ្នកប្រមូលព័ត៌មាន និងទិន្នន័យ ដែលមានបទពិសោធន៍ចំនួន ៤នាក់ អំពីគោលបំណងសិក្សា និងរបៀបធ្វើ KIIs និង FGDs ដោយប្រើប្រាស់កម្រងសំណួរ។ ការធ្វើតេស្តសាកល្បងលើកម្រងសំណួរ ត្រូវបានធ្វើឡើងក្នុងចំណោមអ្នកប្រមូលព័ត៌មាន និងទិន្នន័យ និងក្រុមការងារ CDRI បន្ទាប់មកមានការកែសម្រួលសំណួរមួយចំនួន។ នៅពេលបញ្ចប់ការធ្វើតេស្តសាកល្បង និងការកែសម្រួលរួចមក ការប្រមូលទិន្នន័យចាប់ផ្តើមធ្វើនៅសប្តាហ៍ទីបីនៃខែមករា ឆ្នាំ២០២៤។ រាល់ការធ្វើសម្ភាសន៍ KIIs និងការពិភាក្សា FGDs ត្រូវបានថតទុកជាសំឡេងដោយមានការយល់ព្រមពីអ្នកចូលរួមម្នាក់ៗ។ ការថតសំឡេងត្រូវបានចម្លងជាអក្សរ និងបកប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេសសម្រាប់ការវិភាគទិន្នន័យ។

### ៣.៣ ការវិភាគទិន្នន័យ

ព័ត៌មានដែលប្រមូលបានពី KIIs និង FGDs ត្រូវបានចងក្រង សង្ខេប និងវិភាគតាមប្រធានបទនីមួយៗ ដោយប្រើបញ្ជីទម្រង់ Excel។ ប្រធានបទដើមទីដែលបានកំណត់ពីទិន្នន័យដែលប្រមូលបាន រួមមាន ការយល់ដឹងអំពីអាហារូបត្ថម្ភ ទម្លាប់នៃការចំណាយ ការផលិតស្បៀងអាហារ និងវិធីទប់ទល់ក្នុងគ្រាមានប្រាក់ចំណូលទាប។ យើងបានដាក់តម្រៀបលទ្ធផលតាមតំបន់នីមួយៗ និងលក្ខណៈរបស់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីទទួលបានការយល់ដឹងច្បាស់លាស់ អំពីរបៀបដែលប្រធានបទទាំងនេះ ប្រែប្រួល និងប្រមូលបញ្ចូលគ្នាក្នុងក្រុមផ្សេងៗ។ នៅក្នុងជំហានចុងក្រោយ យើងបានចងក្រងជាការអត្ថាធិប្បាយទៅតាមប្រធានបទនីមួយៗ ដើម្បីរៀបចំសម្រាប់ការបកស្រាយទិន្នន័យ និងការពិភាក្សាអំពីលទ្ធផលរកឃើញ។ សម្រាប់ប្រធានបទនីមួយៗ យើងបានបង្ហាញលទ្ធផលដែលបានពីទីតាំងនីមួយៗ ដើម្បីជួយសម្រួលដល់ការប្រៀបធៀប សបញ្ជាក់ឱ្យឃើញអំពីភាពស្រដៀងគ្នា និងភាពខុសគ្នា រវាងភាគីពាក់ព័ន្ធ និងទីតាំងនីមួយៗ។ លើសពីនេះទៅទៀត នៅកន្លែងមួយចំនួនដែលអាច យើងបានរួមបញ្ចូលសម្តីដោយផ្ទាល់ពីភាគីពាក់ព័ន្ធ និងទីតាំងផ្សេងៗ ដើម្បីគាំទ្រដល់ការរកឃើញ និងការពិភាក្សារបស់យើង។

## ៤. លទ្ធផលស្រាវជ្រាវ

ត្រង់ផ្នែកនេះ បង្ហាញពីបរិបទរបស់អ្នកឆ្លើយសំណួរ ដែលកំពុងរស់នៅតាមទីកន្លែងដែលយើងបានធ្វើការសិក្សា និងលទ្ធផលស្រាវជ្រាវសំខាន់ៗអំពី ការយល់ដឹង និងការទទួលបានព័ត៌មានអាហារូបត្ថម្ភ ការចំណាយលើស្បៀងអាហារ ការផលិតស្បៀងអាហារ ការចាត់ចែងស្បៀងអាហារក្នុងគ្រាខ្វះខាត ផលប៉ះពាល់ និងឧបសគ្គផ្លូវការ និងក្រៅផ្លូវការចំពោះការផលិត និងប្រើប្រាស់ស្បៀងអាហារ និងអាហារូបត្ថម្ភ។

### ៤.១ បរិបទ

គ្រួសារដែលរស់នៅតាមទីតាំងដែលបានធ្វើការសិក្សា មានសក្តានុពលសេដ្ឋកិច្ច-សង្គមខុសប្លែកគ្នា។ ភាគច្រើនការធ្វើស្រែចម្ការ គឺជាប្រភពចំណូលចម្បង ដោយមានកម្មសិទ្ធិដីធ្លីក្នុងទំហំខុសៗគ្នា។ ការអប់រំនៅមានកម្រិតទាប ទោះបីជាគ្រួសារខ្លះមិនមែនជាក្រីក្រ ក៏ទទួលបានការអប់រំខ្ពស់ជាធម្មតាក៏ដោយ។

នៅក្នុងគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង ស្ថានភាពសេដ្ឋកិច្ច-សង្គម មានភាពខុសប្លែកគ្នាយ៉ាងទូលំទូលាយក្នុងចំណោមគ្រួសារនីមួយៗ។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ពឹងអាស្រ័យលើការនេសាទ ការធ្វើស្រែចម្ការ និងការចិញ្ចឹមសត្វដើម្បីរកប្រាក់ចំណូល ដោយសមាជិកខ្លះបានធ្វើចំណាកស្រុកតាមរដូវកាល ដើម្បីទៅធ្វើការងារបន្ថែមនៅខាងក្រៅ។ ស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រភាគច្រើន ពឹងអាស្រ័យលើកម្មវិធីគាំពារសង្គម ការនេសាទ និងការងារកសិកម្ម ហើយជាទូទៅមានកម្មសិទ្ធិដីធ្លីមានកម្រិត។ ចំណែកបុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ អាចរកប្រាក់ចំណូលបានពីប្រភពស្រដៀងគ្នានេះដែរ ជាមួយនឹងកម្មសិទ្ធិដីធ្លីក្នុងទំហំខុសៗគ្នា។ ទាំងស្ត្រី និងបុរសដែលមិនមែនស្ថិតក្នុងគ្រួសារ

ក្រីក្រ ប្រកបរបរកសិកម្ម ចម្លាក់ថ្ម និងនេសាទ ដោយខ្លះទៀត បានធ្វើចំណាកស្រុកទៅធ្វើការនៅខាងក្រៅ។ ជាទូទៅ ពួកគេមានដីធ្លីក្នុងទំហំពីមធ្យមទៅធំ។

នៅក្នុងទីតាំងស្រះជម្រកត្រីសហគមន៍បឹងរៀម គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ទទួលបានប្រាក់ចំណូលជាចម្បងពីការធ្វើស្រែចម្ការ ចម្លាក់ថ្ម និងការចិញ្ចឹមសត្វ ហើយមានកម្រិតអប់រំទាប។ អ្នកខ្លះទៀតបានឱ្យដឹងថា សមាជិកគ្រួសាររបស់ខ្លួនបានធ្វើចំណាកស្រុកទៅក្រៅប្រទេស ដើម្បីស្វែងរកការងារធ្វើ។ ស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់ពឹងអាស្រ័យលើការផ្ទេរសាច់ប្រាក់ដែលបានពីកម្មវិធីគាំពារសង្គម ការងារកសិកម្ម និងការនេសាទ ហើយមានកម្មសិទ្ធិដីធ្លីមានកម្រិត។ ចំណែកបុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ មានប្រភពចំណូលស្រដៀងគ្នានេះដែរ ជាមួយនឹងកម្មសិទ្ធិដីធ្លីក្នុងទំហំខុសៗគ្នា។ ស្ត្រី និងបុរសដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ មានប្រភពចំណូលស្រដៀងនឹងអ្នករស់នៅក្នុងខេត្តតាកែវដែរ ហើយជាទូទៅមានដីធ្លីក្នុងទំហំពីមធ្យមទៅធំ។

## ៤.២ ការផ្សព្វផ្សាយ និងការទទួលបានព័ត៌មានស្តីពីអាហារូបត្ថម្ភ

អ្នកចូលរួមឆ្លើយសំណួរ បានបង្ហាញពីការយល់ដឹងជាមូលដ្ឋានអំពីអាហារូបត្ថម្ភ ប៉ុន្តែនៅខ្វះចំណេះដឹងលម្អិត។ សាលារៀនត្រូវបានគេកំណត់ថា ជាទីកន្លែងចម្បងក្នុងការផ្សព្វផ្សាយព័ត៌មានស្តីពីអាហារូបត្ថម្ភ បន្ទាប់មក គឺតាមរយៈទូរស័ព្ទ វិទ្យុ និងទូរទស្សន៍។ ទោះជាយ៉ាងណាក៏ដោយ លទ្ធភាពទទួលបានប្រភពព័ត៌មានទាំងនេះ នៅមានកម្រិតជាពិសេស សម្រាប់អ្នកដែលស្ថិតក្នុងគ្រួសារក្រីក្រ។

ទោះបីជាមានសារតារសេដ្ឋកិច្ច-សង្គមចម្រុះផ្សេងគ្នាក៏ដោយ ទាំងបុរស និងស្ត្រី បានចែករំលែកការយល់ដឹងទូទៅអំពីអាហារូបត្ថម្ភដល់គ្នាទៅវិញទៅមក។ ទោះជាយ៉ាងណាក៏ដោយ ការយល់ដឹងនេះ ច្រើនតែស្រពេចស្រពិលគ្មានភាពច្បាស់លាស់ទេ។ អាហារូបត្ថម្ភត្រូវបានផ្សារភ្ជាប់ជារួម ជាមួយនឹងការទទួលទានរបបអាហារចម្រុះច្រើនយ៉ាងដែលរួមមានអាហារសំខាន់ៗដូចជា អង្ករ (ឬបាយ) ប្រភពប្រូតេអ៊ីន ដូចជា ត្រី និងសាច់ និងបន្លែបង្ការជាច្រើនប្រភេទជាដើម។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ បើទោះបីជាមានការទទួលស្គាល់ពីសារៈសំខាន់នៃគ្រាប់ធញ្ញជាតិ នៅក្នុងរបបអាហារដែលមានតុល្យភាពក៏ដោយ ក៏ពួកគេទាំងបុរស និងស្ត្រី មិនបានលើកឡើងនៅក្នុងនិយមន័យនៃអាហារូបត្ថម្ភទេ ដែលនេះចង្អុលបង្ហាញឱ្យឃើញពីគម្លាតនៃចំណេះដឹងផ្នែកអាហារូបត្ថម្ភ។ ក្នុងចំណោមបុគ្គលដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ ដោយមិនគិតពីភេទ ឬទីកន្លែង មានការទទួលស្គាល់ច្បាស់លាស់អំពីសារៈសំខាន់នៃអនាម័យ និងទិដ្ឋភាពនៃការទទួលបានអាហារូបត្ថម្ភតាមវិធីត្រឹមត្រូវ។ ទស្សនៈយល់ឃើញពី សារៈសំខាន់នៃទម្លាប់ទទួលទានរបបអាហារមានអនាម័យ ក៏ត្រូវបានចែករំលែកដោយស្ត្រីមួយចំនួនជាមេគ្រួសារក្នុងខេត្តតាកែវ ដូចខាងក្រោម៖

> *អាហារូបត្ថម្ភ គឺមានន័យថា ការបរិភោគបន្លែដែលគ្មានជាតិគីមី និងការបរិភោគស្អាត។ ការបរិភោគបន្លែបង្ការដែលដាំតាមផ្ទះ ក្នុងសួនច្បាររបស់យើង គឺល្អជាងការទិញពីទីផ្សារ។ តាមការយល់ដឹងរបស់ខ្ញុំ វាអាចការពារកុមារ និងមនុស្សចាស់ មិនឱ្យឆ្លងជំងឺដែលបង្កគ្រោះថ្នាក់។* FGD, ស្ត្រីដែលជាមេគ្រួសារ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

នៅគ្រប់ក្រុមទាំងអស់ បានឱ្យដឹងថា អាហារូបត្ថម្ភមិនត្រឹមតែមានសារៈសំខាន់ប៉ុណ្ណោះទេ ប៉ុន្តែជាភាពចាំបាច់នៃសុខុមាលភាព ដោយមនុស្សជាច្រើនជឿជាក់ថា ការទទួលទានអាហារដូចដែលបានរៀបរាប់ខាងលើ ពិតជាអាចជួយធ្វើឱ្យរាងកាយមាំមួន និងផ្តល់ការការពារប្រឆាំងនឹងជំងឺផ្សេងៗ។ ជំនឿនេះគូសបញ្ជាក់ពីទំនាក់ទំនងដោយផ្ទាល់រវាងរបបអាហារ សុខភាព និងសុខុមាលភាព ហើយសបញ្ជាក់ឱ្យឃើញពីតួនាទីសំខាន់នៃអាហារូបត្ថម្ភក្នុងជីវិតរស់នៅរបស់ពួកគេ។ ការពង្រីកការយល់ដឹងអំពីអាហារូបត្ថម្ភ និងផលប៉ះពាល់របស់វាទៅលើសុខភាព និងសុខុមាលភាព ផ្តល់នូវទិដ្ឋភាពដ៏ទូលំទូលាយនៃសក្តានុពលសេដ្ឋកិច្ច-សង្គមនៃក្រុមនីមួយៗ។

ប្រភព និងពេលវេលានៃការអប់រំអាហារូបត្ថម្ភ បានបង្ហាញពីការប្រែប្រួលយ៉ាងខ្លាំង ក្នុងចំណោមអ្នកចូលរួមឆ្លើយសំណួរ ដែលត្រូវបានជះឥទ្ធិពលដោយកត្តានានា ដូចជា យេនឌ័រ និងស្ថានភាពសេដ្ឋកិច្ច-សង្គម។ ប្រភពទូទៅនៃព័ត៌មានដែលលាតសន្ធឹងទាំងផ្លូវការ និងក្រៅផ្លូវការ រួមទាំងបណ្តាញផ្សព្វផ្សាយសង្គម ទូរស័ព្ទ ទូរទស្សន៍ និងវិទ្យុ (ទោះបីជាលទ្ធភាពប្រើប្រាស់មធ្យោបាយទាំងនេះ ជាធម្មតានៅមានកម្រិតក៏ដោយ) ក៏ដូចជាក្រុមគ្រួសារ មិត្តភក្តិ

សាលារៀន និងការពិនិត្យសុខភាព។ ស្ត្រី ជាពិសេសអ្នកដែលរៀបការហើយ ឬមានផ្ទៃពោះ តែងតែទទួលបានចំណេះដឹងអំពីអាហារូបត្ថម្ភ តាមរយៈការពិនិត្យសុខភាពអំឡុងពេលមានផ្ទៃពោះ។ និន្នាការនេះ ត្រូវបានគេដឹងកាន់តែច្បាស់ក្នុងចំណោមស្ត្រីដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ ដែលនេះសបញ្ជាក់ឱ្យឃើញពីបញ្ហាទូលំទូលាយ ទាក់ទងនឹងការទទួលបានសេវាថែទាំសុខភាព និងវិសមភាពក្នុងការទទួលបានការអប់រំនៅក្នុងចំណោមក្រុមសេដ្ឋកិច្ច-សង្គមទាំងអស់៖

*មណ្ឌលសុខភាពស្រុកបានពន្យល់ប្រាប់ពួកខ្ញុំថា អ្វីខ្លះជាអាហារមានជីវជាតិ និងគួរទទួលទានក្នុង អំឡុងពេលមានផ្ទៃពោះ ដើម្បីមានសុខភាពល្អ។* FGD ស្ត្រីដែលជាមេគ្រួសារ រស់នៅភូមិសំណាក ឃុំកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

*ខ្ញុំបានទទួលព័ត៌មានអំពីអាហារូបត្ថម្ភតាមរយៈ មណ្ឌលសុខភាព និងពីអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាតាមហ្វេសប៊ុក។* FGD ស្ត្រីដែលមិនមែនស្ថិតនៅក្នុងគ្រួសារក្រីក្រ រស់នៅភូមិសំរោង ឃុំកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

ផ្ទុយទៅវិញ បុរសខ្លះដែលស្ថិតក្នុងគ្រួសារក្រីក្រ ជាពិសេសនៅខេត្តតាកែវ មានការយល់ដឹងអំពីអាហារូបត្ថម្ភនៅពេលទៅជួបគ្រូពេទ្យម្តងៗ ឬនៅពេលទៅមណ្ឌលថែទាំសុខភាពក្នុងមូលដ្ឋាន។ ចំណែកអ្នកផ្សេងទៀត ជាពិសេសក្នុងខេត្តកំពង់ធំ មានការយល់ដឹងខ្លះៗតាមរយៈការសន្ទនាជាមួយក្រុមគ្រួសារ និងមិត្តភក្តិ។ បុគ្គលមួយចំនួនតូច ដែលភាគច្រើនមកពីគ្រួសារក្រីក្រមិនថាបុរស ឬស្ត្រី បានរំលឹកពីការរៀនសូត្រខ្លះៗ អំពីអាហារូបត្ថម្ភពីគ្រួសាររបស់ពួកគេកាលពីនៅកុមារភាព។ និន្នាការនេះត្រូវបានគេដឹងតិចតួចណាស់ក្នុងចំណោមអ្នកដែលមកពីគ្រួសារក្រីក្រ ជាពិសេសស្ត្រីមេគ្រួសារ និងអ្នកដែលត្រូវបានកំណត់អត្តសញ្ញាណជាជនក្រីក្រ។ បុគ្គលមួយចំនួនទៀតទទួលបានចំណេះដឹងផ្នែកអាហារូបត្ថម្ភកាលពីនៅរៀនសាលាបឋមសិក្សា (អាយុចន្លោះពី ៦ ទៅ ១៥ឆ្នាំ) រីឯអ្នកផ្សេងទៀតខកខានរៀនដោយសារតែខ្វះសាលារៀននាពេលនោះ ដែលសបញ្ជាក់ឱ្យឃើញពីវិសមភាពក្នុងការទទួលបានការអប់រំផ្លូវការ៖

*ខ្ញុំមិនដែលបានដឹងរឿងអស់នេះទេ តាំងពីខ្ញុំនៅរៀនម្ល៉េះ។ ភាគច្រើន ខ្ញុំធ្លាប់បានឮការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍។* FGD ស្ត្រីដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកំពង់រាប ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

*ពេលនេះ ខ្ញុំមានអាយុជិត ៥០ឆ្នាំទៅហើយ។ ខ្ញុំធ្លាប់បានឮជាលើកដំបូងអំពីអាហារូបត្ថម្ភកាលពីប្រហែល ២០ឆ្នាំមុន។ ប៉ុន្តែខ្ញុំមិនមានចំណេះដឹងស៊ីជម្រៅអ្វីទេ ហើយក៏មិនដែលបានរៀនសូត្រពីអាហារូបត្ថម្ភនៅសាលាដែរ។* FGD បុរសដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកំពង់រាប ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ការពិនិត្យសុខភាព សេវាផ្សព្វផ្សាយ និងយុទ្ធនាការអប់រំដែលបានរៀបចំដោយ មណ្ឌលសុខភាពក្នុងមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានគេលើកឡើងជាញឹកញាប់ថា ជាប្រភពចម្បងនៃការទទួលបានព័ត៌មានអំពីអាហារូបត្ថម្ភសម្រាប់ទាំងគ្រួសារក្រីក្រ និងគ្រួសារមិនមែនក្រីក្រនៅក្នុងទីតាំងទាំងពីរ៖

*មណ្ឌលសុខភាពស្រុក បានរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់អ្នកភូមិខ្លះដែរ។ កាលពីឆ្នាំមុនក្នុងឆ្នាំ២០២២ អង្គការអុកស្វាម ក៏បានផ្តល់ការបណ្តុះបណ្តាល និងយុទ្ធនាការអប់រំអំពីអាហារូបត្ថម្ភ និងសុខភាពផងដែរ។ តាមខ្ញុំនៅចាំបាន ខ្ញុំធ្លាប់ចូលរួមបួនដងដែរ។ ក្នុងវគ្គមួយនោះ គេបានបង្រៀនយើងអំពីអាហារូបត្ថម្ភ អនាម័យ ការបរិភោគទឹកស្អាត និងទទួលទានបន្លែបៃតង ដើម្បីជួយឱ្យរាងកាយយើងបានរឹងមាំ។ ទាំងប្រពន្ធ និងកូនស្រីរបស់ខ្ញុំ ក៏ធ្លាប់បានចូលរួមជាមួយខ្ញុំក្នុងវគ្គអប់រំផ្សព្វផ្សាយនោះដែរ។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកំពង់រាប ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ទោះបីជាមានប្រភពព័ត៌មានច្រើនហើយក្តី ការទទួលបានការអប់រំស្តីពីអាហារូបត្ថម្ភ នៅតែមិនទាន់ស្មើភាពគ្នាដោយសារតែកត្តាសេដ្ឋកិច្ច-សង្គម ដើរតួនាទីយ៉ាងសំខាន់ ក្នុងចំណោមក្រុមមនុស្សផ្សេងៗគ្នា។ ស្ត្រី ជាពិសេសស្ត្រីជាម្តាយ ឬជាភរិយា ត្រូវបានគេមើលឃើញថា ជាអ្នកចូលរួមចម្បងនៅក្នុងព្រឹត្តិការណ៍អប់រំផ្សព្វផ្សាយការយល់ដឹងអំពីសុខភាព និងអាហារូបត្ថម្ភនៅទីតាំងទាំងពីរ។ ចំណូលចិត្តសម្រាប់ការចូលរួមរបស់ស្ត្រី ត្រូវបានចាក់ឫសយ៉ាងជ្រៅនៅក្នុងបទដ្ឋានសង្គមដែលផ្សារភ្ជាប់ពួកគេជាមួយនឹងតួនាទីគ្រប់គ្រងគ្រួសារ និងការថែទាំ។ លទ្ធភាពរបស់ស្ត្រី អាចធ្វើកិច្ចការនៅផ្ទះបាន បើប្រៀបធៀបទៅនឹងបុរសតែងតែធ្វើការនៅខាងក្រៅផ្ទះ ដូច្នេះហើយទើបស្ត្រីមានលទ្ធភាពអាចចូលរួមក្នុងព្រឹត្តិការណ៍អប់រំទាំងនេះបន្ថែមទៀត ដូចដែលបានលើកឡើងខាងក្រោម៖

*ខ្ញុំមានកូនតូចៗនៅផ្ទះ ហើយប្រពន្ធខ្ញុំ គឺជាអ្នកមើលថែពួកគេ ពេលខ្ញុំទៅធ្វើការរកប្រាក់នៅខាងក្រៅ។ ប្រហែលជាប្រពន្ធខ្ញុំ ធ្លាប់បានចូលរួមការប្រជុំផ្សេងៗ ឬធ្លាប់បានទទួលការបណ្តុះបណ្តាលអំពីប្រធានបទនេះ។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ។

គេសង្កេតឃើញថា ក្រុមបុរសមួយចំនួនដែលបានចូលរួមឆ្លើយសំណួរ មិនត្រឹមតែមិនបានដឹងពីពេលវេលា និងព័ត៌មានលម្អិតនៃព្រឹត្តិការណ៍ទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែក៏មិនប្រាកដប្រជាផងដែរថាតើភរិយា ឬក្រុមគ្រួសាររបស់ពួកគាត់ធ្លាប់បានចូលរួមកម្មវិធីអប់រំផ្សព្វផ្សាយទាំងនោះដែរឬអត់ផង។ ដូច្នេះគេអាចទាញការសន្និដ្ឋានជាមូលដ្ឋានថា បញ្ហាទាក់ទងនឹងស្បៀងអាហារ និងអាហារូបត្ថម្ភ គឺជាទំនួលខុសត្រូវរបស់ស្ត្រីជាចម្បង ដោយសារតួនាទីរបស់ពួកគេជាមេផ្ទះ និងអ្នកថែទាំបបមះ

*ខ្ញុំមិនប្រាកដថា គេកំពុងបន្តផ្សព្វផ្សាយ ឬអត់ទេតឡូវនេះ ប៉ុន្តែបើតាមខ្ញុំចាំ ប៉ុន្មានឆ្នាំមុន ខ្ញុំធ្លាប់ឮមេភូមិហៅគ្រួសារតាមផ្ទះនីមួយៗឱ្យចូលរួមប្រជុំ ប៉ុន្តែខ្ញុំជាប់រវល់ ហើយខ្ញុំមិនច្បាស់ថា ប្រពន្ធ ឬអ្នកណា នៅក្នុងគ្រួសាររបស់ខ្ញុំបានចូលរួមទេ។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ។

*មុខរបរខ្ញុំ គឺជាអ្នកចម្រៀងបទប្រពៃណីក្នុងពិធីមង្គលការ។ ដូច្នេះ ខ្ញុំមិនសូវបាននៅផ្ទះទេ។ ខ្ញុំតែងតែចេញទៅភូមិផ្សេងៗ ដែលគេជួលខ្ញុំឱ្យទៅច្រៀងក្នុងពិធីផ្សេងៗ។ ប្រហែលជាមានវគ្គបណ្តុះបណ្តាល ឬការប្រជុំខ្លះដែរអំពី [អាហារូបត្ថម្ភ] ហើយប្រធានភូមិ ធ្លាប់បានសួរប្រពន្ធខ្ញុំ ប៉ុន្តែខ្ញុំមិនបានឮអ្វីទេ ហើយខ្ញុំក៏មិនប្រាកដថា ប្រពន្ធខ្ញុំបានចូលរួមដែរឬអត់ផង។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកប្បាស ខេត្តតាកែវ។

ទោះបីជាយ៉ាងនេះក្តី មានករណីជាច្រើនដែលបុរស ជាពិសេសស្វាមី ឬជាឪពុក ធ្លាប់បានចូលរួមកម្មវិធីអប់រំផ្សព្វផ្សាយខ្លះៗដែរ ប្រសិនបើមានគេរៀបចំឡើង ទោះបីមិនសូវបានញឹកញាប់ក៏ដោយ។ ការចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះ ច្រើនតែកំណត់ដោយស្ថានភាពទំនេររបស់បុគ្គលម្នាក់ៗ ឬសម្រាប់អ្នកដែលមានសេរីភាពក្នុងការចូលរួមដូច្នេះបាន ដូចដែលបានពន្យល់ដោយអ្នកឆ្លើយសំណួរខាងក្រោម។ នេះបង្ហាញថា ទោះបីជាមានការរំពឹងថា ស្ត្រីជាអ្នកដែលត្រូវចូលរួមក្នុងព្រឹត្តិការណ៍បែបនេះស្របតាមតួនាទី និងទំនួលខុសត្រូវក្នុងគ្រួសារក៏ដោយ *បុរសៗយល់ថាមិនចាំបាច់ខ្វល់ខ្វាយអ្វីទេ ឬមិនមានឆន្ទៈក្នុងការអប់រំខ្លួនឯងអំពីបញ្ហាទាំងនេះឡើយ។*

*ប្រសិនបើ ប្តីខ្ញុំត្រឡប់មកពីស្រែវិញទាន់ពេល គាត់ក៏នឹងចូលរួមដែរ។ ប៉ុន្តែភាគច្រើន គាត់រវល់នៅតែវាលស្រែ។* FGD ស្ត្រីស្ថិតក្នុងគ្រួសារមិនមែនក្រីក្រ រស់នៅភូមិសំរោង ឃុំកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

បើគិតតាមទស្សនៈនៃអភិបាលកិច្ច វិធីសាស្ត្រដែលបានធ្វើឡើង ដើម្បីផ្តល់ឱ្យមនុស្សនូវព័ត៌មានអាហារូបត្ថម្ភហាក់មានភាពមិនស្មើគ្នាគួរឱ្យកត់សម្គាល់ នៅក្នុងទីតាំងទាំងពីរដែលបានធ្វើការសិក្សានេះ។ ទាំងនៅក្នុងគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង និងស្រះជម្រកត្រីសហគមន៍បឹងរៀម សុទ្ធតែមានស្ថាប័ន និងតួអង្គផ្សេងៗ កំពុងដំណើរការការងារជាធម្មតា ដោយមានរបៀបវារៈខុសៗគ្នា។ ក្នុងករណីខ្លះ ប្រធានភូមិ មេឃុំ និងក្រុមប្រឹក្សាឃុំ សកម្មណាស់ក្នុងការកៀរគរប្រជាពលរដ្ឋឱ្យចូលរួមវគ្គចែករំលែកព័ត៌មាន និងវគ្គបណ្តុះបណ្តាលស្តីពីអាហារូបត្ថម្ភ ដោយសហការជាមួយសាលារៀន មន្ទីរពេទ្យ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីជួយសម្រួលដល់ការងារផ្សព្វផ្សាយនេះ៖

*អង្គការមិនមែនរដ្ឋាភិបាលមួយ បានមកធ្វើការនៅក្នុងភូមិ ដែលផ្តោតលើការលើកកម្ពស់ការយល់ដឹងនិងការផ្តល់ការបណ្តុះបណ្តាលស្តីពីស្បៀងអាហារ និងអាហារូបត្ថម្ភដល់កុមារ និងស្ត្រីមានផ្ទៃពោះ។ មន្ទីរពេទ្យក្នុងមូលដ្ឋាន ក៏ធ្លាប់បង្រៀនលើប្រធានបទសំខាន់នេះផងដែរ (...) បើមានស្ថាប័នដៃគូណាមួយចូលមកដល់ភូមិមេដើរតួជាអ្នកសម្របសម្រួលក្នុងការប្រមូលផ្តុំមនុស្ស ឱ្យមកចូលរួមវគ្គបណ្តុះបណ្តាល ឬចូលរួមប្រជុំ ជាដើម។* ប្រធានភូមិជ័យជំនះ ខេត្តកំពង់ធំ។

ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីផ្សេងទៀត វាច្បាស់ណាស់ថា ការផ្សព្វផ្សាយព័ត៌មានអាហារូបត្ថម្ភ មិនត្រូវបានចាត់ទុកថា ជាអាទិភាព ឬជាកត្តាសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀងនោះទេ។ នៅពេលសាកសួរឱ្យរៀបរាប់អំពីលក្ខណៈ និងការផ្តោតលើការងាររបស់ពួកគេទាក់ទងនឹងអាហារូបត្ថម្ភ អ្នកចូលរួមឆ្លើយសំណួរមួយចំនួនបានឆ្លើយដូច្នេះថា៖

*ខាងឃុំបានសហការជាមួយខាងសាលារៀន និងនាយកសាលា ដើម្បីផ្សព្វផ្សាយការយល់ដឹង និងអប់រំសិស្សានុសិស្ស អំពីសុវត្ថិភាពចំណីអាហារ សុខភាព អនាម័យ និងបរិស្ថាន។ ជាងនេះទៅទៀត ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាទាំងនេះ ក៏ត្រូវបានលើកយកមកពិភាក្សា និងផ្សព្វផ្សាយក្នុងវេទិកាសាធារណៈ ការប្រជុំភូមិ និងការបណ្តុះបណ្តាលផងដែរ។* KII មេឃុំកំពង់រាប ខេត្តតាកែវ។

*ប្រធានភូមិធ្លាប់បានចូលរួមក្នុងការងារទាក់ទងនឹងសេវាផ្សព្វផ្សាយអំពីកសិកម្ម ដែលរៀបចំដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាល។ ប្រធានបទសំខាន់ៗនៃការពិភាក្សានោះ រួមមានបច្ចេកទេសកសិកម្ម ការដាំដុះស្រូវ និងគ្រាប់ពូជដែលធន់ទ្រាំ។* KII អនុប្រធានភូមិ នៅភូមិសំណាកខេត្តកំពង់ធំ។

អ្នកចូលរួមឆ្លើយសំណួរម្នាក់ទៀតពន្យល់ថា អាហារូបត្ថម្ភ គឺជាការមានអាហារហូបចុកគ្រប់គ្រាន់ ប៉ុន្តែការទទួលបានដីធ្លី ក៏មានសារៈសំខាន់ដូចគ្នាដែរ ដោយសារវាអាចធានាថាស្បៀងអាហារអាចដាំដុះបាន ដើម្បីបំពេញតម្រូវការអាហារូបត្ថម្ភ ហើយជួយទ្រទ្រង់ដល់ជីវភាពគ្រួសារផងដែរ។

នៅថ្នាក់ខេត្ត មានភាពខុសប្លែកគ្នា គួរឱ្យកត់សម្គាល់ពីរបៀបដែលស្ថាប័ននានាបានព្យាយាមដោះស្រាយ និងផ្តល់អាទិភាពលើបញ្ហាអាហារូបត្ថម្ភ ក្នុងវិសាលភាពធំទូលាយនៃសកម្មភាពការងាររបស់ពួកគេ។ ជាឧទាហរណ៍ មន្ទីរបរិស្ថានខេត្តកំពង់ធំ បានបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការផ្សព្វផ្សាយព័ត៌មានអាហារូបត្ថម្ភ និងរៀបចំកម្មវិធីដែលផ្តោតលើអាហារូបត្ថម្ភ ចំណែកមន្ទីរបរិស្ថានក្នុងខេត្តតាកែវវិញ មិនបានដាក់បញ្ចូលកិច្ចការអាហារូបត្ថម្ភ ឬការរៀបចំផែនការអាហារូបត្ថម្ភ ទៅក្នុងការងាររបស់ខ្លួនជាចម្បងទេ ដោយសារមន្ទីរផ្តោតការងារសំខាន់លើបញ្ហាទាក់ទងនឹងប្រព័ន្ធអេកូឡូស៊ី និងការការពារ និងអភិរក្សបរិស្ថាន៖

*មន្ទីរបរិស្ថានខេត្ត បានធ្វើការងារផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋាន រួមទាំង អាហារូបត្ថម្ភដល់សហគមន៍ផងដែរ។ យើងមានការិយាល័យអប់រំផ្សព្វផ្សាយ ដែលទទួលខុសត្រូវក្នុងការផ្សព្វផ្សាយចំណេះដឹង និងការលើកកម្ពស់ការយល់ដឹងសម្រាប់មាតា និងកុមារ ឱ្យមានការយល់ដឹងអំពីអាហារូបត្ថម្ភ។* KII អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំ។

*មន្ទីរបរិស្ថានខេត្ត ធ្វើការតែទៅលើបញ្ហាទាក់ទងនឹងបរិស្ថាន និងការការពារតំបន់អភិរក្សតែប៉ុណ្ណោះ។ មន្ទីរបានចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន តាមរយៈការជួយដាំដុះស្បៀងអាហារក្នុងតំបន់ការពារ (...) ការប្រជុំ ឬសិក្ខាសាលានានា ភាគច្រើនទាក់ទងនឹងបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីស្បៀងអាហារ។* KII អនុប្រធានមន្ទីរបរិស្ថានខេត្តតាកែវ។

ដូចគ្នានេះដែរ ការិយាល័យនៃមន្ទីរកសិកម្មខេត្ត នៅតាមទីតាំងដែលបានធ្វើការសិក្សានេះ មានវិធីសាស្ត្រផ្ទុយគ្នាក្នុងការកែលម្អស្ថានភាពសន្តិសុខស្បៀងក្នុងខេត្តរៀងៗខ្លួន។ ក្នុងខេត្តកំពង់ធំ ការពង្រឹងការយល់ដឹងអំពីអាហារូបត្ថម្ភ គឺជាសមាសភាគដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់ការិយាល័យខ្លួន ក្នុងការលើកកម្ពស់សន្តិសុខស្បៀងអាហារ ចំណែកនៅការិយាល័យខេត្តតាកែវវិញ ការដាក់បញ្ចូលផែនការអាហារូបត្ថម្ភទៅក្នុងការងាររបស់ខ្លួន ហាក់ដូចជាមិនត្រូវបានចាត់ទុកថាជាអាទិភាព សម្រាប់ការសម្រេចបាននូវគោលដៅស្រដៀងគ្នានោះទេ ទោះបីជាមានតម្រូវការជាក់ស្តែង និងឱកាសចំពោះការងារបែបនេះក្តី។ នេះសបញ្ជាក់ឱ្យឃើញពីភាពមិនស៊ីសង្វាក់គ្នា មិនត្រឹមតែនៅក្នុងរបៀបដែលរចនាសម្ព័ន្ធរដ្ឋាភិបាលក្នុងតំបន់ដោះស្រាយបញ្ហាសន្តិសុខស្បៀង និងការផ្សព្វផ្សាយព័ត៌មានអាហារូបត្ថម្ភប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរវាងគោលនយោបាយ និងគោលបំណងរបស់រដ្ឋាភិបាលផងដែរ (ដូចមានចែងក្នុងយុទ្ធសាស្ត្រ NSFSN) និងសកម្មភាពដែលកំពុងអនុវត្តផ្ទាល់នៅថ្នាក់ខេត្ត៖

*មន្ទីរកំពុងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជនក្នុងតំបន់ស្តីពីសន្តិសុខស្បៀងអាហារូបត្ថម្ភរបស់កុមារ និងនិរន្តរ៍ស្បៀងភាពអាហារ។ ដៃគូទាំងនោះរួមមាន AFD, World Vision, WCF, World Fish និងច្រើនទៀត។* KII អនុប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ។

*មន្ទីរកសិកម្មកំពុងធ្វើការលើ គោលនយោបាយយុទ្ធសាស្ត្រ ដែលធានាសន្តិសុខស្បៀង និងសុវត្ថិភាពចំណីអាហារសម្រាប់ខេត្តផ្ទាល់។ ការិយាល័យផ្សព្វផ្សាយកសិកម្ម ដើរតួជាអ្នកសម្របសម្រួល ក្នុងការបង្កើតសហគមន៍កសិកម្ម (...) ការងារតែមួយគត់លើអាហារូបត្ថម្ភដែលមន្ទីរកសិកម្មអាចធ្វើបាន គឺការរៀបចំវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាលើកកម្ពស់ការយល់ដឹងអំពីអាហារូបត្ថម្ភ។* KII នាយខណ្ឌរដ្ឋបាលជលផល មន្ទីរកសិកម្មខេត្តតាកែវ។

អ្នកចូលរួមឆ្លើយសំណួរមកពីខេត្តតាកែវបានបន្ថែមថា វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពីអាហារូបត្ថម្ភ ដែលរៀបចំដោយមន្ទីរកសិកម្ម បានលើកឡើងជាប្រចាំនូវបញ្ហាយេនឌ័រ សិទ្ធិស្ត្រី ពលកម្មកុមារ និងអំពើហិង្សាក្នុងគ្រួសារ។ ទោះបីជាស្ថាប័នរដ្ឋាភិបាល មានភាពខុសប្លែកគ្នានៅក្នុងការផ្តោតការងារ និងអាទិភាពនៅទូទាំងខេត្ត ដូចដែលបានបង្ហាញនៅខាងលើក៏ដោយ ក៏បញ្ហាទូទៅនៅក្នុងវិធីសាស្ត្ររបស់ស្ថាប័ន គឺការសង្កត់ធ្ងន់លើចំណុចប្រសព្វនៃសន្តិសុខស្បៀង និងការផ្សព្វផ្សាយ និងលើកកម្ពស់សិទ្ធិរបស់ក្រុមងាយរងគ្រោះ ឬក្រុមដែលជួបការលំបាក។

## ៤.៣ ការចំណាយ និងស្បៀងអាហារ

ទាំងនៅទីតាំងគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង និងស្រះដម្រកត្រីសហគមន៍បឹងរៀម អាទិភាពចំណាយរបស់អ្នកចូលរួម ឆ្លើយត្រូវស្របគ្នាច្រើន គឺលើម្ហូបអាហារ ការសិក្សារបស់កូនៗ និងថ្លៃព្យាបាលជំងឺ។ ស្បៀងអាហារត្រូវបានចាត់ថ្នាក់ជាទូទៅថាជាអាទិភាពទីមួយ ដោយឆ្លុះបញ្ចាំងពីតួនាទីជាមូលដ្ឋានក្នុងជីវិតប្រចាំថ្ងៃ ហើយការសម្រេចចិត្តលើការទិញម្ហូបអាហារ ជាធម្មតាត្រូវបានធ្វើឡើងជាសមូហភាពក្នុងគ្រួសារតាមចំណង់ចំណូលចិត្ត ក៏ដូចជាតាមលទ្ធភាពថវិកាដែលមាន។ មេគ្រួសារ ជាពិសេសស្ត្រី តែងតែសម្រេចចិត្តដោយឯករាជ្យទាក់ទងនឹងការទិញស្បៀងអាហារ និងការរៀបចំម្ហូបអាហារ។ នៅក្នុងគ្រួសារខ្លះ ប្តីជាអ្នករកប្រាក់ចំណូលចម្បង មានឥទ្ធិពលយ៉ាងខ្លាំងលើការសម្រេចចិត្តទិញចំណីអាហារ ដែលជាការរួមចំណែកដល់អំណាចគ្រប់គ្រងសេដ្ឋកិច្ចរបស់គ្រួសារ។

> *គ្រួសាររបស់ខ្ញុំ ទិញម្ហូបអាហារ អាស្រ័យលើអ្វីដែលកូនរបស់ខ្ញុំ ចូលចិត្តញ៉ាំ និងអ្វីដែលស្វាមីខ្ញុំចង់បាន ពីព្រោះគាត់ត្រូវការថាមពល ដើម្បីធ្វើការងារ ដូច្នេះគាត់ត្រូវញ៉ាំអាហារដែលអាចទ្រទ្រង់កម្លាំងរបស់គាត់។* FGD ក្រុមស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកញ្ចិល ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

> *ឪពុក ប្តី និងកូនៗរបស់ខ្ញុំ មានចំណូលចិត្តអាហារខុសៗគ្នា ដូច្នេះភាគច្រើន ខ្ញុំធ្វើម្ហូបណាដែលគ្រប់គ្នាអាចញ៉ាំបាន។ ប៉ុន្តែពេលយើងមិនមានលុយគ្រប់គ្រាន់ ខ្ញុំធ្វើម្ហូបតាមអ្វីដែលយើងមាន ហើយឱ្យពួកគាត់បានញ៉ាំ ទោះបីមិនសូវចូលចិត្តក៏ដោយ។* FGD ក្រុមស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកញ្ចិល ឃុំកំពង់រាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។

នៅទីតាំងទាំងពីរ អ្នកចូលរួមឆ្លើយសំណួរទាំងអស់ បានឱ្យដឹងថា ការទិញស្បៀងអាហារចម្បងរបស់ពួកគេសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ រួមមាន អង្ករ ត្រី សាច់ បន្លែបង្ការ និងគ្រឿងទេសសម្រាប់ចម្អិនអាហារ។ ក្រុមអ្នកឆ្លើយសំណួរមួយចំនួនបានលើកឡើងពីសារៈសំខាន់នៃប្រភេទចំណីអាហារ ការគិតគូរពីសុខភាព និងការសម្រេចចិត្តទិញចំណីអាហារណាដែលគ្មានគីមីគ្រោះថ្នាក់ដល់សុខភាព។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេមិនសូវជាបានលើកឡើងពីចំណូលចិត្តគ្រួសារ និងភាពអាចរកបានផ្នែកហិរញ្ញវត្ថុ ដែលជាកត្តាចម្បងជះឥទ្ធិពលលើការស្បៀងអាហារ ការគិតគូរពីប្រភេទអាហារ និងកត្តាសុខភាព។

> *ពេលសម្រេចចិត្តធ្វើម្ហូបម្តងៗ ខ្ញុំត្រូវរកនឹកថាតើគួរចំណាយលុយប៉ុន្មាន? បើមានលុយតិច ខ្ញុំគ្រាន់តែធ្វើម្ហូបណាដែលយើងមានស្រាប់។* FGD ស្ត្រីដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិសំណាក ឃុំកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

> *ប្តីខ្ញុំធ្វើការហត់នឿយណាស់។ គាត់ចូលចិត្តអាហារខ្លះ ដូចជា ស៊ុបជាមួយសាច់ និងបន្លែ ជាជាងអាហារក្រៀមក្រោះ ព្រោះវាជួយបង្កើនថាមពល និងជួយឱ្យគាត់មានកម្លាំង អាចបន្តធ្វើការងារបាន។ ដូច្នេះ ភាគច្រើននៅពេលខ្ញុំធ្វើម្ហូបម្តងៗ ខ្ញុំគិតពីគាត់មុនគេ ដោយសារគាត់ត្រូវការថាមពលបន្ថែមពីម្ហូបអាហារដើម្បីធ្វើការ និងរកប្រាក់។* FGD ស្ត្រីដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិសំណាក ឃុំកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

ថ្លៃសិក្សា និងថ្លៃព្យាបាលជំងឺរបស់កូនៗ ត្រូវបានចាត់ថ្នាក់ជាការចំណាយធំបំផុតទីពីរ បន្ទាប់ពីស្បៀងអាហារ។ អាទិភាពនៃការចំណាយបន្ថែម ដូចជាការដឹកជញ្ជូន ធាតុចូលកសិកម្ម ថ្លៃទឹក និងថ្លៃអគ្គិសនី ក៏ត្រូវបានលើកឡើងផងដែរ ហើយមានទំហំចំណាយខុសៗគ្នាក្នុងចំណោមអ្នកចូលរួមឆ្លើយសំណួរ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺប្រាក់កម្ចីធនាគារ ក៏ជាអាទិភាពមួយក្នុងការចំណាយផងដែរ ដោយបង្ហាញឱ្យឃើញពីកាតព្វកិច្ចហិរញ្ញវត្ថុរបស់គ្រួសារទាំងនេះ។ សរុបមក ទោះបីជាមានភាពខុសប្លែកគ្នាក្នុងអាទិភាពចំណាយជាក់លាក់ខ្លះក៏ដោយ ទុក្ខកង្វល់ធំៗរបស់គ្រួសារនីមួយៗដែលកំពុងរស់នៅទីតាំងសិក្សាទាំងពីរនេះគឺ បញ្ហាស្បៀងអាហារ និងការសិក្សារបស់កូនៗ។

## ៤.៤ ផលិតកម្មស្បៀងអាហារ

គ្រួសារភាគច្រើន ប្រកបរបរចិញ្ចឹមជីវិតដែលពឹងអាស្រ័យលើកសិកម្ម ដូចជាការដាំដំណាំស្រូវ និងបន្លែបង្ការជាដើម។ ឧបសគ្គចំពោះការផលិតស្បៀងរួមមាន កង្វះលទ្ធភាពទទួលបានដី និងទឹក ការប្រែប្រួលអាកាសធាតុ និងកង្វះសេវាផ្សព្វផ្សាយ។ នៅក្នុងទីតាំងទាំងពីរដែលបានសិក្សា ភាគច្រើននៃអ្នកចូលរួមឆ្លើយសំណួរ ជាពិសេសស្ត្រីមេគ្រួសារ និងស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ មិនបានប្រកបរបរធ្វើស្រែចម្ការទេ ដោយសារខ្វះដីដាំដុះ។ ផ្ទុយទៅវិញ ពួកគេបានផ្តោតលើការដាំបន្លែបង្ការនៅជុំវិញផ្ទះ និងការចិញ្ចឹមសត្វស្រុក ដែលជាប្រភេទសកម្មភាពត្រូវការកន្លែងតូចល្មម និងធនធានតិចតួច។ បុគ្គលមួយចំនួនតូច រួមទាំងស្ត្រីមេគ្រួសារ និងបុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ ដែលមានកម្មសិទ្ធិដីធ្វើស្រែចម្ការតិចតួចនៅជិតភូមិ បានប្រកបរបរធ្វើស្រែចម្ការ។ បុគ្គលមួយចំនួននៅក្នុងទីតាំងទាំងពីរនេះ ជាពិសេសនៅខេត្តតាកែវ និងខេត្តកំពង់ធំ ក៏បានប្រកបរបរធ្វើស្រែចម្ការ និងចម្ការស្វាយចន្ទីផងដែរ ដោយសារពួកគាត់មានដីធ្វើស្រែចម្ការក្បែរភូមិ។ សរុបមក ដោយសារតែការធ្វើស្រែចម្ការនៅមានកម្រិត ព្រោះខ្វះដីដាំដុះ ទើបការដាំបន្លែបង្ការ និងការចិញ្ចឹមសត្វ បានលេចចេញជាសកម្មភាពកសិកម្មពេញនិយមក្នុងចំណោមក្រុមអ្នកចូលរួមឆ្លើយសំណួរទាំងនោះ។

ទីតាំងសិក្សាទាំងពីរនេះ បានជួបនឹងឧបសគ្គក្នុងការផលិតស្បៀងអាហារ ដោយសារកត្តាផ្សេងៗ។ អវត្តមាននៃបុរសពេញវ័យនៅក្នុងគ្រួសារ ជាពិសេស មនុស្សវ័យចំណាស់ បានរួមចំណែកដល់បញ្ហាប្រឈមក្នុងការផលិតស្បៀង ជាពិសេស សម្រាប់ស្ត្រីដែលជាមេគ្រួសារតែម្តង។

*ស្ត្រីមេគ្រួសារមានឧបសគ្គច្រើន ពីព្រោះពួកគេត្រូវធ្វើស្រែចម្ការដោយខ្លួនឯង ហើយចំណាយកម្លាំងពលកម្មច្រើនហួសប្រមាណ ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់ពួកគាត់ និងត្រូវបញ្ចេញថាមពលច្រើន ទៅលើទំនួលខុសត្រូវដែលមានស្រាប់ ក្នុងការថែរក្សាក្រុមគ្រួសាររបស់ពួកគាត់។* KII សមាជិកក្រុមប្រឹក្សាឃុំកោះ គណៈកម្មការស្រះជម្រកត្រីសហគមន៍បឹងរៀម ប្រធានគណៈកម្មការនៃ សហគមន៍កសិករអ្នកប្រើប្រាស់ទឹក តាំងក្រសាំង ក្នុងខេត្តកំពង់ធំ។

*ស្ត្រីទាំងនោះ (ឧទាហរណ៍ ស្ត្រីដែលជាមេគ្រួសារ) ត្រូវដើរតួនាទីជា ម្តាយផង និងជាឪពុកផង ក្នុងពេលតែមួយ។ ពួកគាត់ត្រូវពឹងលើខ្លួនឯង ដើម្បីចិញ្ចឹមបីបាច់កូនៗរបស់ខ្លួន។ជួនកាល ពួកគាត់មិនអាចបញ្ជូនកូនទៅសាលារៀនបានទេ ដោយសារជីវភាពក្រីក្រ និងត្រូវខិតខំរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។ ស្ត្រីខ្លះទៀត ត្រូវនាំកូនៗទៅធ្វើការជាមួយដែរ ដូច្នេះពួកគាត់អាចធ្វើការផង និងអាចមើលថែកូនៗក្នុងពេលតែមួយបាន។* KII សមាជិកក្រុមប្រឹក្សាឃុំកកោះ ខេត្តកំពង់ធំ។

លើសពីនេះ ធាតុចូលកសិកម្មដូចជា ជី គ្រាប់ពូជ និងកម្លាំងពលកម្ម ត្រូវបានកត់សម្គាល់ឃើញថាមានតម្លៃថ្លៃបង្កជាឧបសគ្គផ្នែកហិរញ្ញវត្ថុយ៉ាងធំ ដែលប៉ះពាល់ជាវិសមាមាត្រដល់ស្ត្រីមេគ្រួសារ និងស្ត្រីក្រីក្រ។ ថ្វីបើមានការកើនឡើងនៃតម្លៃធាតុចូលកសិកម្មក៏ដោយ ក្រុមអ្នកឆ្លើយសំណួរបានឱ្យដឹងពីការធ្លាក់ចុះនៃទិន្នផលកសិកម្ម និងតម្លៃទីផ្សារទាប ដែលធ្វើឱ្យបញ្ហាប្រឈមនៃផលិតកម្មស្បៀងកាន់តែធ្ងន់ធ្ងរឡើង។

*ប្រជាជននៅក្នុងសហគមន៍ភាគច្រើន គឺពឹងអាស្រ័យលើរបរកសិកម្ម។ ស្ទើរតែ ៧០% នៃប្រជាជនដែលបង្កបង្កើនផលស្រូវ នៅជិតប្រភពទឹក... បញ្ហាប្រឈមសម្រាប់ស្រះជម្រកត្រីរបស់សហគមន៍នាពេលបច្ចុប្បន្ននេះ គឺកសិករចាប់ផ្តើមដាំដុះស្រូវកាន់តែច្រើននៅរដូវប្រាំង ដោយពួកគាត់បូមទឹកចេញពីបឹងមកស្រោចស្រព។ ទន្ទឹមនឹងនេះ កសិករមានការចំណាយកាន់តែច្រើន ជាពិសេស ស្ត្រីដែលត្រូវថែទាំគ្រួសារ ផ្ទះសម្បែង កូនៗ និងម្ហូបអាហារ។* KII អនុប្រធានគណៈកម្មការស្រះជម្រកត្រីសហគមន៍បឹងរៀម ក្នុងខេត្តកំពង់ធំ។

ទោះបីជាប្រឈមមុខនឹងបញ្ហាទាំងនេះយ៉ាងណាក្តី ក៏ក្រុមអ្នកចូលរួមឆ្លើយសំណួរទាំងនេះបានសង្កត់ធ្ងន់ មិនត្រឹមតែទៅលើកម្រិតខ្ពស់នៃការចូលរួមរបស់ស្ត្រី ក្នុងដំណើរការផលិតស្បៀងអាហារប៉ុណ្ណោះទេ ថែមទាំងទៅលើការគ្រប់គ្រងធនធាន និងកិច្ចការជួយសហគមន៍ ដោយបង្ហាញពីការរួមចំណែកដ៏សំខាន់របស់ពួកគេ ចំពោះសន្តិសុខស្បៀង និងសុខុមាលភាពសហគមន៍ទាំងមូល។ ចំណុចនេះត្រូវបានរំលេចនៅក្នុងការលើកឡើងដូចខាងក្រោម៖

*យើងខ្ញុំបានលើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រី ហើយខ្ញុំបានកត់សម្គាល់ឃើញ ការចូលរួមក្នុងចំណោមស្ត្រីទាំងឡាយ មានការកើនឡើង ជាពិសេស នៅក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងផ្សេងៗ ស្របពេលដែលបុ*

*រសៗ ចូលរួមក្នុងការងារចុះល្បាត។ ខ្ញុំជឿថា ទាំងស្ត្រី និងបុរស មានលទ្ធភាពទទួលបានធនធានជលផលស្មើៗគ្នា ដោយសារពួកគាត់អាចរកត្រីបានយ៉ាងងាយ នៅតាមវាលស្រែរបស់ពួកគាត់។* KII នាយខណ្ឌរដ្ឋបាលជលផល ខេត្តកំពង់ធំ។

*(...) ស្ត្រីមានភាពសកម្មខ្លាំងណាស់ ក្នុងការចូលរួមក្នុងការគ្រប់គ្រងធនធានទឹក មិនត្រឹមតែក្នុងគ្រាលំបាក ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងជីវភាពប្រចាំថ្ងៃយ៉ាងទៀងទាត់ផងដែរ។* KII ប្រធានការិយាល័យស្រុកនៃមន្ទីរធនធានទឹក និងឧតុនិយមខេត្តតាកែវ។

ការប្រែប្រួលអាកាសធាតុ រួមទាំង ការផ្លាស់ប្តូរលំនាំអាកាសធាតុ ការកើនឡើងសីតុណ្ហភាព និងគ្រោះរាំងស្ងួត កំពុងបង្កើតបញ្ហាប្រឈមយ៉ាងសំខាន់ ចំពោះការធ្វើកសិកម្ម និងការចិញ្ចឹមសត្វក្នុងស្រុក ក្នុងចំណោមគ្រប់ក្រុមអ្នកចូលរួមឆ្លើយសំណួរទាំងអស់ ដែលហាក់កាន់តែធ្ងន់ធ្ងរទៅៗ ដោយសារកង្វះការផ្សព្វផ្សាយ និងជំនួយបច្ចេកទេសមិនគ្រប់គ្រាន់។ ទីតាំងដីស្រែចម្ការ ដែលនៅឆ្ងាយពីហេដ្ឋារចនាសម្ព័ន្ធទឹក បង្កជាឧបសគ្គបន្ថែមទៀត ដល់ការផលិតស្បៀងសម្រាប់កសិករគ្រប់រូប ដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់ពួកគេ។ បញ្ហាប្រឈមនេះ ត្រូវបានទទួលរងជាពិសេសដោយស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅជុំវិញគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង និងបុរស និងស្ត្រីដែលមិនស្ថិតក្នុងភាពក្រីក្រ កំពុងរស់នៅតំបន់ទាំងពីរ។ ប្រជាជនភាគច្រើនដែលរស់នៅជុំវិញជម្រកស្រះត្រីសហគមន៍ ពឹងអាស្រ័យលើរបរកសិកម្ម សម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគេ៖ ការកើនឡើងតម្លៃស្រូវ បានធ្វើឱ្យមានការប្រកួតប្រជែងដើម្បីទទួលបានទឹកប្រើប្រាស់។ ស្របពេលដែលកសិករជាច្រើន ទទួលបានអត្ថប្រយោជន៍ពី សហគមន៍កសិករអ្នកប្រើប្រាស់ទឹក អ្នកដែលរស់នៅឆ្ងាយពីប្រភពទឹក បានងាកទៅបូមទឹកប្រើប្រាស់ចេញពីស្រះជម្រកត្រីសហគមន៍ ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានជលផលទៅវិញ។ លើសពីនេះ ប្រជាពលរដ្ឋដែលរស់នៅឆ្ងាយពីប្រព័ន្ធធារាសាស្ត្រ ត្រូវចំណាយបន្ថែមលើការទិញប្រេងសាំងសម្រាប់ម៉ាស៊ីនបូមទឹក ដើម្បីបូមទឹកចូលស្រែរបស់ពួកគេ។

*ប្រជាពលរដ្ឋនៅឃុំកកោះ និងសហគមន៍ទាំងមូល ពឹងអាស្រ័យលើការដាំដុះស្រូវ សម្រាប់ចិញ្ចឹមជីវិត។ បញ្ហាប្រឈមចម្បងសម្រាប់កសិករក្នុងសហគមន៍ គឺការបូមទឹកដែលដាក់ស្រែដែលនៅឆ្ងាយពីប្រព័ន្ធធារាសាស្ត្រ។ បច្ចុប្បន្ននេះ មានការព្រួយបារម្ភអំពីលទ្ធភាពទទួលបានទឹកសម្រាប់កសិករធ្វើស្រែចម្ការក្នុងរដូវប្រាំង។ នៅពេលមានឧបសគ្គបែបនេះ ប្រជាសហគមន៍ បានសហការជាមួយអាជ្ញាធរមូលដ្ឋាន មេឃុំ និងប្រធានភូមិ ដើម្បីដោះស្រាយបញ្ហាដែលបានកើតឡើង។* KII សមាជិកក្រុមប្រឹក្សាឃុំកកោះ ខេត្តកំពង់ធំ។

*ប្រជាកសិករដែលមានស្រែ ឬចម្ការ នៅឆ្ងាយពីប្រភពទឹក អាចប្រឈមនឹងការចំណាយច្រើន លើប្រព័ន្ធស្រោចស្រព។* KII ប្រធានការិយាល័យស្រុក ការិយាល័យកសិកម្មស្រុក ធនធានទឹក និងធនធានធម្មជាតិ ខេត្តកំពង់ធំ។

*ឧបសគ្គសម្រាប់កសិករនាពេលបច្ចុប្បន្ន គឺថ្លៃដើមខ្ពស់សម្រាប់ជី ថ្នាំសម្លាប់សត្វល្អិត កម្លាំងពលកម្ម និងសម្ភារៈប្រើប្រាស់។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បានបង្កជាជំងឺលើផលដំណាំ កង្វះចំណេះដឹងផ្នែកបច្ចេកទេសកសិកម្ម និងការប្រែប្រួលតម្លៃទីផ្សារ។ ម្យ៉ាងវិញទៀត កសិករដែលមានស្រែចម្ការនៅឆ្ងាយពីប្រព័ន្ធធារាសាស្ត្រ ជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនក្នុងការចែកចាយទឹក និងចំណាយច្រើនលើធាតុចូល ដើម្បីស្រោចស្រពស្រែចម្ការរបស់ពួកគេ។* KII អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ។

*ឧបសគ្គទូទៅបំផុតរបស់ប្រជាកសិករចំពោះការងារកសិកម្ម គឺតម្លៃជី និងប្រេងសាំងខ្ពស់។ ការលំបាកក្នុងការទទួលបានប្រភពទឹក ក៏ត្រូវបានចាត់ទុកថា ជាឧបសគ្គសម្រាប់កសិករទាំងនោះ ដែលរស់នៅឆ្ងាយពីប្រភពទឹកផងដែរ។ ការបែងចែកកម្លាំងពលកម្មក្នុងភូមិ ក៏ហាក់មានការលំបាក សម្រាប់គ្រួសារតូចៗ ដែលសមាជិកធ្វើចំណាកស្រុក។* KII ប្រធានភូមិនៅទីតាំងគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង ខេត្តតាកែវ។

ទីតាំងទាំងពីរនេះ ទទួលបានគម្រោងវិនិយោគដែលផ្តោតជាចម្បងលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ ជាដើម។ ការវិនិយោគទាំងនេះ ដែលជាផ្នែកនៃផែនការអភិវឌ្ឍន៍ឃុំ ក្នុងគោលបំណងពង្រឹងការតភ្ជាប់ និងជំរុញសមត្ថភាពផលិតកម្មស្បៀង ដោយផ្តោតជាពិសេសលើការធ្វើស្រែប្រាំង។ ការបង្កើតប្រព័ន្ធធារាសាស្ត្រ និងការចែកចាយគ្រាប់ពូជស្រូវ គឺជាសកម្មភាពសំខាន់ដែលរួមចំណែកដល់ការបង្កើនសមត្ថភាពផលិតស្បៀង។ ទោះជាយ៉ាងណាក៏ដោយ គេបានកត់សម្គាល់ឃើញថា ការវិនិយោគទាំងនេះ នៅមានការខ្វះខាតជាក់ស្តែង

លើការលើកកម្ពស់ការផ្សព្វផ្សាយ ឬការយល់ដឹងអំពីអាហារូបត្ថម្ភ។ ទោះបីជាមានការយកចិត្តទុកដាក់ទៅលើការកែលម្អផលិតកម្មស្បៀង តាមរយៈការវិនិយោគហេដ្ឋារចនាសម្ព័ន្ធក៏ដោយ ក៏នៅតែមានគម្លាតក្នុងការដោះស្រាយបញ្ហាអាហារូបត្ថម្ភ សន្តិសុខស្បៀង និងសុខុមាលភាពនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំដែរ។

*ក្រុមប្រឹក្សាស្រុក សង្កត់ធ្ងន់ទៅលើសារៈសំខាន់សំខាន់នៃការចែករំលែកព័ត៌មាន ទាក់ទងនឹងការអនុវត្តគម្រោងនានាចេញពីមន្ទីរពាក់ព័ន្ធក្នុងខេត្តទាំងមូល។ ចំណុចនេះមានសារៈសំខាន់ជាពិសេស ចំពោះវិមជ្ឈការនាពេលថ្មីៗនេះ នៅតាមការិយាល័យជំនាញ ដែលបច្ចុប្បន្នស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋបាលស្រុក-ខណ្ឌ និងក្រសួងមហាផ្ទៃ។ ចាប់តាំងពីមានការរៀបចំរចនាសម្ព័ន្ធនេះឡើងវិញ ការិយាល័យជំនាញ បានសង្កេតឃើញពីការថយចុះនៃសកម្មភាព និងការចូលរួមក្នុងការអភិវឌ្ឍគម្រោងនានា។ ដូច្នេះ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងការផ្លាស់ប្តូរព័ត៌មាន ពិតជាមានសារៈសំខាន់ណាស់ ដើម្បីធានាថាការិយាល័យជំនាញនៅតែទទួលបានព័ត៌មាន និងអាចរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការអភិវឌ្ឍគម្រោងទាំងនេះ។* KII ប្រធានការិយាល័យកសិកម្មស្រុក ធនធានធម្មជាតិ និងបរិស្ថាន ខេត្តតាកែវ។

បញ្ហាប្រឈមដែលក្រុមអ្នកចូលរួមឆ្លើយសំណួរបានជួបប្រទះ ជាពិសេស សម្រាប់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងគ្រួសារដែលស្ថិតក្នុងគ្រួសារក្រីក្រ គឺការចិញ្ចឹមសត្វស្រុក និងការដាំបន្លែបង្ការជុំវិញផ្ទះ ទាំងកង្វះព័ត៌មានផ្សព្វផ្សាយ និងការណែនាំបច្ចេកទេសមិនគ្រប់គ្រាន់។

*ពួកយើង [គ្រួសារ] ចិញ្ចឹមសត្វដោយផ្អែកលើអ្វីដែលយើងធ្លាប់យល់ដឹង ដោយគ្មានជំនួយបច្ចេកទេស ឬការបណ្តុះបណ្តាលចំណេះដឹងណាមួយឡើយ។ នៅពេលដែលសត្វឈឺ ខ្ញុំមិនប្រាកដថាត្រូវព្យាបាលពួកវាដោយរបៀបណាទេ ដូច្នេះខ្ញុំតែងតែទុកពួកវាចោលអញ្ចឹងទៅ ហើយជាអកុសល ពេលខ្លះពួកវាក៏ងាប់បាត់ទៅ។* FGD ស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិជ័យជំនះ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

*មានបញ្ហាប្រឈមច្រើនក្នុងការចិញ្ចឹមសត្វស្រុក ដោយសារតែខ្វះដីធំទូលាយ និងទីជម្រកសមរម្យសម្រាប់ពួកវា។ សត្វចិញ្ចឹមទាំងនេះ ដើររកចំណីស៊ីដោយខ្លួនឯង ព្រោះខ្ញុំមិនមានពេលមើលថែពួកវាទេវា ខណៈដែលខ្ញុំត្រូវការរកប្រាក់កម្រៃផ្គត់ផ្គង់គ្រួសារ។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិជ័យជំនះ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

*ជួនកាល កើតមានជំងឺលើបន្លែដែលយើងដាំនៅជុំវិញផ្ទះ ហើយខ្ញុំមិនប្រាកដថា ត្រូវដោះស្រាយដោយរបៀបណាទេ ដូច្នេះខ្ញុំមានតែទុកចោលអញ្ចឹងទៅ។* FGD ស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិជ័យជំនះ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

## ៤.៥. ការចាត់ចែងស្បៀងអាហារក្នុងគ្រាខ្វះខាត និងផលប៉ះពាល់នៃផលិតកម្មស្បៀងអាហារ

នៅក្នុងតំបន់សិក្សាទាំងពីរនេះ គ្រួសារទាំងឡាយបានអនុវត្តតាមយុទ្ធសាស្ត្រជាច្រើន ដើម្បីទប់ទល់ក្នុងគ្រាដែលរកប្រាក់ចំណូលបានតិចតួច។ ដំណោះស្រាយផ្អែកលើសេដ្ឋកិច្ចគ្រួសារ គឺជារឿងធម្មតា ដោយមានបុគ្គលជាច្រើនបានសុំខ្ចីលុយពីសាច់ញាតិ អ្នកជិតខាង និងមិត្តភក្តិ ហើយអ្នកខ្លះទៀតថែមទាំងងាកទៅរកកម្ចីពីធនាគារទៀតផង។ ដំណោះស្រាយផ្អែកលើចំណីអាហារ ក៏មានប្រភេទឡង់ច្រើនផងដែរ ដោយក្រុមអ្នកចូលរួមឆ្លើយសំណួរទាំងអស់បានឱ្យដឹងពីការថយចុះទាំងបរិមាណ និងគុណភាពនៃចំណីអាហារដែលត្រូវបរិភោគ ដោយអាស្រ័យលើចំណីអាហារដែលមិនសូវមានជីវជាតិច្រើន ដែលមានជាតិខ្លាញ់ ស្ករ និងប្រេងខ្លាំង ដែលមិនល្អសម្រាប់សុខភាព ហើយមានតម្លៃថោកក៏ពិតមែន ប៉ុន្តែវាមានផលប៉ះពាល់យ៉ាងខ្លាំងដល់របបអាហារនៃសមាជិកទាំងអស់ក្នុងគ្រួសារ។

ក្រុមអ្នកចូលរួមឆ្លើយសំណួរនៅទីតាំងសិក្សាទាំងពីរនេះ ក៏បានឱ្យដឹងផងដែរ អំពីដំណោះស្រាយផ្អែកលើជីវភាពគ្រួសារ ដូចជាការកាត់បន្ថយការចំណាយដែលមិនចាំបាច់ និងការផ្លាស់ប្តូរទៅរកអាជីពផ្សេងៗទៀត។ ជាឧទាហរណ៍ បុគ្គលមួយចំនួន ក្នុងនោះភាគច្រើនជាស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ បានចុះទៅនេសាទត្រី បើទោះបីវាមិនមែនជាទម្លាប់របស់ពួកគេក៏ដោយ។ បុរសមួយចំនួនដែលស្ថិតក្នុងគ្រួសារក្រីក្រ ដែលរស់នៅជុំវិញប្រព័ន្ធធារាសាស្ត្រតាសួង ក៏បានចុះទៅនេសាទត្រីផងដែរ ហើយជួនកាល ពួកគេបានប្រើឧបករណ៍នេសាទខុសច្បាប់ ដោយធ្វើយ៉ាងណា ឱ្យតែអាចរស់បានមួយគ្រាសិនះ

*យើងគ្មានលុយគ្រប់គ្រាន់ ដើម្បីទិញម្ហូបអាហារទេ ដូច្នេះយើងត្រូវតែទៅនេសាទត្រី ហើយពេលខ្លះយើងបានប្រើមងនេសាទ ឬឧបករណ៍ឆក់ត្រីខុសច្បាប់ទៀតផង។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកញ្ចិល ឃុំកំពង់រាប ស្រុកព្រែកប្រាស ខេត្តតាកែវ។

ក្រុមបុរសមកពីគ្រួសារក្រីក្រក្នុងខេត្តតាកែវ បានស្វះស្វែងរកការងារធ្វើនៅតាមរោងចក្រកាត់ដេរ និងវាយនភណ្ឌ ឬធ្វើជាកម្មករសំណង់ នៅតាមតំបន់ជាយក្រុង ឬចំណាកស្រុកទៅក្រៅប្រទេស ដើម្បីជាវិធីដោះស្រាយក្នុងគ្រាមានប្រាក់ចំណូលតិចតួច។ នៅខេត្តកំពង់ធំ ក្រុមបុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ និងសមាជិកគ្រួសារដែលមិនស្ថិតក្នុងគ្រួសារក្រីក្រ បានងាកមកចាប់យកការងារសំណង់ សម្រាប់ជាជម្រើសជំនួសដើម្បីរកចំណូលក្នុងគ្រាលំបាក៖

*ជាធម្មតា គ្រួសាររបស់ខ្ញុំពឹងអាស្រ័យលើការងារស្រែចម្ការ ប៉ុន្តែ ក្នុងគ្រាលំបាក ខ្ញុំទៅធ្វើការនៅការដ្ឋានសំណង់ ដើម្បីរកប្រាក់កម្រៃបន្ថែម។* FGD បុរសដែលមិនស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិជ័យជំនះ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

ទោះជាយ៉ាងណាក៏ដោយ វិធីទប់ទល់ទាំងនេះ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ ការអប់រំរបស់កុមារ ត្រូវបានប៉ះពាល់យ៉ាងខ្លាំង ដោយកុមារខ្លះត្រូវឈប់រៀនដើម្បីប្រកបមុខរបរទាំងមិនទាន់គ្រប់អាយុ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ជាពិសេសនៅតាមរោងចក្រកាត់ដេរ និងវាយនភណ្ឌ ឬជាកម្មករស៊ីឈ្នួលតាមផ្ទះ។ គេបានកត់សម្គាល់ឃើញថា ចំណុចនេះមិនត្រូវបានលើកឡើងដោយក្រុមអ្នកចូលរួមឆ្លើយសំណួរទាំងនោះទេ ទាំងក្រុមបុរសដែលមិនស្ថិតក្នុងគ្រួសារក្រីក្រ ទាំងក្រុមបុរសដែលស្ថិតក្នុងគ្រួសារក្រីក្រផង។ ភាពខុសគ្នាទាំងនេះ ភាគច្រើនបណ្ដាលមកពីការប្រែប្រួលនៃលទ្ធភាពរកបានទូវធនធាន និងប្រភេទនៃឱកាសការងារនៅក្នុងតំបន់នីមួយៗ។

*កូនៗរបស់ខ្ញុំបានឈប់រៀន នៅពេលពួកគេប្រឡងធ្លាក់ បន្ទាប់មកក៏ចាប់ផ្ដើមទៅធ្វើការ នៅតាមរោងចក្រកាត់ដេរ និងវាយនភណ្ឌក្នុងរាជធានីភ្នំពេញ។ ពួកគេផ្ញើប្រាក់មកឱ្យខ្ញុំ ដើម្បីទិញអង្ករ និងចំណាយលើអ្វីៗផ្សេងទៀត ដើម្បីផ្គត់ផ្គង់គ្រួសារ។* FGD ស្ត្រីដែលជាមេគ្រួសារ រស់នៅភូមិកញ្ចិល ឃុំកំពង់រាប ស្រុកព្រែកប្រាស ខេត្តតាកែវ។

នៅទីតាំងសិក្សាទាំងពីរនេះ ក្រុមអ្នកចូលរួមឆ្លើយសំណួរទាំងអស់បានបញ្ជាក់ថា ក្នុងគ្រាដែលមានប្រាក់ចំណូលទាប គឺប៉ះពាល់យ៉ាងខ្លាំងដល់ការទទួលទានអាហាររបស់ពួកគេ ដោយអ្នកខ្លះបានឱ្យដឹងថា ពួកគេបានកាត់បន្ថយចំនួនអាហារប្រចាំថ្ងៃពី បីពេល មកនៅត្រឹម ពីរពេលវិញ ហើយក្នុងករណីខ្លះពីពីរពេល មកនៅត្រឹមមួយពេលតែប៉ុណ្ណោះ។ ដូច្នេះគេអាចសន្និដ្ឋានថា ករណីបែបនេះនឹងនាំឱ្យមានអត្រាខ្ពស់នៃកង្វះអាហារូបត្ថម្ភ ហើយក៏អាចបង្កើនហានិភ័យនៃកង្វះអាហារូបត្ថម្ភផងដែរ ដោយសារការថយចុះនៃចំនួនពេលដែលត្រូវបរិភោគអាហារប្រចាំថ្ងៃ និងមិនគ្រប់បរិមាណដែលត្រូវបានណែនាំទាក់ទងនឹងសារធាតុចិញ្ចឹមចាំបាច់សម្រាប់ការថែរក្សាសុខភាព និងសុខុមាលភាពទូទៅ៖

*យើងធ្លាប់ញ៉ាំចំណីចំណុកផ្សេងៗ ពេលរសៀល បន្ទាប់ពីអាហារថ្ងៃត្រង់រួច ប៉ុន្តែក្នុងគ្រាលំបាកបែបនេះ យើងត្រូវឈប់ទិញចំណីចំណុកផ្សេងៗទាំងនោះ។ យើងថែមទាំងត្រូវកាត់បន្ថយបរិមាណម្ហូបអាហារដែលយើងញ៉ាំ ពីអាហារពីរពេល មកនៅត្រឹមមួយពេលវិញ។* FGD ស្ត្រីដែលមិនស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិសំរោង ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

*យើងត្រូវកាត់បន្ថយបរិមាណម្ហូបអាហារដែលយើងញ៉ាំក្នុងរយៈពេលពីរបីថ្ងៃ រហូតដល់យើងមានលុយវិញគ្រប់គ្រាន់ ដើម្បីទិញម្ហូបអាហារជាថ្មី។ ជាឧទាហរណ៍ យើងធ្លាប់ទិញសាច់ឱ្យបានកន្លះគីឡូក្រាមសម្រាប់ធ្វើម្ហូបមួយពេលក្នុងគ្រួសារ ប៉ុន្តែក្នុងគ្រាមានប្រាក់ចំណូលតិចតួច យើងបានកាត់បន្ថយចំនួនសាច់នេះ មកត្រឹមពីរខាំវិញក្នុងមួយពេល។* FGD ស្ត្រីមេគ្រួសារ រស់នៅឃុំកំពង់រាប ស្រុកព្រែកប្រាស ខេត្តតាកែវ។

ជាការពិតណាស់ ដំណោះស្រាយផ្អែកលើចំណីអាហារ ក៏មានប្រេវ៉ាឡង់ច្រើនផងដែរ ដោយក្រុមអ្នកចូលរួមឆ្លើយសំណួរទាំងអស់ បានឱ្យដឹងពីការថយចុះទាំងបរិមាណ និងគុណភាពនៃចំណីអាហារដែលត្រូវបរិភោគ ដោយអាស្រ័យលើចំណីអាហារដែលមិនសូវមានជីវជាតិច្រើន ដែលមានជាតិខ្លាញ់ ស្ករ និងប្រៃខ្លាំង ដែលមិនល្អសម្រាប់សុខភាព ហើយមានតម្លៃថោកក៏ពិតមែន ប៉ុន្តែវាមានផលប៉ះពាល់យ៉ាងខ្លាំងដល់របបអាហារនៃសមាជិកទាំងអស់ក្នុងគ្រួសារ។ អាហារដែលមានតម្លៃសមរម្យ ដូចជា ស៊ុត ត្រីឆ្អិតតូចៗ និងត្រីផ្អក ជាញឹកញាប់ត្រូវបានទិញមកបរិភោគ ជំនួសសាច់ក្នុងគ្រាលំបាកទាំងនេះ ដោយអាហារចុងក្រោយនេះ គឺជាជម្រើសដែលងាយរកបាន។ ទោះជាយ៉ាងណាក៏ដោយ អាហារ

ត្រីផ្អកទាំងនេះ មិនបានផ្តល់ផលល្អដល់សុខភាពទេ ដោយសារវាមានជាតិសូដ្យូមខ្ពស់ ហើយប្រសិនបើទទួលទានច្រើនពេក អាចនឹងបង្កគ្រោះថ្នាក់ដល់សុខភាពទៀតផង។ អាហារទាំងនេះ ត្រូវបានគេបរិភោគជាប្រចាំ លាយឡំជាមួយបន្លែដែលដាំដុះនៅជុំវិញផ្ទះ ដែលជាទូទៅត្រូវបានគេបេះបោចយកមកធ្វើម្ហូបក្នុងគ្រារកប្រាក់ចំណូលបានតិចតួច។

*ប្រពន្ធខ្ញុំ ធ្វើម្ហូបកាន់តែតិចជាងមុន។ យើងដើរបេះបន្លែបៃតងដែលដាំនៅជុំវិញផ្ទះ និងមានពងមាន់ ឬពងទាខ្លះមកធ្វើម្ហូប។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិជ័យជំនះ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

*យើងបានកាត់បន្ថយច្រើន លើការទទួលទានអាហារ។ ឧទាហរណ៍ យើងធ្លាប់ញាំត្រី និងសាច់ ប៉ុន្តែដោយសារបញ្ហាហិរញ្ញវត្ថុ យើងបានញាំពងមាន់ពងទាជំនួសវិញ។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិជ័យជំនះ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

ក្រុមអ្នកចូលរួមឆ្លើយសំណួរពីរបីនាក់ បានឱ្យដឹងពីការរក្សាទុកអាហារក្រៀមនៅផ្ទះ សម្រាប់បរិភោគក្នុងគ្រាមានបញ្ហាផ្នែកហិរញ្ញវត្ថុ ដែលជួយកាត់បន្ថយផលប៉ះពាល់លើទម្លាប់ ឬលំអាននៃការទទួលទានរបស់ពួកគេ។ សរុបមក ទន្ទឹមនឹងភាពស្រដៀងគ្នា ក្នុងវិធីទប់ទល់ក្នុងគ្រាលំបាករបស់អ្នករស់នៅទីតាំងសិក្សាទាំងពីរនេះ ក៏មានភាពខុសប្លែកគ្នាខ្លះផងដែរនៅក្នុងមុខម្ហូបជាក់លាក់ដែលបានទិញ និងវិធានការបន្ថែមដែលធ្វើឡើង ដើម្បីកាត់បន្ថយផលប៉ះពាល់នៃប្រាក់ចំណូលទាបលើការទទួលទានអាហារ។ ទោះបីជាមានការផ្លាស់ប្តូរទាំងនេះក៏ដោយ ក៏ពួកគេខិតខំប្រឹងប្រែងដើម្បីធានាថាកូនៗអាចរក្សារបបអាហាររបស់ពួកគេបាន ដោយបានគិតគូរពីតម្រូវការចាំបាច់ និងការអប់រំរបស់ពួកគេ។

*នៅពេលយើងកាត់បន្ថយការទទួលទានអាហារដូច្នេះ កុមារកាន់តែចុះខ្សោយ ហើយងាយនឹងឈឺទៀតផង។* FGD ស្ត្រីដែលជាមេគ្រួសារ រស់នៅឃុំកំពង់រាប ស្រុកព្រែកប្រសព្វ ខេត្តតាកែវ។

គ្រួសារមួយចំនួន ជាពិសេសនៅជុំវិញស្រះជម្រកត្រីសហគមន៍បឹងរៀម ក្នុងខេត្តកំពង់ធំ ត្រូវបានគេកត់សម្គាល់ថា មានការថយចុះនូវការទទួលទានអាហារ និងអាហារមិនមានរសជាតិ ដោយបានគូសបញ្ជាក់ពីភាពស្មុគស្មាញនៃការរក្សាស្តង់ដាររបបអាហារក្នុងគ្រាមានការលំបាកផ្នែកហិរញ្ញវត្ថុ៖

*ប្រសិនបើយើងជាមនុស្សប្រុស បរិភោគអាហារតិចពេក ឬគ្មានរសជាតិ នោះយើងច្បាស់ជាមានអារម្មណ៍ថា ខ្សោះខ្សោយ និងមិនសូវមានកម្លាំងទេ។* FGD បុរសដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិជ័យជំនះ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ។

ក្នុងគ្រាមានប្រាក់ចំណូលទាប អ្នកចូលរួមឆ្លើយសំណួរទាំងអស់នៅក្នុងទីតាំងសិក្សាទាំងពីរ បានសង្កេតឃើញការផ្លាស់ប្តូរទម្រង់នៃការទទួលទានអាហារ និងទម្លាប់នៃរបបអាហាររបស់សមាជិកគ្រួសារទាំងអស់ រួមទាំងបុរស ស្ត្រី និងកុមារ។ អ្នកចូលរួមឆ្លើយសំណួរភាគច្រើននៅគ្រប់ក្រុមទាំងអស់ បានលើកឡើងពីការផ្តល់អាទិភាពលើការទទួលទានអាហារសម្រាប់បុរសដែលជាអ្នកធ្វើការងារ និងជាអ្នករកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ៖

*ប្តីរបស់ខ្ញុំ ត្រូវការញាំច្រើនជាងគេ។ ខ្ញុំទុកម្ហូបអាហារឱ្យគាត់ ច្រើនជាងខ្លួនឯង ព្រោះគាត់ត្រូវការថាមពល និងមានកម្លាំង ដើម្បីធ្វើការជាបន្ត។* FGD ស្ត្រីជាមេគ្រួសារ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកប្រសព្វ ខេត្តតាកែវ។

*ពេលគ្រួសារខ្ញុំ រកប្រាក់មិនបានគ្រប់គ្រាន់ យើងមិនបានទិញម្ហូបអាហារទេ។ ខ្ញុំត្រូវចេញទៅនេសាទ។ ដូច្នេះហើយគ្រួសារខ្ញុំ ត្រូវរំពឹងលើការនេសាទនេះ ហើយពេលខ្លះយើងមានតែត្រីមួយ ឬពីរសម្រាប់ហូបជាមួយគ្នា ប៉ុន្តែប្រពន្ធខ្ញុំទុកឱ្យខ្ញុំ និងកូនៗ បានហូបច្រើនជាងគាត់។* FGD បុរសដែលស្ថិតក្នុងគ្រួសារក្រីក្រ រស់នៅភូមិកញ្ជិល ឃុំកំពង់រាប ស្រុកព្រែកប្រសព្វ ខេត្តតាកែវ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ មនុស្សភាគច្រើន បានកត់សម្គាល់ឃើញ ពីផ្លាស់ប្តូរលំអាននៃការទទួលទានអាហារ រីឯអ្នកខ្លះមិនបានសង្កេតឃើញពីការផ្លាស់ប្តូរណាមួយ នៅក្នុងទម្លាប់នៃរបបអាហាររបស់សមាជិកគ្រួសារទាំងអស់ រួមទាំងកុមារផង ដោយបង្ហាញពីភាពធន់របស់គ្រួសារទាំងនេះ ជាពិសេសអ្នកដែលមិនមែនស្ថិតក្នុងក្រុមក្រីក្រ និងសមត្ថភាពរបស់ពួកគេក្នុងការសម្របខ្លួនក្នុងស្ថានភាពលំបាកផ្នែកសេដ្ឋកិច្ចគ្រួសារ។

លក្ខណៈ និងភាពញឹកញាប់នៃជំនួយ ដែលប្រជាជនបានទទួលក្នុងគ្រាលំបាក មានភាពខុសប្លែកគ្នានៅក្នុងទីតាំងដែលបានសិក្សា។ ទោះបីមិនមែនជាបាតុភូតធម្មតាក៏ដោយ រចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋាន មិនសុទ្ធតែមានសមត្ថភាពផ្ដល់ជំនួយហិរញ្ញវត្ថុ ដល់ប្រជាជនក្នុងគ្រាលំបាកនោះទេ ផ្ទុយទៅវិញ ការផ្ដល់ស្បៀងអាហារដល់ជនដែលរងផលប៉ះពាល់ ឬពឹងផ្អែកលើអង្គការ និងស្ថាប័នខាងក្រៅសម្រាប់ជំនួយ ជាធម្មតាត្រូវបានធ្វើឡើងក្នុងទម្រង់ជាការបរិច្ចាគអំណោយ។ នៅពេលសួរថាតើពួកគេធ្លាប់បានទទួលដំបូន្មាន ឬការណែនាំអំពីជម្រើសអាហារ និងអាហារូបត្ថម្ភជាអាទិភាពក្នុងគ្រាលំបាកដែរឬអត់ ពេលនោះអ្នកចូលរួមឆ្លើយសំណួរភាគច្រើនបានឆ្លើយថា ពួកគេមិនដែលបានទទួលដំបូន្មានទាំងនេះទេ ហើយក៏គ្មានដំណោះស្រាយណាមួយ ចំពោះបញ្ហាអាហារូបត្ថម្ភឱ្យបានច្បាស់លាស់នោះដែរ។ ដោយសារតែឧបសគ្គលើគុណភាពអាហារ និងបរិមាណដែលប្រជាជនបានជួបប្រទះ ក្នុងគ្រាលំបាកផ្នែកហិរញ្ញវត្ថុដូចដែលបានរៀបរាប់ខាងដើម វាពិតជាមានសារៈសំខាន់ណាស់ក្នុងការផ្ដល់ការណែនាំអំពី របៀបបង្កើនបរិមាណអាហារូបត្ថម្ភរបស់ពួកគេឱ្យបានច្រើនបំផុតក្នុងស្ថានភាពបែបនេះ។ អ្នកចូលរួមឆ្លើយសំណួរមួយចំនួន ក៏បានលើកឡើងផងដែរថា តម្រូវការចាំបាច់បន្ថែមរបស់ក្រុមងាយរងគ្រោះ គួរតែត្រូវបានយកមកពិចារណាៈ

> *មិនមានជំនួយអ្វីទេ។ ខាងឃុំក៏អះអាងដែរថា ខ្លួនគ្មានសមត្ថភាពជួយបានទេ ទោះបីជាកសិករបាត់បង់ផលប្រយោជន៍ពីការធ្វើស្រែចម្ការ ជាពិសេស នៅរដូវប្រាំង ដោយសារខ្វះទឹកស្រោចស្រពក៏ដោយ។ ខាងឃុំអាចផ្ដល់ជំនួយបន្តិចបន្តួចប៉ុណ្ណោះ ដូចជា អង្ករ ត្រីខកំប៉ុង និងទឹកស៊ីអ៊ីវ ដល់ប្រជាពលរដ្ឋណាដែលរងគ្រោះខ្លាំង។ មេភូមិមិនដែលណែនាំនរណាម្នាក់ អំពីទម្លាប់ហូបចុករបស់ពួកគេ ឬអ្វីដែលត្រូវបរិភោគនោះឡើយ។ វាគឺជាជីវិតផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ ដែលមេភូមិមានសមត្ថភាពតិចតួចណាស់ក្នុងការណែនាំគេ។* KII អនុប្រធានភូមិ ភូមិសំណាក ខេត្តកំពង់ធំ។

> *ក្នុងពេលលំបាក មិនថាពេលគ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួតនោះទេ ភូមិទទួលបានការឧបត្ថម្ភពីសាលាស្រុក និងឃុំ។ ជាងនេះទៅទៀត ភូមិមានថវិកាកំណត់សម្រាប់ផ្គត់ផ្គង់ដល់មនុស្សចាស់ អតីតយុទ្ធជន កុមារកំព្រា និងស្ត្រីមានផ្ទៃពោះ ឬស្ត្រីក្រីក្រ។ ជំនួយទាំងនោះ រួមមានគ្រឿងឧបភោគបរិភោគដូចជា អង្ករ ត្រីខកំប៉ុង និងទឹកស្អាត ព្រមទាំងថវិកាមួយចំនួនផងដែរ។ កាកបាទក្រហម ក៏បានបរិច្ចាគថវិកាមួយចំនួនរបស់ខ្លួន ដើម្បីជួយជនរងគ្រោះក្នុងព្រឹត្តិការណ៍បែបនេះផងដែរ។ (...) ប្រធានភូមិ បានណែនាំប្រជាពលរដ្ឋ ឱ្យមានការប្រុងប្រយ័ត្ននៅពេលមានគ្រោះទឹកជំនន់ ឬគ្រោះអាកាសធាតុ ហើយបានប្រាប់ពួកគេឱ្យបរិភោគអាហារណាដែលផ្ដល់សុខភាពល្អ និងផឹកទឹកឱ្យបានគ្រប់គ្រាន់។ អាហារដែលត្រូវបានណែនាំដល់អ្នកភូមិ រួមមាន សាច់ ត្រី ស៊ុត និងបន្លែ ព្រោះអាហារទាំងនោះ អាចផ្ដល់ថាមពលដល់រាងកាយរបស់យើង។* KII ប្រធានភូមិជ័យជំនះ ខេត្តកំពង់ធំ។

> *ចំពោះអ្នកដែលមានជីវភាពដុនដាប និងគ្មានអាហារគ្រប់គ្រាន់ មេភូមិសំណូមពរដល់សប្បុរសជន និងគណបក្សប្រជាជនកម្ពុជាឱ្យជួយឧបត្ថម្ភ និងផ្ដល់ស្បៀងអាហារផងដែរ។ កាកបាទក្រហម ក៏បានផ្ដល់ការឧបត្ថម្ភដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ផងដែរ (...) ប្រធានភូមិបានណែនាំឱ្យប្រជាពលរដ្ឋ ដាំដុះបន្លែបង្ការជាលក្ខណៈគ្រួសារ និងបានណែនាំដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ឱ្យអនុវត្តការបរិភោគចំណីអាហារឱ្យបានត្រឹមត្រូវ និងការប្រើប្រាស់ទឹកប្រកបដោយសុវត្ថិភាព។* KII ប្រធានភូមិកញ្ជិល ខេត្តតាកែវ។

## ៥. ការពិភាក្សា

ការប្រើប្រាស់ស្បៀង ដែលជាសសរស្តម្ភដ៏សំខាន់មួយនៃសន្តិសុខស្បៀង សំដៅលើការទទួលបានសារធាតុចិញ្ចឹមប្រកបដោយប្រសិទ្ធភាពសម្រាប់រាងកាយមនុស្ស។ ការអនុវត្តលើការចិញ្ចឹមបីបាច់ និងការរៀបចំ ការចែកចាយអាហារក្នុងគ្រួសារ អនាម័យ និងការផ្គត់ផ្គង់ទឹក និងប្រភេទចម្រុះនៃរបបអាហារ មានតួនាទីសំខាន់ក្នុងការកំណត់ការប្រើប្រាស់ជីវសាស្ត្រនៃលទ្ធផលអាហារ និងអាហារូបត្ថម្ភ។ វិមាត្រនៃការប្រើប្រាស់សេដ្ឋកិច្ច-សង្គម ដែលជារឿយៗត្រូវបានមើលរំលង រួមបញ្ចូលទាំងកត្តាមួយចំនួនដូចជា ចំណេះដឹងអំពីរបបអាហារ ទម្លាប់ និងដំណើរការធ្វើការសម្រេចចិត្តទាក់ទងនឹងការទិញ និងការចាត់ចែងអាហារ ដែលជារឿយៗ ត្រូវបានផ្សារភ្ជាប់ទៅនឹងការទទួលបានការអប់រំ សមាសភាពយេនឌ័រក្នុងគ្រួសារ និងកម្រិតប្រាក់ចំណូល (Placzek 2021)។ ទិន្នន័យ KII និង FGD ដែលបានពីការសិក្សានេះ បានផ្ដល់នូវលទ្ធផលរកឃើញដ៏មានតម្លៃចំពោះទម្លាប់នៃរបបអាហារ និងការអនុវត្តផលិតកម្មអាហារនៅក្នុងតំបន់ទំនាបលិចទឹកបឹងទន្លេសាប និងតំបន់ដីសណ្ដទន្លេមេគង្គរបស់ប្រទេសកម្ពុជា ជាពិសេសឧបសគ្គផ្លូវការ

និងក្រៅផ្លូវការដែលប៉ះពាល់ដល់ការផលិត និងការប្រើប្រាស់ស្បៀងអាហារប្រកបដោយអាហារូបត្ថម្ភ ដែលក្រុមអ្នកចូលរួមឆ្លើយសំណួរកំពុងប្រឈម នៅក្នុងសហគមន៍ដែលបានសិក្សា។ ដូចដែលបានរៀបរាប់ពីខាងដើម មានភាពស្មុគស្មាញ សេដ្ឋកិច្ច-សង្គមប្រទាក់ក្រឡាគ្នា សមត្ថភាពស្ថាប័ន និងកត្តាបរិស្ថាន ដែលជាអ្នកកំណត់ និងមានឥទ្ធិពលលើការប្រើប្រាស់ស្បៀងអាហារ និងស្ថានភាពអាហារូបត្ថម្ភនៅកម្រិតបុគ្គល និងគ្រួសារ។

សារៈសំខាន់នៃអង្ករសម្រាប់ប្រទេសកម្ពុជា មិនអាចមើលរំលងបានឡើយ។ អង្ករ គឺជាអាហារចម្បងនៃរបបអាហាររបស់ប្រជាជន ជាកសិផលនាំចេញដ៏សំខាន់ និងជាកត្តាជំរុញកំណើនសេដ្ឋកិច្ច ហើយផលិតកម្មស្រូវអង្ករបានរួមចំណែកយ៉ាងធំដល់ការកាត់បន្ថយភាពក្រីក្រ (Ros, Nang and Chhim 2011)។ គ្រួសារនៅជនបទភាគច្រើនអាស្រ័យយ៉ាងខ្លាំងលើវិស័យកសិកម្ម ដោយសារភាគច្រើនជាផលិតកម្មស្រូវអង្ករ និងការនេសាទ សម្រាប់តម្រូវការអាហារូបត្ថម្ភ និងសន្តិសុខស្បៀងរបស់ពួកគេ។ ក្នុងន័យនេះ បង្ហាញថាទីតាំងសិក្សាដែលបានជ្រើសរើស គឺជាករណីលើកលែង ចំពោះនិន្នាការទូលំទូលាយនៅក្នុងប្រទេសកម្ពុជា៖ គ្រួសារភាគច្រើន ដែលរស់នៅជុំវិញគម្រោងប្រព័ន្ធធារាសាស្ត្រតាសួង និងស្រះជម្រកត្រីសហគមន៍បឹងរៀម ប្រកបរបរកសិកម្មតាមផ្ទះ និងការចិញ្ចឹមសត្វ ដែលទាមទារឱ្យមានទំហំដីសមរម្យ និងការចំណាយធនធានតិចជាងការដាំដុះស្រូវ។ ការបរិភោគបន្លែ និងផលិតកម្មនៅក្នុងប្រទេសកម្ពុជាជាទូទៅមានកម្រិតទាប ក្នុងនោះប្រជាជនកម្ពុជាតិចជាង ៥០% ដែលបានទទួលទានបន្លែប្រចាំថ្ងៃតាមការណែនាំ និងមានចំនួនតិចជាង ១០% នៃផ្ទៃដីដាំដុះ (Vilain et al. 2016; Yu and Fan 2009)។ ការទទួលទានតិចតួច និងមិនអាចរកទិញបាន បើធៀបនឹងអាហារដែលមានសារធាតុចិញ្ចឹមតិច ជាទូទៅដោយសារតែផ្លែឈើ និងបន្លែភាគច្រើនដែលដាំដុះក្នុងប្រទេសកម្ពុជាច្រើនតែអាស្រ័យលើទឹកភ្លៀង ដូច្នេះហើយងាយរងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ រីឯការអាស្រ័យខ្ពស់របស់កសិករលើផលិតកម្មស្រូវ បានដាក់កម្រិតលើភាពចម្រុះផ្នែកកសិកម្ម និងរបបអាហារ (GIZ 2023)។ ម៉្យាងវិញទៀត ការលើកកម្ពស់ការធ្វើពិពិធកម្មកសិកម្មឱ្យទូលំទូលាយ និងការដាំដុះដំណាំដែលធន់នឹងអាកាសធាតុ ដូចជាត្រកួន ដំឡូងជ្វា ល្ពៅ និងបន្លែយកមើមផ្សេងទៀត (ដែលសមស្រប) នឹងជួយបង្កើនភាពសម្បូរបែបនៃរបបអាហារ និងអាហារូបត្ថម្ភរបស់គ្រួសារនីមួយៗ (GIZ 2023)។ វិធីសាស្ត្រនេះមានសក្តានុពលក្នុងការកាត់បន្ថយភាពក្រីក្រដោយការធ្វើពិពិធកម្មប្រភពចំណូល កាត់បន្ថយការពឹងផ្អែកដំណាំតែមួយមុខ និងការកែលម្អភាពធន់ទៅនឹងវិបត្តិសេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុ។

ភាពខុសគ្នាខ្លាំង កើតមានក្នុងចំណោមក្រុមសេដ្ឋកិច្ច-សង្គម នៅពេលនិយាយអំពីលទ្ធភាពប្រើប្រាស់ធនធានដែលបង្ហាញពីភាពខុសគ្នាគួរឱ្យកត់សម្គាល់នៅក្នុងលទ្ធផលសន្តិសុខអាហារ និងអាហារូបត្ថម្ភ។ អ្នកចូលរួមឆ្លើយសំណួរដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្រ ដែលជាធម្មតាមានកម្មសិទ្ធិដីធ្លីទំហំធំៗ ហាក់មិនបង្ហាញឱ្យឃើញថា មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងទម្លាប់នៃរបបអាហារក្នុងគ្រួសាររបស់ពួកគេទេ។ ពួកគេក៏មានលទ្ធភាពទទួលបានកាន់តែប្រសើរនូវសេវាផ្សព្វផ្សាយ កម្រិតអប់រំកាន់តែខ្ពស់ និងការយល់ដឹងកាន់តែទូលំទូលាយអំពីអាហារូបត្ថម្ភ និងអនាម័យ បើធៀបទៅនឹងអ្នកដែលស្ថិតក្នុងគ្រួសារក្រីក្រ។ ជារួម ភាពល្អប្រសើរទាំងនេះ បានជំរុញឱ្យអ្នកដែលមិនស្ថិតក្នុងគ្រួសារក្រីក្រ រីករាយនឹងទទួលទានអាហារដែលកាន់តែមានស្ថិរភាព និងមានជីវជាតិគ្រប់គ្រាន់។ ផ្ទុយទៅវិញ សម្រាប់អ្នកដែលមានដីធ្លីទំហំតូច កង្វះលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយ និងការអប់រំកម្រិតទាប បានជំរុញឱ្យមានភាពងាយរងគ្រោះកាន់តែច្រើន និងកាត់បន្ថយលទ្ធភាពក្នុងការធានាសន្តិសុខស្បៀង ក្នុងចំណោមគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងគ្រួសារក្រីក្រ ដោយគូសបញ្ជាក់ពីតម្រូវការចាំបាច់សម្រាប់ដំណោះស្រាយប្រកបដោយនិរន្តរភាព ដើម្បីធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់គ្រប់ក្រុមទាំងអស់ ជាពិសេសក្នុងគ្រាមានការលំបាកផ្នែកហិរញ្ញវត្ថុ។

សក្តានុពលយេនឌ័រ និងគ្រួសារ បានលេចចេញជាកត្តាសំខាន់ ដែលជះឥទ្ធិពលលើលំអាននៃការប្រើប្រាស់ស្បៀងអាហារ និងសន្តិសុខអាហារូបត្ថម្ភក្នុងចំណោមគ្រួសាររស់នៅជនបទនៃប្រទេសកម្ពុជា។ ដូចដែលបានពិភាក្សានៅក្នុងវិវេចនាឯកសារ ស្ត្រីខ្មែរទទួលបន្ទុកលើកិច្ចការច្រើនដូនចជាការថែទាំ និងការគ្រប់គ្រងគ្រួសារទាំងមូល ដូច្នេះហើយពួកគេបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងគ្រួសាររបស់ខ្លួន។ បន្ថែមពីលើនេះ ការសិក្សានេះបានរកឃើញថា ស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ ឬស្ត្រីជាមេគ្រួសារ ទទួលរងផលប៉ះពាល់ដោយភាពតានតឹងផ្នែកសេដ្ឋកិច្ច និងបញ្ហាប្រឈមក្នុងការផលិតស្បៀងអាហារ។ ជាការពិត ការប្រឈមមុខនឹងទំនួលខុសត្រូវក្នុងការគ្រប់គ្រងការចំណាយលើការអប់រំរបស់កូនៗ ការកើនឡើងនៃថ្លៃដើមផលិតកម្ម ក៏ដូចជាការលំបាកក្នុង

ការទទួលបានធនធានផ្សេងៗ ធ្វើឱ្យពួកគេត្រូវប្រឈមនឹងការលំបាកផ្នែកហិរញ្ញវត្ថុកាន់តែធ្ងន់ធ្ងរឡើង ក្នុងនាមជាអ្នកផ្ដល់សេវាចម្បងសម្រាប់ក្រុមគ្រួសារ។ ដូច្នេះហើយ ទើបពួកគេត្រូវទទួលរងដោយផ្ទាល់នូវផលប៉ះពាល់ដល់សុខភាព និងស្ថានភាពអាហារូបត្ថម្ភ។ អ្នកចូលរួមឆ្លើយសំណួរភាគច្រើននៅទីតាំងទាំងពីរដែលបានធ្វើការសិក្សា បានឱ្យដឹងពីការកាត់បន្ថយបរិមាណ និងគុណភាពនៃការទទួលទានអាហារក្នុងគ្រាមានការលំបាកផ្នែកហិរញ្ញវត្ថុ។ ទោះយ៉ាងណាតម្រូវការអាហារូបត្ថម្ភរបស់បុរស ដែលជាអ្នកធ្វើការរកប្រាក់ចិញ្ចឹមគ្រួសារ ត្រូវបានផ្ដល់អាទិភាពជាងសមាជិកគ្រួសារផ្សេងទៀត ដែលហាក់ដូចជាស្របទៅនឹងលទ្ធផលរកឃើញនៃការសិក្សាដោយ McDonald et al. (2015) ស្ដីពីការអង្កេតស្រាវជ្រាវលើ ទំនាក់ទំនងនៃកង្វះអាហារូបត្ថម្ភរបស់ស្ត្រីជាមាតានៅប្រទេសកម្ពុជា។ ចំណុចនេះចង្អុលបង្ហាញពីតម្រូវការជាក់លាក់សម្រាប់ការគាំទ្រកាន់តែច្រើន សម្រាប់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងងាយរងគ្រោះ ដើម្បីធានាថា សមាជិកទាំងអស់ក្នុងគ្រួសារនីមួយៗកំពុងទទួលទានរបបអាហារដែលមានតុល្យភាពអាហារូបត្ថម្ភ។

ការបន្តរក្សាវិសមភាពក្នុងតួនាទី និងទំនួលខុសត្រូវលើមូលដ្ឋានយេនឌ័រ មានផលប៉ះពាល់អវិជ្ជមានដល់អនាគតនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រទេសកម្ពុជា។ ទោះបីជាស្ត្រីមានតួនាទីសំខាន់ក្នុងការផលិតស្បៀង និងការចូលរួមក្នុងកិច្ចការសហគមន៍ដូចដែលបានបង្ហាញនៅក្នុងការសិក្សានេះក៏ដោយ ក៏សិទ្ធិទទួលបានធនធាន ដីធ្លី និងសេវាផ្សព្វផ្សាយ និងហិរញ្ញវត្ថុនៅមានកម្រិត និងមានផលប៉ះពាល់យ៉ាងខ្លាំងលើការទទួលទានអាហារ និងអាហារូបត្ថម្ភក្នុងគ្រួសាររបស់ពួកគេ ក៏ដូចជាធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពក្នុងការរួមចំណែកប្រកបដោយប្រសិទ្ធភាព និងអត្ថប្រយោជន៍ពីការកែលម្អវិស័យកសិកម្ម។ ទស្សនៈតាមទម្លាប់នៅក្នុងសង្គម បានផាត់ពួកគេចេញពីដំណើរការធ្វើសេចក្ដីសម្រេចចិត្ត (Messina et al. 2017)។ ជាឧទាហរណ៍ កត្តារួមផ្សំដែលនៅពីក្រោយលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយរបស់ស្ត្រីនៅមានកម្រិត គឺដោយសារសមាសភាពបុគ្គលិកដែលធ្វើការផ្នែកសេវាផ្សព្វផ្សាយភាគច្រើន គឺជាបុរស (UNIFEM 2004)។ បុរសជាភ្នាក់ងារដែលធ្វើការផ្នែកសេវាផ្សព្វផ្សាយយល់ឃើញថា ពិតជាមានការលំបាកខាងវប្បធម៌ក្នុងការប្រាស្រ័យទាក់ទង និងចូលរួមជាមួយកសិករជាស្ត្រី ប៉ុន្តែក៏មិនអាចផ្ដល់ឱ្យពួកគេនូវព័ត៌មាន និងការគាំទ្រជាក់លាក់ចំពោះសកម្មភាពកសិកម្មដែលជាធម្មតាធ្វើឡើងដោយស្ត្រី។ ភាពមិនស្មើគ្នាបែបនេះ បង្កើតជាភាពងាយរងគ្រោះបន្ថែមទៀតចំពោះការប្រែប្រួលអាកាសធាតុ ការថយចុះសមត្ថភាពសម្របខ្លួន និងផលិតភាពរបស់ស្ត្រី និងធ្វើឱ្យអសន្តិសុខស្បៀងកាន់តែធ្ងន់ធ្ងរដែលជៀសមិនរួច ដោយសារលក្ខខណ្ឌប្រឈមកាន់តែខ្លាំងឡើងនៃការប្រែប្រួលអាកាសធាតុ។

រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងខិតខំប្រឹងប្រែងធ្វើសមាហរណកម្មទស្សនៈយេនឌ័រ នៅក្នុងវិស័យកសិកម្ម ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គួរកត់សម្គាល់ថា ផែនការសកម្មភាពអាទិភាពនៃការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៤-២០១៨ និងគោលនយោបាយស្ដីពីការបញ្ជ្រាបយេនឌ័រ និងក្របខណ្ឌយុទ្ធសាស្ត្រក្នុងវិស័យកសិកម្ម ឆ្នាំ២០១៦-២០២០ ដែលបង្កើតឡើងដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF 2013; 2015) ក៏ដូចជាផែនការមេស្ដីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៨-២០៣០ ដែលបង្កើតដោយក្រសួងកិច្ចការនារី (MoWA 2017) ដើម្បីស្វែងរកការលើកកម្ពស់សិទ្ធិអំណាចរបស់ស្ត្រី ដោយធានាឱ្យមាន សិទ្ធិទទួលបានធនធាន និងតំណាងដោយសមធម៌ ការទទួលស្គាល់ និងការគាំទ្រតួនាទីរបស់ស្ត្រី ក្នុងដំណើរការផលិតស្បៀងអាហារ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកែលម្អសមត្ថភាពស្ថាប័ន។ តួនាទី និងសិទ្ធិអំណាចរបស់ស្ត្រី គឺជាកត្តាកំណត់លទ្ធផលអាហារូបត្ថម្ភក្នុងគ្រួសារនីមួយៗ។

ការធ្វើចំណាកស្រុករបស់ប្រជាជន ជាពិសេសយុវជននៅតាមជនបទ ក្នុងការស្វែងរកការងារ ដើម្បីបង្កើនប្រាក់ចំណូល គឺមានជាទូទៅនៅក្នុងប្រទេសកម្ពុជា ហើយបង្កឱ្យមានផលប៉ះពាល់មួយចំនួនដល់សន្តិសុខស្បៀងក្នុងគ្រួសារ។ កម្រិតខ្ពស់នៃការធ្វើចំណាកស្រុក បានបណ្ដាលឱ្យមានការកើនឡើងនៃចំនួនគ្រួសារដែលមានស្ត្រីជាមេគ្រួសារ ដែលជាបាតុភូតមួយ ត្រូវបានទទួលស្គាល់នៅក្នុងគោលនយោបាយ ស្ដីពីការបញ្ជ្រាបយេនឌ័រ និងក្របខណ្ឌយុទ្ធសាស្ត្រក្នុងវិស័យកសិកម្មឆ្នាំ២០១៦-២០២០ (MAFF 2015) ដូចដែលបានរៀបរាប់នៅខាងដើម។ តាមការសង្កេត អ្នកចូលរួមឆ្លើយសំណួរមកពីគ្រួសារដែលមានស្ត្រីជាមេគ្រួសារ និងដែលមានសមាជិកគ្រួសារបានធ្វើចំណាកស្រុក ជារឿយៗតែងតែគាំទ្រនិន្នាការនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានបង្ហាញនៅក្នុងទិន្នន័យ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ គឺស្ថិតក្នុងចំណោមជនងាយរងគ្រោះបំផុត ដោយប្រឈមខ្លាំងចំពោះអសន្តិសុខស្បៀង ការលំបាកធ្ងន់ធ្ងរក្នុង

ការទទួលបានធនធាន និងហិរញ្ញវត្ថុ និងការកាត់បន្ថយសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ទន្ទឹមនឹងនេះ ការសិក្សារបស់ Sithirith et al. (2024) បានរកឃើញថា ការកើនឡើងនៃការធ្វើចំណាកស្រុកនៅតាមទីក្រុង និងក្រៅប្រទេស បាននាំឱ្យមានការកើនឡើងលើការទទួលទានអាហារដែលខ្វះសារធាតុចិញ្ចឹម ដូចជាអាហាររហ័ស មីកញ្ចប់ និងភេសជ្ជៈមានជាតិស្ករជាដើម ដោយបានបង្ហាញឱ្យឃើញពីទម្លាប់ និងវប្បធម៌នៃការបរិភោគអាហារតាមបែបអ្នកនៅជនបទ និងអ្នកនៅទីក្រុង។ និន្នាការបែបនេះធ្វើឱ្យអសន្តិសុខស្បៀងកាន់តែធ្ងន់ធ្ងរ កាត់បន្ថយផលិតភាពជនបទ និងចំណេះដឹងផ្នែកកសិកម្ម និងធ្វើឱ្យលទ្ធផលអាហារូបត្ថម្ភកាន់តែដុនដាបសម្រាប់ប្រជាជនដែលងាយរងគ្រោះ។ ដូច្នេះគេគួរតែពិចារណាលើការដោះស្រាយបញ្ហាប្រឈមនៃសេដ្ឋកិច្ច-សង្គមទាក់ទងនឹងការធ្វើចំណាកស្រុក និងការផ្លាស់ប្តូរអាហារូបត្ថម្ភដែលតម្រូវឱ្យអនុវត្ត។

លទ្ធផលរកឃើញនៃការសិក្សានេះបង្ហាញថា លទ្ធភាពទទួលបានព័ត៌មាន ស្តីពីអាហារូបត្ថម្ភដែលមានលក្ខណៈមិនស្មើគ្នា និងមានកម្រិត គឺជាឧបសគ្គដ៏ធំក្នុងការសម្រេចបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា។ ជាទូទៅ អ្នកចូលរួមឆ្លើយសំណួរបានបង្ហាញពីការយល់ដឹងជាមូលដ្ឋានលើគោលគំនិតអាហារូបត្ថម្ភសំខាន់ៗ និងតួនាទីរបស់ពួកគេក្នុងការធានាសុខភាព និងសុខុមាលភាពបុគ្គល ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ លទ្ធភាពទទួលបានការអប់រំស្តីពីអាហារូបត្ថម្ភជាលក្ខណៈផ្លូវការ និងទូលំទូលាយ ត្រូវបានរារាំងដោយវិសមភាពសេដ្ឋកិច្ច-សង្គម និងយេនឌ័រ ដែលបណ្តាលឱ្យមានគម្លាតយ៉ាងធំផ្នែកចំណេះដឹងស្តីពីអាហារូបត្ថម្ភ ជាពិសេសក្នុងចំណោមស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រ។ បទពិសោធន៍របស់អ្នកចូលរួមឆ្លើយសំណួរ ដែលបានចងក្រងជាឯកសារក្នុងការសិក្សានេះបង្ហាញថា បញ្ហាវិសមភាពនេះកើតមានជាទូទៅនៅទូទាំងប្រទេសកម្ពុជា។ វាស្របទៅនឹងការរកឃើញពីការអង្កេតស្រាវជ្រាវរបស់ Wallace et al. (2014) លើការទទួលបានសារធាតុចិញ្ចឹមរបស់ស្ត្រីរស់នៅក្នុងខេត្តកណ្តាល។ ទោះបីជាការសិក្សារបស់ Wallace et al. (2014) បានគ្របដណ្តប់លើទីតាំងផ្សេងគ្នា និងមានការផ្តោតទៅលើការស្រាវជ្រាវផ្សេងគ្នាក៏ដោយ ក៏ការសិក្សានេះបានឈ្វេងយល់អំពីកម្រិតនៃចំណេះដឹងផ្នែកអាហារូបត្ថម្ភផងដែរ ដោយបានសន្និដ្ឋានថា ការអប់រំសុខភាពមិនត្រូវបានរួមបញ្ចូលគ្រប់គ្រាន់ និងមិនបានគិតគូរពីភាពខុសគ្នានៃការរស់នៅជាក់ស្តែង និងការអនុវត្តរបស់ក្រុមមនុស្សផ្សេងៗគ្នា។ ដោយសារស្ត្រីមានតួនាទីស្នូល ក្នុងការធានាសន្តិសុខស្បៀងក្នុងគ្រួសាររបស់ពួកគេ ដូច្នេះគេត្រូវកំណត់គោលដៅអន្តរាគមន៍ចាំបាច់ ដើម្បីសម្រេចបាននូវសិទ្ធិទទួលបានព័ត៌មានស្តីពីអាហារូបត្ថម្ភប្រកបដោយសមធម៌។

លើសពីនេះ ការសិក្សានេះបានរកឃើញនូវទំនោរងាកឆ្ពោះទៅរកដំណើរការរៀបចំផែនការអភិវឌ្ឍន៍ តាមរយៈការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើនសមត្ថភាពផលិតកម្មស្បៀង ជាជាងការផ្តល់អាទិភាពលើគំនិតផ្តួចផ្តើមក្នុងគោលដៅលើកកម្ពស់ការយល់ដឹងអំពីទិដ្ឋភាពនៃការផលិត និងការប្រើប្រាស់ស្បៀងអាហារ។ ជាការពិតណាស់កិច្ចខិតខំប្រឹងប្រែងទាំងនេះច្រើនតែត្រូវបានមើលរំលងពីកត្តាសំខាន់នេះ ដោយការផ្តោតអារម្មណ៍និន្នាការទៅលើការបង្កើនបរិមាណអាហារដែលត្រូវផលិត (ឧទាហរណ៍ ផលិតកម្មស្រូវ) ជាជាងគុណភាពនៃអាហារទាក់ទងនឹងគុណតម្លៃអាហារូបត្ថម្ភ។ វាក៏មានគម្លាតគួរឱ្យកត់សម្គាល់ ក្នុងការដោះស្រាយទិដ្ឋភាពអាហារូបត្ថម្ភនៃសន្តិសុខស្បៀង នៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ ដោយបង្ហាញថា សារៈសំខាន់នៃអាហារូបត្ថម្ភក្នុងការធានាសន្តិសុខស្បៀង និងសុខុមាលភាពបុគ្គល មិនត្រូវបានទទួលស្គាល់គ្រប់ជ្រុងជ្រោយ ឬមិនបានដាក់បញ្ចូលទៅក្នុង យុទ្ធសាស្ត្រអភិវឌ្ឍន៍ក្នុងមូលដ្ឋាននោះទេ។ ដូច្នេះ វាចង្អុលបង្ហាញពីតម្រូវការចាំបាច់ សម្រាប់ការរួមបញ្ចូលការអប់រំអាហារូបត្ថម្ភទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហាសន្តិសុខស្បៀងប្រកបដោយប្រសិទ្ធភាព។

ឧបសគ្គផ្លូវការ ចំពោះការទទួលទានអាហារ និងស្ថានភាពនៃការទទួលបានសារធាតុចិញ្ចឹមក្នុងប្រទេសកម្ពុជាច្រើនតែត្រូវបានផ្សារភ្ជាប់ទៅនឹងការចំណាយលើវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ ការសិក្សានេះបានបង្ហាញថា គ្រួសារជាច្រើនប្រឈមនឹងបញ្ហាធំ នៅពេលនិយាយអំពីការផលិតស្បៀង៖ អ្នកចូលរួមឆ្លើយសំណួរបានកត់សម្គាល់ថា ការចំណាយខ្ពស់លើថ្លៃអង្ករ ប្រេងសាំង និងធាតុចូលកសិកម្មដូចជា ជី គ្រាប់ពូជ និងថ្នាំសម្លាប់សត្វល្អិត គួបផ្សំនឹងកំណើននៃការប្រកួតប្រជែងចំពោះបញ្ហាទឹក តម្លៃទីផ្សារទាប និងទិន្នផលកសិកម្មទាប បានធ្វើឱ្យមានភាពតានតឹងផ្នែកហិរញ្ញវត្ថុដល់កសិករ និងគំរាមកំហែងដល់សន្តិសុខស្បៀងអាហារ និងជីវភាពរស់នៅរបស់ពួកគេ។ ការធ្លាក់ចុះនៃទិន្នផល ក៏ឆ្លុះបញ្ចាំងពីបញ្ហាប្រឈមជាច្រើនដល់វិស័យកសិកម្មរបស់ប្រទេសកម្ពុជាផងដែរ ដោយសារការកើនឡើងនៃសីតុណ្ហភាពអាកាសធាតុ និងលំនាំអាកាសធាតុខុសប្រក្រតី ដូចដែលបានរកឃើញនៅក្នុងការស្រាវជ្រាវពីមុន

(Alvar-Beltrán et al. 2022; Chhinh and Poch 2012; Korn 2021; Sok et al. 2)។ ម្យ៉ាងទៀត កង្វះសេវាកម្មផ្សព្វផ្សាយ និងការគាំទ្រផ្នែកបច្ចេកទេស បានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងនូវផលប៉ះពាល់ជារួមក្នុងចំណោមអ្នកឆ្លើយសំណួរក្នុងការសិក្សានេះ ដោយមិនគិតពីសារតារសេដ្ឋកិច្ច-សង្គម។ បញ្ហានេះកើតឡើងជាពិសេស ដោយសារកង្វះការយល់ដឹងរបស់កសិករអំពីរបៀបប្រើប្រាស់ធាតុចូលកសិកម្មឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ដូចដែលបានលើកឡើងដោយ Korn (2021)។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយគម្លាតទាំងនេះក្នុងការផ្តល់សេវាផ្សព្វផ្សាយ ដើម្បីគាំទ្រដល់វិស័យកសិកម្ម និងធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

សមត្ថភាពស្ថាប័នមានកម្រិត និងការសម្របសម្រួលទន់ខ្សោយរវាងភ្នាក់ងាររដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ បង្កបញ្ហាប្រឈមបន្ថែមទៀតសម្រាប់ប្រទេសកម្ពុជា នៅពេលនិយាយអំពីអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ម្យ៉ាងវិញទៀត អាជ្ញាធរឃុំតែងតែលើកឡើងថា ខ្លួនគ្មានធនធានគ្រប់គ្រាន់សម្រាប់ជួយប្រជាជន ឬផ្តល់ការណែនាំអំពីអាហារូបត្ថម្ភ ជាពិសេសក្នុងអំឡុងពេលមានភាពតានតឹងផ្នែកសេដ្ឋកិច្ច និងវិបត្តិទាក់ទងនឹងអាកាសធាតុ ដូចជាគ្រោះទឹកជំនន់ ឬគ្រោះរាំងស្ងួត។ ការសិក្សានេះបានកំណត់ពីភាពមិនស៊ីសង្វាក់គ្នានៃវិធីសាស្ត្រដែលអាជ្ញាធរឃុំ ទាំងក្នុងទីតាំងសិក្សា និងនៅជុំវិញខេត្ត ដោះស្រាយបញ្ហាអសន្តិសុខអាហារ និងអាហារូបត្ថម្ភ ជាពិសេសបង្ហាញឱ្យឃើញពីការបែងចែកអាទិភាពនៃអាហារូបត្ថម្ភ ដែលមានលក្ខណៈមិនស្មើគ្នានៅក្នុងក្របខណ្ឌសន្តិសុខស្បៀង និងគម្រោងផ្សព្វផ្សាយព័ត៌មាន។ បញ្ហានេះត្រូវបានឆ្លុះបញ្ចាំងនៅថ្នាក់ខេត្ត ជាមួយនឹងមន្ទីរពាក់ព័ន្ធ និងស្ថាប័នគ្រប់គ្រងធនធានដែលកំពុងធ្វើការងារផ្នែកផ្សព្វផ្សាយព័ត៌មាន ស្តីពីអាហារូបត្ថម្ភនៅកម្រិតផ្សេងៗគ្នា។ កង្វះនៃវិធីសាស្ត្រស្អិតរមួតនៅគ្រប់កម្រិតនៃអភិបាលកិច្ច ចង្អុលបង្ហាញពីតម្រូវការចាំបាច់សម្រាប់យុទ្ធសាស្ត្ររួមបញ្ចូលគ្នាកាន់តែច្បាស់លាស់ ដើម្បីដោះស្រាយបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រកបដោយប្រសិទ្ធភាព និងដើម្បីសម្រេចបាននូវគោលបំណងដែលមានចែងនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (NSFSN)។

តាមការរាយការណ៍របស់អ្នកចូលរួមឆ្លើយសំណួរក្នុងការសិក្សានេះ បានបញ្ជាក់ថា ការផ្លាស់ប្តូររបបអាហារទៅរកអាហារដែលមានជីវជាតិតិច ក្នុងអំឡុងពេលមានប្រាក់ចំណូលទាប ពិតជាមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើសុខភាពរាងកាយ និងសុខុមាលភាពរបស់សមាជិកគ្រួសារទាំងមូល ដូចដែលបានលើកឡើងនៅក្នុងវិរចនាឯកសារ (Peña and Bacallao, 2002)។ ជាការពិតណាស់ ការបាត់បង់គុណភាពរបបអាហាររបស់មនុស្សម្នាក់ៗ អាចនាំឱ្យមានកង្វះសារធាតុចិញ្ចឹម និងបញ្ហាសុខភាពរាងកាយផ្សេងទៀត ដូចជាជំងឺស្លេកស្លាំង ខ្វះគ្រាប់ឈាម និងជំងឺទឹកនោមផ្អែម ដែលនាំឱ្យបាត់បង់ផលិតភាព និងប្រាក់ចំណូល។ ទោះជាយ៉ាងណាក៏ដោយ គេក៏មិនគួរមើលរំលងចំពោះផលប៉ះពាល់ផ្លូវចិត្តផងដែរ។ ការស្រាវជ្រាវបានបង្ហាញថា ការទទួលទានអាហារមិនគ្រប់គ្រាន់ ឬមិនអាចទិញអាហារសម្បូរជីវជាតិគ្រប់គ្រាន់ មានផលប៉ះពាល់យ៉ាងសំខាន់ចំពោះសុខភាពផ្លូវចិត្ត និងសុខុមាលភាពបុគ្គល (Ejiohuo et al. 2024; Thompson 2021)។ របាយការណ៍ដែលផលិតដោយ Royal Holloway នៃសាកលវិទ្យាល័យឡុនដុន បានរកឃើញថា ភាពតានតឹងផ្លូវចិត្តដែលទាក់ទងនឹងការជំពាក់បំណុល ធ្វើការលើសកម្រិត និងការផ្តាច់ខ្លួនចេញពីសង្គម ដើម្បីបំពេញតម្រូវការរបបអាហារប្រចាំថ្ងៃ បាននាំឱ្យអត្រានៃការថប់បារម្ភ និងសុខភាពផ្លូវចិត្តកើនឡើងក្នុងចំណោមប្រជាជនកម្ពុជានៅតាមជនបទ ដែលជំរុញឱ្យមានវដ្តនៃភាពក្រីក្រ និងអសន្តិសុខអាហារ និងអាហារូបត្ថម្ភ (Iskander et al. 2022)។ ដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ដែលត្រូវបានព្យាករថានឹងបង្កើនភាពមិនច្បាស់លាស់ផ្នែកហិរញ្ញវត្ថុ និងអសន្តិសុខស្បៀងក្នុងប៉ុន្មានឆ្នាំខាងមុខ អាចលេចចេញជាបញ្ហាបន្ទាន់មួយ ដោយគូសបញ្ជាក់អំពីតម្រូវការក្នុងការបង្កើតសំណាញ់សុវត្ថិភាពសង្គម និងប្រព័ន្ធគាំទ្រ ដែលផ្តល់ឱ្យគ្រួសារនីមួយៗនូវជំនួយសម្រាប់ដោះបំណុល និងជំនួយហិរញ្ញវត្ថុក្នុងគ្រាលំបាក។

## ៦. សេចក្តីសន្និដ្ឋាន

បឹងទន្លេសាប និងដីសណ្តទន្លេមេគង្គរបស់ប្រទេសកម្ពុជា ដែលជាប្រព័ន្ធអេកូឡូស៊ី-សង្គម កំពុងប្រឈមមុខនឹងបញ្ហាមួយចំនួន ដោយសារតែការគំរាមកំហែងទ្វេរដងនៃការប្រែប្រួលអាកាសធាតុ និងកំណើនសេដ្ឋកិច្ចក្នុងតំបន់។ ការគំរាមកំហែងទាំងនេះ មានផលប៉ះពាល់យ៉ាងទូលំទូលាយ ទៅដល់សន្តិសុខស្បៀងទាំងលើវិសាលភាពក្នុងស្រុក និងពិភពលោក។ នៅក្នុងប្រទេសកម្ពុជា អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ គឺជាបញ្ហាដែលកំពុងរីករាលដាល ទោះបីជាមានជម្រើសអាហារដែលត្រូវការសម្រាប់បំពេញរបបអាហារចម្រុះក៏ដោយ។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះគឺមានសារៈសំខាន់សម្រាប់និរន្តរភាព និងសុខុមាលភាពរបស់សហគមន៍ដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ី-សង្គម។ ការសិក្សាស្រាវជ្រាវនេះ បង្ហាញពីទំនាក់ទំនងស្មុគស្មាញនៃឧបសគ្គផ្លូវការ និងក្រៅផ្លូវការ ដែលប៉ះពាល់ដល់ការទទួលទានអាហារ និងការទទួលបានអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជា។

ឧបសគ្គក្រៅផ្លូវការចំពោះរបបអាហារពេញលេញ និងមានជីវជាតិគ្រប់គ្រាន់ ត្រូវបានចាក់ឫសយ៉ាងជ្រៅនៅក្នុងបទដ្ឋានសង្គមផ្អែកលើយេនឌ័រ និងសក្តានុពលគ្រួសារនីមួយៗ។ តួនាទីយេនឌ័រត្រូវបានគេរកឃើញថា មានឥទ្ធិពលយ៉ាងសំខាន់ទៅលើលំអាននៃការបរិភោគ ទម្លាប់នៃរបបអាហារ ក៏ដូចជាការទទួលបានអាហារូបត្ថម្ភ។ ជាពិសេសសម្រាប់ស្ត្រីជាមេគ្រួសារ តែងតែទទួលរងនូវបញ្ហាប្រឈមទាំងនេះ។ ទោះបីជាមានការយល់ដឹងជាមូលដ្ឋានខ្លះអំពីអាហារូបត្ថម្ភក៏ដោយ ក៏ចំណេះដឹងនេះ នៅមិនទាន់បានស៊ីជម្រៅទេ ជាពិសេសក្នុងចំណោមគ្រួសារក្រីក្រ ដែលមានគម្លាតយេនឌ័រលើការយល់ដឹងអំពីអាហារូបត្ថម្ភផងដែរ។ ការសិក្សានេះបង្ហាញពីភាពខុសគ្នាយ៉ាងខ្លាំង ក្នុងការទទួលបានការអប់រំអាហារូបត្ថម្ភជាផ្លូវការនៅតាមសាលារៀន ដោយសារចំណេះដឹងសំខាន់ៗជាច្រើន មិនត្រូវបានបង្រៀនក្នុងអំឡុងឆ្នាំសិក្សានោះទេ។

ម៉្យាងវិញទៀត ឧបសគ្គផ្លូវការត្រូវបានផ្សារភ្ជាប់ជាមួយនឹងការចំណាយលើវិស័យកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំអភិបាលកិច្ចមិនទាន់គ្រប់គ្រាន់។ ការចំណាយខ្ពស់លើធាតុចូលកសិកម្ម និងការប្រែប្រួលអាកាសធាតុដែលបង្កឡើងដោយគ្រោះគ្រាបរិស្ថាន បង្កបញ្ហាប្រឈមក្នុងការធ្វើកសិកម្មជាពិសេសក្នុងចំណោមស្ត្រីជាមេគ្រួសារ និងស្ត្រីដែលមានប្រាក់ចំណូលតិចតួច។ ជាងនេះទៅទៀត ដោយសារតែដីស្រែចម្ការនៅឆ្ងាយពីប្រភពទឹក បូករួមនឹងការកើនឡើងនៃថ្លៃប្រេងសាំងសម្រាប់ប្រើម៉ាស៊ីនបូមទឹក និងការកើនឡើងតម្លៃស្រូវ បាននាំឱ្យកើនឡើងនូវការប្រកួតប្រជែងលើបញ្ហាទឹក។ នេះហើយដែលជាបញ្ហាប្រឈមធំបំផុត ចំពោះអ្នកដែលមានដីសម្រែចម្ការនៅឆ្ងាយពីប្រភពទឹក។ ការសិក្សាក៏បានបង្ហាញផងដែរថា គ្រួសារខ្លះប្រឈមមុខនឹងការលំបាកខ្លាំងក្នុងការផលិតស្បៀង ដោយសារការកើនឡើងថ្លៃដើម ទិន្នផលថយចុះ និងតម្លៃទីផ្សារចុះទាប។ ទោះបីជាមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតគួរឱ្យកត់សម្គាល់ទាក់ទងនឹងគំនិតផ្តួចផ្តើមបង្កើនការយល់ដឹងអំពីអាហារូបត្ថម្ភ ដោយផ្តោតលើការបង្កើនបរិមាណស្បៀងដែលមានស្រាប់ ជាជាងគុណភាពនៃស្បៀងប្រកបដោយអាហារូបត្ថម្ភ។

បញ្ហាទាំងនេះ បានរីករាលដាលពាសពេញតំបន់ផ្សេងៗទៀត ហើយបានបង្កការគំរាមកំហែងយ៉ាងធំដល់សន្តិសុខស្បៀង ជីវភាពរស់នៅ និងសុខុមាលភាពទូទៅ ដែលទាមទារជាចាំបាច់ឱ្យមានវិធីសាស្ត្រទូលំទូលាយក្នុងការដោះស្រាយឧបសគ្គផ្លូវការ និងក្រៅផ្លូវការទាំងនេះ ដើម្បីបង្កើនលទ្ធភាពទទួលបានស្បៀងអាហារ និងសារធាតុចិញ្ចឹម។ ចំណុចនេះតម្រូវឱ្យមានជាចាំបាច់នូវយុទ្ធសាស្ត្រពហុវិមាត្រដែលគិតគូរពីកត្តាសេដ្ឋកិច្ច-សង្គម និងបរិស្ថានដ៏ស្មុគស្មាញ ទន្ទឹមនឹងការលើកកម្ពស់ការអនុវត្តប្រកបដោយនិរន្តរភាព ការលើកកម្ពស់ចំណេះដឹងអាហារូបត្ថម្ភ និងដំណោះស្រាយបញ្ហាឫសគល់នៃឧបសគ្គទាំងនេះ។ មានតែតាមរយៈយុទ្ធសាស្ត្រទាំងនេះប៉ុណ្ណោះ ទើបយើងមានក្តីសង្ឃឹមក្នុងការធានាសន្តិសុខស្បៀង និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលរស់នៅតំបន់ដីសណ្តទន្លេមេគង្គ និងតំបន់ផ្សេងៗទៀត។

## ៧. អនុសាសន៍

ជាមួយនឹងលទ្ធផលរកឃើញទាំងអស់នេះ ការសិក្សាស្រាវជ្រាវបានស្នើឱ្យមានកិច្ចអន្តរាគមន៍មួយចំនួន ក្នុងគោលបំណងបង្កើនលទ្ធភាពទទួលបានព័ត៌មានស្តីពីអាហារូបត្ថម្ភ កាត់បន្ថយឧបសគ្គនៃផលិតកម្មស្បៀង និងការគាំទ្រក្រុម ឬគ្រួសារដែលងាយរងគ្រោះ ដើម្បីដោះស្រាយបញ្ហាប្រឈមភ្លាមៗ តាមរយៈការកសាងភាពធន់ក្នុងគ្រួសារនីមួយៗ និងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភរយៈពេលវែង។

- **ការចូលរួមរបស់សហគមន៍៖** សហគមន៍ចាំបាច់ត្រូវចូលរួមនៅក្នុងការរចនា និងការគ្រប់គ្រងសេវាកម្មទាក់ទងនឹងអាហារូបត្ថម្ភ និងសេវាផ្សព្វផ្សាយព័ត៌មាន។ ពួកគេគួរតែមានលទ្ធភាពទទួលបានសេវាទាំងនេះ (រួមទាំងសុខភាព ទឹកស្អាត កសិកម្ម និងការគាំពារសង្គម) ដែលពួកគេត្រូវការជាចាំបាច់ និងប្រាថ្នាទទួលបានអាហារូបត្ថម្ភ និងសន្តិសុខស្បៀងល្អបំផុត។ ការពង្រឹងផែនការអភិវឌ្ឍន៍ឃុំ និងផែនការវិនិយោគឃុំបីឆ្នាំរំកិលសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ គឺជារឿងចាំបាច់។
- **ជំនួយសង្គម៖** កម្មវិធីជំនួយសង្គមដែលមានគោលបំណងកាត់បន្ថយឧបសគ្គ ចំពោះសេវាសុខភាព និងអាហារសម្បូរជីវជាតិ អាចកាត់បន្ថយបានយ៉ាងច្រើននូវបញ្ហាកង្វះអាហារូបត្ថម្ភ។ ការពង្រីកកម្មវិធីជំនួយសង្គម ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ ដូចជាស្ត្រី និងកុមារ គឺជាការបោះជំហានយ៉ាងសំខាន់ឆ្ពោះទៅរកការសម្រេចបាននូវប្រព័ន្ធគាំពារសង្គមប្រកបដោយប្រសិទ្ធភាព និងសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅប្រទេសកម្ពុជា។
- **ការអប់រំផ្នែកអាហារូបត្ថម្ភ និងសមភាពយេនឌ័រ៖** ការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីលទ្ធភាពទទួលបានអាហារសម្បូរជីវជាតិដែលមានតម្លៃសមរម្យ និងការតស៊ូមតិ សម្រាប់ជម្រើសនៃការទទួលទានអាហារដែលផ្តល់សុខភាពល្អ គឺចាំបាច់ណាស់។ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់តួនាទីចម្បងរបស់ស្ត្រីក្នុងការគ្រប់គ្រងអាហារូបត្ថម្ភក្នុងគ្រួសារ និងសារៈសំខាន់នៃការអប់រំរបស់ពួកគេ នៅក្នុងតំបន់នេះ។ បុរសក៏គួរត្រូវបានរួមបញ្ចូលផងដែរនៅក្នុងការអប់រំអាហារូបត្ថម្ភ ការលើកកម្ពស់ការបែងចែកប្រកបដោយតុល្យភាពលើកិច្ចការក្នុងគ្រួសារ និងការលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភជារួមនៅក្នុងគ្រួសារនីមួយៗ។
- **ការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ៖** ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ អាចធ្វើឱ្យកាន់តែធ្ងន់ធ្ងរដល់ឧបសគ្គដែលក្រុមងាយរងគ្រោះ ដូចជា ស្ត្រី និងកុមារ ដែលត្រូវប្រឈមមុខក្នុងការសម្រេចបាននូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការកសាងភាពធន់នៅក្នុងប្រព័ន្ធផលិតកម្ម និងចែកចាយស្បៀងអាហារ ដើម្បីសម្រេចឱ្យបាននូវស្ថិរភាពក្នុងការផលិត និងការប្រើប្រាស់ស្បៀងអាហារ តាមរយៈប្រព័ន្ធអាហារដែលមានភាពធន់។

## ៨. ដែនកំណត់ និងទិសដៅសម្រាប់ការស្រាវជ្រាវបន្ថែម

ការសិក្សាស្រាវជ្រាវក្នុងបច្ចុប្បន្ននេះ មានដែនកំណត់មួយចំនួនដែរ។ ទីមួយ លទ្ធផលរកឃើញត្រូវបានកំណត់តាមរយៈបទពិសោធន៍របស់ក្រុមអ្នកចូលរួមឆ្លើយសំណួរ ដែលរស់នៅតំបន់ជនបទនៃខេត្តទាំងពីរ ហើយមិនឆ្លុះបញ្ចាំងពីស្ថានភាពសន្តិសុខស្បៀងអាហារ និងអាហារូបត្ថម្ភនៅទូទាំងប្រទេសកម្ពុជាជាទូទៅទេ ជាពិសេស នៅតំបន់ទីក្រុងដែលមានប្រជាជនរស់នៅ ជួបបញ្ហាប្រឈមខុសៗគ្នាច្រើន (Boonyabancha et al. 2019)។ អ្វីដែលមានសារៈសំខាន់ជាពិសេសក្នុងការពិចារណានេះ មិនខុសពីអ្វីដែលបានរៀបរាប់ពីខាងដើមនោះទេ គឺថាតំបន់ដែលបានសិក្សាហាក់ដូចជាខុសប្លែកពីប្រក្រតីនៅក្នុងបរិបទនៃប្រទេសកម្ពុជា ដែលគ្រួសារជាច្រើនបានប្រកបរបរចិញ្ចឹមសត្វ និងដាំបន្លែបង្ការនៅជុំវិញផ្ទះ ជាជាងសកម្មភាពធម្មតានៃការដាំដុះស្រូវ និងការនេសាទ។ លើសពីនេះទៀត ទន្ទឹមនឹងការសិក្សានេះបានបង្ហាញពីបទពិសោធន៍របស់បុគ្គលមកពីសារតារសេដ្ឋកិច្ច-សង្គមផ្សេងៗ និងតួនាទីនៅក្នុងសហគមន៍របស់ពួកគេ ទស្សនៈបានពីភាគីពាក់ព័ន្ធផ្សេងទៀត ដូចជាអ្នកផ្តល់សេវាថែទាំសុខភាព ដែលចូលរួមជាប្រចាំជាមួយសហគមន៍ទាំងនេះ និងដោះស្រាយបញ្ហាពាក់ព័ន្ធ មិនត្រូវបានរាប់បញ្ចូលនោះទេ។ គួរកត់សម្គាល់ថា លទ្ធផលរកឃើញទាំងនេះ មិនបានចាប់សេចក្តីទាំងស្រុងលើនិន្នាការរយៈពេលវែងនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជានោះទេ។

ដូច្នេះ ការសិក្សានេះបានផ្តល់ជាការណែនាំខ្លះៗដូចខាងក្រោម សម្រាប់ការស្រាវជ្រាវជាបន្តនាពេលអនាគត៖

- ធ្វើការសិក្សាស្រាវជ្រាវឱ្យបានទូលំទូលាយស្រដៀងគ្នានេះ លើការប្រើប្រាស់ស្បៀងអាហារ និងការទទួលបានអាហារូបត្ថម្ភនៅក្នុងតំបន់ទីក្រុង ដើម្បីទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅ អំពីការអនុវត្តការប្រើប្រាស់ និងលទ្ធផលអាហារូបត្ថម្ភនៅប្រទេសកម្ពុជា ដោយសារស្ថានភាពសេដ្ឋកិច្ច-សង្គមនៅតំបន់ជនបទមានលក្ខណៈខុសប្លែកគ្នាពីនៅក្នុងទីក្រុង។
- ធ្វើការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យ ដោយប្រើទិន្នន័យស្ទង់មតិ ដើម្បីប្រៀបធៀប និងវាយតម្លៃអត្រាប្រេវ៉ាឡង់ និងភាពធ្ងន់ធ្ងរនៃកត្តាផ្សេងៗ ដែលប៉ះពាល់ដល់ការទទួលបានអាហារូបត្ថម្ភនៅទូទាំងតំបន់ទីក្រុង និងជនបទផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា។
- ធ្វើការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធនឹងអ្នកផ្តល់សេវាថែទាំសុខភាព អ្នកអនុវត្តផ្ទាល់ ឬអ្នកស្ម័គ្រចិត្ត ដើម្បីទទួលបានទស្សនៈយល់ឃើញរបស់ពួកគេ លើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភនាពេលបច្ចុប្បន្ន និងកំណត់បញ្ហាប្រឈមសំខាន់ៗក្នុងការថែទាំសុខភាព និងការគាំពារសង្គម ដែលទាមទារជាចាំបាច់ឱ្យមានការយកចិត្តទុកដាក់ ដើម្បីដោះស្រាយបញ្ហាទាំងនេះប្រកបដោយប្រសិទ្ធភាព។
- ធ្វើការសិក្សាស្រាវជ្រាវបន្ថែម ដោយការវាយតម្លៃពីផលប៉ះពាល់នៃការអនុវត្តកសិកម្មប្រកបដោយ និរន្តរភាព (ដូចជាកសិកម្មឆ្លាតវៃ ឬកសិកម្មអភិរក្ស) លើសន្តិសុខស្បៀង និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជានៅតំបន់ជនបទ។

# ឧបសម្ព័ន្ធ

តារាង ក១៖ ព័ត៌មានលម្អិតនៃក្រុមគោលដៅ និងទីតាំងសិក្សាសម្រាប់ការសម្ភាស

| ខេត្ត | ស្រុក | ឃុំ | ភូមិ | ការពិភាក្សាក្រុម (FDG) | ការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ (KII) |
|---|---|---|---|---|---|
| **ស្រះជម្រកត្រីសហគមន៍បឹងរៀម** | | | | | |
| • កំពង់ធំ | សន្ទុក | កកោះ | • ជ័យជំនះ<br>• សំណាក | ១. FGD ជាមួយស្ត្រីដែលជាមេគ្រួសាររស់នៅជុំវិញស្រះជម្រកត្រីសហគមន៍បឹងរៀម (២ ក្រុម)<br>២. FGD ជាមួយស្ត្រីដែលស្ថិតក្នុងគ្រួសារក្រីក្រនៃស្រះជម្រកត្រីសហគមន៍បឹងរៀម (២ ក្រុម)<br>៣. FGD ជាមួយបុរសដែលស្ថិតក្នុងគ្រួសារក្រីក្ររស់នៅជុំវិញស្រះជម្រកត្រីសហគមន៍បឹងរៀម (២ ក្រុម)<br>៤. FGD ជាមួយស្ត្រីដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្ររស់នៅជុំវិញស្រះជម្រកត្រីសហគមន៍បឹងរៀម (២ ក្រុម)<br>៥. FGD ជាមួយបុរសដែលមិនមែនស្ថិតក្នុងគ្រួសារក្រីក្ររស់នៅជុំវិញស្រះជម្រកត្រីសហគមន៍បឹងរៀម (២ ក្រុម) | ១. KII ជាមួយអនុប្រធានភូមិសំណាក<br>២. KII ជាមួយប្រធានភូមិជ័យជំនះ<br>៣. KII ជាមួយសមាជិកក្រុមប្រឹក្សាឃុំកកោះ<br>៤. KII ជាមួយអនុប្រធានការិយាល័យកសិកម្ម ធនធានទឹក និងបរិស្ថានស្រុក<br>៥. KII ជាមួយនាយខណ្ឌរដ្ឋបាលជលផលខេត្តកំពង់ធំ<br>៦. KII ជាមួយអនុប្រធានស្រះជម្រកត្រីសហគមន៍<br>៧. KII ជាមួយប្រធានសហគមន៍កសិករអ្នកប្រើប្រាស់ទឹកតាំងក្រសាំង<br>៨. KII ជាមួយប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត<br>៩. KII ជាមួយអនុប្រធានមន្ទីរបរិស្ថានខេត្ត<br>១០. KII ជាមួយអនុប្រធានមន្ទីរកសិកម្មខេត្ត |
| **គម្រោងប្រព័ន្ធធារាសាស្ត្រតាសួង** | | | | | |
